# ក្ដីសង្ឃឹមអ្នកមានគុណ



រៀបរៀងដោយ
ខ្ញុំព្រះករុណា
ភិក្ខុ ចិន្ត កវី **ទូច ចន្ថា**

ផ្សាយចេញពីពុទ្ធិកសមាគមសមណនិស្សិតកម្ពុជា–ស្រីលង្កា

ព.ស. ២៥៥៦ គ.ស. ២០១៣

- ឈ្មោះសៀវភៅ : **ភ្លឺសច្ចធម៌អ្នកមានគុណ**
- រៀបរៀងដោយ : ភិក្ខុ ចិន្តកវី **ទូច ចន្ថា**
- ត្រួតពិនិត្យដោយ : **ក្រុមយុវសមណអ្នកនិពន្ធ**
- ឧបត្ថម្ភដោយ : ពុទ្ធបរិស័ទគ្រប់មជ្ឈដ្ឋាន
- ធ្វើចេញពីមាតុភូមិខ្ញុំ :វត្តព្រះចន្ទរង្សី ភូមិត្រពាំងម្លូរ ឃុំក្រាំងស្គារ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង នៃព្រះរាជាណាចក្រកម្ពុជា
- កាលបរិច្ឆេទធ្វើចប់ : ថ្ងៃពុធ ៧កើត ខែចេត្រ ឆ្នាំរោងចត្វាស័ក ព.ស.២៥៥៦ ត្រូវនឹងថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០១៣
- បោះពុម្ពលើកទី ១ : ចំនួន ៥.000 ក្បាល
- មួយក្បាលតម្លៃ : ៣.000 រៀល
- អស់ទឹកប្រាក់ចំនួន :១៥.000.000រៀល=៣.៧៥0ដុល្លារ
- រក្សាសិទ្ធិដោយ : ពុទ្ធកសមាគមសមណនិស្សិតកម្ពុជា-ស្រីលង្កា
- រោងពុម្ពឈ្មោះ : **ម៉ៅ ផុន** (ភ្នំពេញ)
- ចែកផ្សាយក្នុងឱកាស : បុណ្យធម្មទានទូទៅ
- ការផ្សាយរបស់ : ពុទ្ធកសមាគមសមណនិស្សិតកម្ពុជា-ស្រីលង្កា
- ផ្តល់មតិយោបល់ : ម្ចាស់សៀវភៅផ្ទាល់
- ទូរស័ព្ទ : 012 38 50 66/0៩៤ ៧៧៥ ៥៨១ ៦៨៦
- អ៊ីម៉ែល :chanthatuoch@yahoo.com

# នាមអ្នកមានឧបការៈក្នុងការចេញធម្មទាន

| | |
|---|---|
| -ព្រះអង្គគ្រូ **ស៊ឹម សំអួន** | -ព្រះអង្គគ្រូ **សុខ សុភាព** |
| -ព្រះអង្គគ្រូ **ផន សុឡា** | -លោកម្ចាស់ **សំ ស៊ីណាង** |
| -លោកម្ចាស់ **ស្លួន ចំរើន** | -លោកម្ចាស់ **ធី ចាន់ណា** |
| -លោកម្ចាស់ **ចក់ ចន្ធី** | -លោកម្ចាស់ **គឹន រិទ្ធី** |
| -លោកម្ចាស់ **គឹម ភាន** | -លោកគ្រូ **មួ ស៊ីផូ** |
| -លោកជំទាវ **យាន ហុនលី** | -ឧ.សិ. **ឆេង លៀង** |
| -ឧ.សិ.**ធម្ម ធន្ធី** | -ឧ.សិ.**អ៊ុក សៅភន** |
| - ញោម **គេន ម៉ៅ** | -ឧ.សិ.**លឹម ច័ន្ទនារី** |
| -ឧ.សិ. **ស្លួន ទ្រី** | -ឧ.ស. **សម សុខ** |
| -ឧ.ស.**ចាន់ ប៉ុន** | -ឧ.សិ.**ម៉ៅ ប្រាថ្នា** (USA) |
| -ឧ.សិ. **ពៅ ស៊ីវុដ្ឋា** | -ឧ.សិ.**អ៊ុល ណៃ** |
| -ឧ.សិ.**បាវ នុ** | -ឧ.សិ.**ម៉ៅ ស៊ីវន** |
| -ឧ.សិ. **កែ លីដា** | -ឧ.សិ.**ឡាយ ម៉ា** |
| -ឧ.សិ. **ឃុត ថន** | -ឧ.សិ.**អ៊ូច សុខុន** |
| -ឧ.ស. **អ៊្លូម សាលឿត** | -ឧ.ស.**សម កុសល្យ** |
| -ឧ.សិ.**អ៊ុយ ចាន្ធី** | -ឧ.សិ.**ឯក សារី** |
| -ឧ.សិ.**សុខ សុផានី** | -ឧ.ស. **ជា ពលរដ្ឋ** |

# អារម្ភកថា

សៀវភៅដែលមានឈ្មោះថា **ភ្លឺសង្ឃឹមអ្នកមានគុណ** មួយក្បាលនេះ កើតឡើងដោយវិរិយភាពរបស់ខ្ញុំ គឺជាឈ្មោះសៀវភៅក្បាលទីពីរនៅក្នុងវស្សាទី ៨ ថែមទាំងត្រូវនឹងព្រះជន្មាយុរបស់ខ្ញុំព្រះករុណា ២៤ ឈានចូល ២៥ ឆ្នាំរបស់ខ្ញុំព្រះករុណាផងដែរ ដោយការឆ្លៀតពេលវេលាខ្លះៗ ក្នុងវស្សានោះខ្ញុំព្រះករុណាក៏បានរៀបចំអត្ថបទនេះទុកសម្រាប់ធ្វើជាធម្មទាន។

ចំពោះសៀវភៅនេះមានអត្ថន័យយ៉ាងណា ខ្ញុំក៏មិនហ៊ានវាតម្លៃដែរ ដោយសារតែពេលនោះខ្ញុំព្រះករុណារស់នៅក្នុងកុដិតូច តែមានមិត្តសព្រហ្មចារីក្នុងការរស់នៅ រហូតទៅដល់ ៣ អង្គមានការពិភាក្សាគ្នាទៅវិញទៅមករកមធ្យោបាយ ធ្វើយ៉ាងណាដើម្បីការរស់នៅក្នុងសង្គមឱ្យបានល្អ។ ខ្ញុំព្រះករុណាបាននឹកឃើញគោលធម៌របស់ព្រះសម្មាសម្ពុទ្ធខ្លះៗ ក៏បានរកដំណោះស្រាយទុកជាប្រយោជន៍ខ្លះៗសម្រាប់ខ្លួនឯង ម្យ៉ាងទៀតដើម្បី កុំឱ្យបាត់បង់នូវឯកសារនេះផង គឺមានតែសរសេរជាអត្ថបទឱ្យបានកើតជាសៀវភៅមួយដ៏តូចស្តើងឈ្មោះថា **ភ្លឺសង្ឃឹមអ្នកមានគុណ** សម្រាប់ជនគ្រប់រូបអ្នកដែលស្រឡាញ់ការសិក្សា និងចង់ចេះចង់ដឹងនូវ សេចក្តីក្នុងអត្ថបទនេះ។

មួយទៀតសៀវភៅនេះ មិនបានរៀបរាប់ឱ្យពិស្តារអំពីព្រះគុណនោះទេ គ្រាន់តែមួយជ្រុងនៃគំនិត ដែលបាននៅសល់ពីការសិក្សាភ្លេចតែ

ប៉ុណ្ណោះ ទោះបីជាយ៉ាងណាក៏ដោយ ខ្ញុំព្រះករុណាសង្ឃឹមថាកូនសៀវភៅដ៏តូចមួយនេះ បានជាប្រយោជន៍ ខ្លះដល់មិត្តអ្នកអានទាំងឡាយមិនខាន។

ខ្ញុំសូមប្រាប់ដល់មិត្តអ្នកអានទាំងឡាយឱ្យបានជ្រាបថា ធម្មតាកម្រងផ្កាដែលគេក្រងមកនោះ គឺវាងាយនឹងក្រងបាន តែចំពោះអត្ថបទរបស់ខ្ញុំនេះ គឺមានការលំបាកខ្លះដែរ ព្រោះហេតុនេះហើយកំហុសឆ្គងទាំងឡាយដោយអចេតនាតែងមានជាពុំខាន ដូច្នេះសូមអភ័យនូវទោសានុទោសទាំងប៉ុន្មានដែលកើតមានឡើងក្នុងសៀវភៅនេះ។ ខ្ញុំព្រះករុណាសូមរង់ចាំទទួលយកនូវការរិះគន់ដើម្បីស្ថាបនា កែលំអដោយក្ដីរីករាយ សម្រាប់ការបោះពុម្ពនៅពេលក្រោយៗទៀត។

# សម្មោទនីយកថា

ការមានជំងឺផ្លូវកាយគេអាចចូលទៅរកវេជ្ជបណ្ឌិត ដើម្បីឱ្យព្យាបាល ឬស្វែងរកឱសថមកទទួលទានដើម្បីកម្ចាត់រោគទាំងនោះ យ៉ាងណាកាល បើចិត្តនៃបុគ្គលមានជំងឺ គឺលោភៈ ទោសៈ និងមោហៈ បុគ្គលនោះក៏ចាំ បាច់ត្រូវចូលទៅរកវេជ្ជបណ្ឌិត ព្រះសម្មាសម្ពុទ្ធ ដោយស្វែងរកឱសថ គឺព្រះ ធម៌ ដើម្បីព្យាបាលផ្លូវចិត្ត ព្រមទាំងចូលមកសេពគប់នឹងសប្បុរស គឺព្រះ សង្ឃ ដើម្បីឱ្យលោកជួយប្រាប់ផ្លូវជីវិតក៏យ៉ាងនោះដែរ។

ខ្ញុំបានអាន និងពិនិត្យអត្ថបទនេះទាំងស្រុង យល់ឃើញថា ពិតជា មានខ្លឹមសារដល់ពុទ្ធបរិស័ទ ដូចជាប្រទីបជួយបំភ្លឺផ្លូវជីវិតដូចច្នោះឯង។

អាស្រ័យហេតុនេះ ខ្ញុំសូមសរសើរចំពោះការរៀបរៀង និងចងក្រង នូវមាតិកាធម៌ រហូតបានសម្រេចជារូបរាងឡើង។ សូមប្រគេននូវព្រះពុទ្ធ ពរទាំងឡាយ ៤ ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ ចូរកើតមានដល់ លោក ម្ចាស់ចិន្តការី **ទូច ចន្ថា** កុំបីប្រែក្លាយទៅជាប្រការដទៃឡើយ។

**ធ្វើនៅប្រទេសស្រីលង្កា**,ថ្ងៃ៧កើត ខែចេត្រ ចត្វាស័ក ព.ស.២៥៥៦

ប្រធានពុទ្ធិកសមាគមសមណនិស្សិតកម្ពុជា-ស្រីលង្កា

ខ្ញុំព្រះករុណា **ធម្មប្បញ្ញោ ស៊ឹម សំអូន**

# មាតិកាធម៌


-មាតាបិតាមានឈ្មោះ ៤ យ៉ាង ........................................ ១
-ឧបមាព្រះរតនត្រ័យ ២២ យ៉ាង ........................................ ៤
-មហាបុរិសលក្ខណៈ ........................................ ៨
-សេចក្តីល្អរបស់ព្រះដ៏មានព្រះភាគសម្រាប់ជនច្រើនរូប .................. ១៤
-ពុទ្ធកាល ........................................ ២៥
-ពុទ្ធកិច្ចរបស់ព្រះសម្មាសម្ពុទ្ធ ........................................ ២៧
-ព្រះពុទ្ធគុណ ........................................ ២៩
-បុណ្យតែងជួយអ្នកដែលប្រព្រឹត្តល្អ ........................................ ៣២
-សេចក្តីល្អរបស់មិត្ត ........................................ ៣៨
-កូនត្រូវចេះថែរក្សាសុខភាព ........................................ ៤៦
-ធ្វើជាមនុស្សត្រូវចេះអភ័យទោស ........................................ ៤៩
-កូនត្រូវចេះឱ្យទានផង ........................................ ៥៦
-អានិសង្សនៃការឱ្យទាន ........................................ ៦០
-បុគ្គលអ្នកធ្វើបុណ្យបានផលឃើញនឹងភ្នែក ៦ រូបគឺ ...................... ៦២
-ឧត្តមបុរស ........................................ ៦៤
-នាមអ្នកពោល នមោ គ្រាដំបូង ៥ នាក់ ........................................ ៦៦

-រយៈពេលនៃការបំពេញបារមីរបស់ព្រះពុទ្ធ ៣ ព្រះអង្គ .................. ៦៨
-បុញ្ញនិធិ........................................................................... ៧០
-តួនាទីនីមួយៗក្នុងព្រះពុទ្ធសាសនា............................................. ៧២
-សិក្ខាបទទាំង ៥ និងអង្គមានដូចតទៅ ......................................... ៧៨
-សុជីវធម៌ ........................................................................... ៨២
-ស្ត្រី ៤ ពួក ......................................................................... ៨៤
-ស្ត្រីចូលទៅកាន់ត្រកូលស្វាមីមាន ៥ យ៉ាង ................................... ៨៦
-នារីគ្រប់លក្ខណ៍.................................................................... ៨៨
-មង្គលជីវិត .......................................................................... ៩០
-ឃរាវាសធម៌......................................................................... ៩៥
-ឋានសួគ៌ ៦ ជាន់................................................................... ១០០
-មាឃបូជា ........................................................................... ១០៣
-ពិធីបុណ្យមាឃបូជា................................................................ ១០៥
-នរក ៤ រូប .......................................................................... ១០៩
-មហាសុបិនជាតក .................................................................. ១១៣
-កំណាព្យផ្សេងៗ..................................................................... ១២៨

# មាតាបិតាមានឈ្មោះ ៤ យ៉ាង

កូនៗទាំងឡាយ ចូរកូនពិចារណានូវឈ្មោះរបស់មាតាបិតា ដែលមានចំពោះកូនគ្រប់គ្នាទុកជាការចងចាំ ដែលពួកគាត់មានសេចក្ដីល្អសម្រាប់ខ្លួនកូន ហើយសូមកូនរក្សានូវសេចក្ដីល្អរបស់ពុកម៉ែផង។

**១.មាតាបិតា** មានឈ្មោះថាព្រហ្ម ព្រោះជាអ្នកមានចិត្តសន្ដោសចំពោះរូបកូនរបស់ខ្លួន គឺលោកមានមេត្ដាការរាប់អាន ការស្រឡាញ់ចំពោះរូបកូន តាំងតែពីបានដឹងថា មានសត្វមកចាប់បដិសន្ធិក្នុងផ្ទៃ។ អ្នកម្ដាយបានតមអាហារ តមការងារខ្លះៗព្រោះខ្លាចប៉ះពាល់ដល់គភ៌ ដែលនៅក្នុងផ្ទៃ។ មាតាមានការទ្រាំពពោះមានការលំបាកជាទីបំផុត តែរូបគាត់ទ្រាំអត់ធ្មត់រហូតដល់គ្រប់ខែ ពេលប្រសូតហើយ មាតាតែងមានករុណាដ៏ក្រៃលែងទៅរកបុត្រ ទោះបីខ្លួនអស់កម្លាំងយ៉ាងណាក៏ដោយ ក៏នៅតែរីករាយ ព្រោះបានដឹងថា កូនខ្លួនបានឆ្លងផុតពីគ្រោះកាច ពោលគឺ សេចក្ដីអន្ដរាយហើយ។ លោកទាំងពីររួមគ្នាធ្វើកិច្ចការនានា មិនថាធ្ងន់ស្រាល ក្ដៅត្រជាក់នោះទេ គឺពួកគាត់ខំប្រឹងដោយវីរិយភាពដើម្បីរូបកូន។ ពេលដែលកូនធំពេញវ័យ មាតាបិតាមានចិត្តមុទិតា ទោរទន់រីករាយទៅរកកូនស្ងួន ដោយគិតថា កូនយើងសមរម្យ ល្មមនឹងរៀបចំទុកដាក់ ឱ្យមានគូគ្រងហើយ។ មិនតែប៉ុណ្ណោះលោកបានបែងចែកទ្រព្យ ទៅតាមលទ្ធភាពដែលគាត់មាន ហើយ

លោកមានចិត្ត ឧបេក្ខា ជាកណ្ដាលចំពោះកូនរបស់គាត់ ព្រោះកូនមានទីពឹង និងមានគ្នាសម្រាប់រំលែកទុក្ខធុរៈគ្នាទៅវិញទៅមកហើយ។

**២.មាតាបិតា** មានឈ្មោះថាគ្រូដើម គឺលោកជាគ្រូដំបូងបង្អស់ក្នុងការបង្រៀនកូនប្រុសស្រី គឺលោកបង្រៀនរាល់ៗថ្ងៃទាំងការនិយាយស្ដី និងការប្រព្រឹត្ត។ លោកទាំងពីរជាគ្រូមានចិត្តល្អបំផុតក្នុងលោក ដែលបានបង្រៀនកូន ដោយមិនគិតប្រាក់ខែ មិនគិតពីពេលវេលា និងការនឿយហត់ រាល់សកម្មភាពរបស់ឪពុកម្ដាយដែលបានសម្ដែងចេញ គឺជាមេរៀនបង្រៀនកូនរាល់ថ្ងៃ ដែលមេរៀននោះបានដក់ជាប់ក្នុងផ្នត់គំនិតរបស់កូន សម្រាប់យកទៅអនុវត្តក្នុងសង្គម។ បើកូននិយាយពីរោះ ទៀងត្រង់មានឥរិយាបថល្អ សុភាពរាបសានោះ ពួកគាត់ទាំងពីរមានចិត្តត្រេកអរណាស់ ហើយក៏ជាតួនាទីសំខាន់នៃពួកគាត់ក្នុងសង្គមគ្រួសារ។

**៣. មាតាបិតា** មានឈ្មោះថាទេវតាដើម គឺមាតាបិតាលោកតែងស្វែងរកប្រយោជន៍ឱ្យកូន ហើយមិនដែលប្រកាន់ទោសកូនខ្លួនឡើយ ទោះបីកូនធ្វើខុសឆ្គាំឆ្គង ដែលមហាជនតែងខឹងស្អប់យ៉ាងណា ក៏លោកនៅតែស្រលាញ់ និងតាមការពារកូនរបស់ខ្លួនជានិច្ច។

**៤. មាតាបិតា** ឈ្មោះថាព្រះដើម ដោយសារទង្វើដ៏ល្អឥតហ្មង ដែលបានបង្ហូរមករកកូន តាំងពីនៅក្នុងផ្ទៃរហូតមកហ្នឹងឯង ទើបលោកមាន

ឈ្មោះថា ជាព្រះដ៏បរិសុទ្ធរបស់កូនប្រុសស្រី ជាព្រះដែលគួរដល់ការបូជាចំពោះកូនប្រុសស្រី ។

ចំពោះកូនប្រុសស្រី ដែលបានបូជានូវទានរបស់ខ្លួនជូនទៅពួកគាត់រមែងបានផលច្រើន និងមិនចាំបាច់ទៅរកព្រះនៅទីណាមកបូជានោះទេ គឺព្រះនៅក្នុងផ្ទះរបស់យើងទាំងអស់គ្នាហ្នឹងហើយ។ មួយទៀតយើងមិនអាចសងគុណរបស់ពួកគាត់អស់ឡើយ ប៉ុន្តែយើងអាចធ្វើសេចក្តីល្អចំពោះគាត់បានគ្រប់ពេលវេលា គ្រប់ទីកន្លែង មិនថាពេលណានោះទេ ទោះយប់ទោះថ្ងៃ កូនប្រុសស្រីអាចធ្វើសេចក្តីល្អចំពោះគាត់បានច្រើនដើម្បីសម្រេចផលរបស់ខ្លួនឱ្យរឹតតែចម្រើនទៀតផងដែរ។

# ឧបមាព្រះរតនត្រ័យ ២២ យ៉ាង

១-ព្រះពុទ្ធប្រៀបដូចជាព្រះចន្ទពេញបូណ៌មី ព្រះធម៌ប្រៀបដូចជារស្មីនៃព្រះចន្ទ ព្រះសង្ឃប្រៀបដូចជាលោកដែលស្រស់បស់ដោយរស្មីនៃព្រះចន្ទពេញបូណ៌មីនោះ។

២-ព្រះពុទ្ធប្រៀបដូចជាដួងអាទិត្យ ព្រះធម៌ប្រៀបដូចជារស្មីនៃព្រះអាទិត្យ ព្រះសង្ឃប្រៀបដូចជាលោក ដែលដួងអាទិត្យកម្ចាត់ភាពងងឹតហើយ។

៣-ព្រះពុទ្ធប្រៀបដូចជាអ្នកដុតព្រៃ ព្រះធម៌ដុតព្រៃ គឺកិលេសប្រៀបដូចជាភ្លើងដុតព្រៃ ព្រះសង្ឃដែលជាបុញ្ញក្ខេត្ត ព្រោះដុតកិលេសបានហើយប្រៀបដូចជាភូមិភាគដែលជាស្រែព្រោះដុតព្រៃអស់ហើយ។

៤-ព្រះពុទ្ធប្រៀបដូចជាមហាមេឃដែលឱ្យនូវភ្លៀង ព្រះធម៌ប្រៀបដូចជាទឹកភ្លៀង ព្រះសង្ឃអ្នករម្ងាប់នូវលំអងកិលេសប្រៀបដូចជាជនបទដែលរម្ងាប់នូវលំអងធូលី ព្រោះភ្លៀងធ្លាក់។

៥-ព្រះពុទ្ធប្រៀបដូចជាសារថីដ៏ប្រសើរ ព្រះធម៌ប្រៀបដូចជាឧបាយសម្រាប់បង្ហឹកសេះអាជានេយ្យ ព្រះសង្ឃប្រៀបដូចជាហ្វូងសេះអាជានេយ្យដែលហ្វឹកហាត់ល្អហើយ។

៦-ព្រះពុទ្ធប្រៀបដូចជាអ្នកដកព្រួញ ព្រោះទ្រង់ដកសរ គឺទិដ្ឋិបានអស់ ព្រះធម៌ប្រៀបដូចជាឧបាយដកសរចេញបាន ព្រះសង្ឃអ្នកដែលត្រូវដកសរគឺទិដ្ឋិចេញបានហើយ ប្រៀបដូចជាជនដែលត្រូវដកសរចេញបាន។

៧-ព្រះពុទ្ធប្រៀបដូចជាពេទ្យភ្នែក ព្រោះទ្រង់បកស្រទាប់មោហៈចេញបានហើយ ព្រះធម៌ប្រៀបដូចជាឧបាយជាគ្រឿងបកភ្នែក ព្រះសង្ឃមានស្រទាប់ភ្នែកបកហើយ មានភ្នែក គឺញាណដ៏ភ្លឺថ្លាប្រៀបដូចជាជនដែលបកភ្នែកហើយមានភ្នែកភ្លឺ ។

៨-ព្រះពុទ្ធប្រៀបដូចជាពេទ្យដ៏ពូកែ ព្រោះទ្រង់អាចកម្ចាត់នូវព្យាធិ គឺកិលេស ព្រមទាំងអនុស័យចេញបាន ព្រះធម៌ប្រៀបដូចជាថ្នាំដែលផ្សំត្រឹមត្រូវហើយ ព្រះសង្ឃដែលមានព្យាធិ គឺកិលេស និងអនុស័យរម្ងាប់ហើយ ប្រៀបដូចជាពពួកជនដែលមានព្យាធិរម្ងាប់ហើយ ព្រោះកបនឹងថ្នាំ ។

៩-ព្រះពុទ្ធប្រៀបដូចជាអ្នកចង្អុលផ្លូវ ព្រះធម៌ប្រៀបដូចជាផ្លូវល្អ គឺផ្លូវដែលសម្រាប់រួចផុតពីភ័យ ព្រះសង្ឃប្រៀបដូចជាអ្នកដើរផ្លូវដល់ទីដែលផុតភ័យ។

១០-ព្រះពុទ្ធប្រៀបដូចជាអ្នកអុំទូកដ៏ចំណាន ព្រះធម៌ប្រៀបដូចជាទូក ព្រះសង្ឃប្រៀបដូចជាអ្នកដើរផ្លូវបានដល់ត្រើយ។

១១-ព្រះពុទ្ធប្រៀបដូចជាព្រៃហិមពាន្ត (ព្រៃដែលមានទឹកសន្សើម) ព្រះធម៌ប្រៀបដូចជាឱសថដែលកើតនៅក្នុងព្រៃហិមពាន្តនោះ ព្រះសង្ឃប្រៀបដូចជាជនអ្នកមិនមានរោគព្រោះប្រើថ្នាំ ។

១២-ព្រះពុទ្ធប្រៀបដូចជាអ្នកប្រទានទ្រព្យ ព្រះធម៌ប្រៀបដូចជាទ្រព្យ ព្រះសង្ឃអ្នកបានអរិយទ្រព្យមកដោយប្រពៃ ប្រៀបដូចជាជនអ្នកបានទ្រព្យតាមបំណង ។

១៣-ព្រះពុទ្ធប្រៀបដូចជាអ្នកចង្អុលកំណប់ទ្រព្យ ព្រះធម៌ប្រៀបដូចជាកំណប់ទ្រព្យ ព្រះសង្ឃប្រៀបដូចជាជន អ្នកបានកំណប់ទ្រព្យ ។

១៤-ព្រះសម្មាសម្ពុទ្ធជាវីរបុរស ប្រៀបដូចជាអ្នកប្រទាននូវការមិនមានភ័យ ព្រះធម៌ប្រៀបដូចជាការមិនភ័យ ព្រះសង្ឃដែលរួចពីភ័យគ្រប់យ៉ាង ប្រៀបដូចជាជនអ្នកដល់នូវការមិនមានភ័យ ។

១៥-ព្រះពុទ្ធប្រៀបដូចជាអ្នកលួងលោម ព្រះធម៌ប្រៀបដូចជាការលួងលោម ព្រះសង្ឃប្រៀបដូចជាជនអ្នកត្រូវលួងលោម ។

១៦-ព្រះពុទ្ធប្រៀបដូចជាមិត្តល្អ ព្រះធម៌ប្រៀបដូចជាពាក្យដាស់តឿនដែលជាពាក្យមានប្រយោជន៍ ព្រះសង្ឃប្រៀបដូចជាជនអ្នកជួបប្រសព្វនូវ ប្រយោជន៍ ព្រោះធ្វើតាមពាក្យរបស់មិត្តល្អ។

១៧-ព្រះពុទ្ធប្រៀបដូចជាអណ្តូងនាំឱ្យកើតទ្រព្យព្រះធម៌ប្រៀបដូចជាទ្រព្យដែលមានសារៈ ព្រះសង្ឃ ប្រៀបដូចជាជនអ្នកប្រើទ្រព្យដែលជាសារៈ

១៨-ព្រះពុទ្ធប្រៀបដូចជា អ្នកស្រោចទឹកងូតឱ្យព្រះរាជកុមារ ព្រះធម៌ប្រៀបដូចជាទឹក ស្រោចស្រពលើព្រះរាជកុមារតាំងពីព្រះសីសៈចុះមក ព្រះសង្ឃអ្នកបានទទួលនូវការស្រោចស្រពទឹកល្អហើយ ដោយទឹកគឺព្រះសទ្ធម្ម ប្រៀបដូចជាក្រុមព្រះរាជកុមារដែលបានស្រង់ទឹកល្អហើយ ។

១៩-ព្រះពុទ្ធប្រៀបដូចជាជាងធ្វើគ្រឿងប្រដាប់ ព្រះធម៌ប្រៀបដូចជាគ្រឿងប្រដាប់ (អលង្ការ) ព្រះសង្ឃជាអ្នកប្រដាប់ដោយព្រះសទ្ធម្ម ប្រៀបដូចជាព្រះរាជឱរសទាំងឡាយដែលទ្រង់ប្រដាប់ហើយ ។

២០-ព្រះពុទ្ធប្រៀបដូចជាដើមចន្ទន៍ ព្រះធម៌ប្រៀបដូចជាក្លិនដែលកើតអំពីខ្លឹមចន្ទន៍នោះ ព្រះសង្ឃបានរម្ងាប់នូវសេចក្តីក្តៅក្រហាយចិត្តដោយព្រះសទ្ធម្ម ប្រៀបដូចជាជនអ្នករម្ងាប់នូវភាពក្តៅផ្លូវកាយ ព្រោះប្រើលំអិតខ្លឹមចន្ទន៍នោះឯង ។

២១-ព្រះពុទ្ធប្រៀបដូចជាបិតា អ្នកចែកទ្រព្យមរតកប្រកបដោយធម៌ ព្រះធម៌ប្រៀបដូចជាទ្រព្យមរតក ព្រះសង្ឃអ្នកទទួលនូវទ្រព្យមរតកគឺព្រះសទ្ធម្ម ប្រៀបដូចជាបុត្រទាំងឡាយដែលជាអ្នកទទួលនូវទ្រព្យមរតក ។

២២-ព្រះពុទ្ធប្រៀបដូចជាផ្កាឈូកដែលរីក ព្រះធម៌ប្រៀបដូចជាពួកភមរជាតិ (មានសត្វឃ្មុំជាដើម) ដែលក្រេបយកលំអងកេសរ ក្នុងផ្កាឈូក ។ គប្បីប្រកាសព្រះរតនត្រ័យនោះ ដោយសេចក្តីឧបមាទាំងឡាយដូចពោលមកនេះឯង ។

# មហាបុរិសលក្ខណៈ

លក្ខណៈរបស់មហាបុរស គឺបុរសអស្ចារ្យក្នុងលោក មានលក្ខណៈ ៣២ប្រការ មានទំនាយថា បើនៅជាគ្រហស្ថនឹងបានជាស្តេចចក្រពត្តិ បើចេញបួសនឹងបានត្រាស់ជាព្រះសម្មាសម្ពុទ្ធពិតប្រាកដ មហាបុរិសលក្ខណៈ ៣២ប្រការ នោះមាននិយាយក្នុងលក្ខណសូត្រ នៅក្នុងគម្ពីរសុត្តន្តបិដក ទីឃនិកាយបឋមភាគ ព្រះត្រៃបិដកលេខ ១៩ និងព្រហ្មាយុសូត្រ នៅក្នុងគម្ពីរសុត្តន្តបិដក មជ្ឈិមនិកាយ ព្រះត្រៃបិដកលេខ ២៥ ចាប់ពីទំព័រទី ២ ដល់ ៣៤។

១-**សុបតិដ្ឋិតបាទោ** មានផ្ទៃព្រះបាទទាំងគូរាបស្មើគ្នា។

២-**ហេដ្ឋាបាទតលេសុ ចក្កានិ ជាតានិ** ត្រង់ផ្ទៃព្រះបាទខាងក្រោមទាំងគូមានរូបកងចក្រប្រកបដោយកណ្តាប់និងដុំ ព្រមទាំងកាំមួយពាន់ មានចន្លោះស្មើគ្នាគ្រប់អន្លើ។

៣-**អាយតបណ្ហិ** មានព្រះបណ្ហិ គឺកែងព្រះបាទវែង (បើចែកសរីរប្បទេសត្រង់នោះជា ៤ ភាគ,២ ភាគជាចុងព្រះបាទ, ១ ភាគជាព្រះបាទ, ១ ភាគទៀត ជាព្រះបណ្ហិ)។

៤-**ទីឃង្គុលិ** មានព្រះអង្គុលី គឺម្រាមព្រះហស្ត ម្រាមព្រះបាទវែងៗ ចំណែកម្រាមព្រះហស្តទាំង ៤ វែងស្មើគ្នា ម្រាមព្រះបាទទាំង ៥ វែងស្មើគ្នា

ម្រាមទាំងអស់មូលត្រសូលរៀវល្អ ផូរផង់ដូចមនោសិលា ដែលគេលាយប្រេងល្វ។

៥-**មុទុតលនហត្ថបាទោ** មានផ្ទៃព្រះហស្ត និងផ្ទៃព្រះបាទទន់ល្មើយ (ដូចដុំសំឡីដែលគេថ្លេច ១០០ ដងហើយ)។

៦-**ជាលហត្ថបាទោ** មានព្រះហស្ត និងផ្ទៃព្រះបាទាប្រទាក់ដោយក្រឡាដូចជាក្រឡាសំណាញ់។

៧-**ឧស្សង្ខបាទោ** មានបាទដូចជាអណ្តែតឡើងទៅខាងលើ ហាក់ដូចជាមិនជាប់គ្នានឹងខ្នងព្រះបាទ។

៨-**ឯណជង្ឃោ** មានព្រះជង្ឃា គឺស្មងវែងមូលត្រសូល ស្រដៀងនឹងស្មងសត្វទ្រាយ (ពុំនោះសោតស្រដៀងនឹងដង្ហើមស្រូវ)។

៩-**ឋិតកោ ច អនោនមន្តោ ឧភោហិ បាណិតលេហិ ជណ្ណុកានិ បរាមសតិ** កាលបើទ្រង់ឈរមិនឱនព្រះអង្គចុះ អាចស្ទាបព្រះជានុ គឺជង្គង់ដោយព្រះហស្តទាំងពីរបាន។

១០-**កោសោហិតវត្ថគុយ្ហោ** មានព្រះអង្គាវយវៈដែលគប្បីលាក់កំបាំងដោយស្ថិតនៅក្នុងស្រោម (ប្រហែលដូចជាអង្គជាតនៃសត្វដំរីជាដើម)។

១១-**សុវណ្ណ វណ្ណោ** មានព្រះឆវីវណ្ណ គឺពណ៌សម្បុរថ្ងៃ (លឿងភ្លឺអន្លង់) ដូចជាសម្បុរនៃមាស។

១២-**សុខុមច្ឆវី** មានព្រះឆវី គឺពណ៌សម្បុរថ្ងៃស្រទន់ល្អិតផូរផង់រលីងស្រិលរអិលធូលីធ្លាក់ប៉ះមិនជាប់។

១៣-**ឯកេកលោមោ** មានព្រះលោមា គឺរោមក្នុងរណ្ដៅមួយៗមានតែមួយសរសៃៗគ្រប់រណ្ដៅទាំងអស់។

១៤-**ឧទ្ធគ្គលោមោ** មានព្រះលោមា ចុងងឡើងលើជាទក្ខិណាវដ្ដព័ន្ធពេនទៅខាងស្ដាំ មានសម្បុរខៀវស្រស់ដូចជាផ្កាអញ្ចន កួចមូលដូចជាកុណ្ឌល។

១៥-**ព្រហ្មុជុគត្តោ** មានកាយត្រង់ដូចជាកាយនៃព្រហ្ម។

១៦-**សត្តុស្សទោ** មានព្រះមំសៈ គឺសាច់ ៧ អន្លើដោយបរិបូណ៌ (ព្រះមំសៈ៧ អន្លើនោះ គឺត្រង់ខ្នងព្រះហស្ដទាំងពីរ, ខ្នងព្រះបាទទាំងពីរ, ព្រះអំសកូដ គឺចង្កួយស្មាទាំងពីរ និងត្រង់ព្រះខន្ធប្បទេស គឺត្រង់ក, សរីរប្បទេសទាំង ៧ អន្លើនេះមានសាច់ល្អឥតមានឃើញសរសៃឡើយ។

១៧-**សីហបុព្វឌ្ឍកាយោ** មានចំណែកខ្លះព្រះកាយខាងដើមស្រដៀងនឹងចំណែកកន្លះកាយនៃរាជសីហ៍ (ត្រង់កន្លែងដែលគួរវែងគួរខ្លីគួរធាត់គួរស្គម ឬក៏គួររៀវ គួរមូល ក៏វែង ខ្លី ធាត់ ស្គម ឬរៀវមូលសមឥតមានឆ្គង)។

១៨-**ចិដ្ឋន្តរំសោ** មានព្រះបិដ្ឋិ គឺខ្នងពេញបរិបូណ៌ គឺថាសាច់នៃចន្លោះស្លាបប្រចៀវទាំងពីររាបស្មើឥតមានចង្អូរផតខូងត្រង់កណ្ដាលឡើយ។

១៩-**និគ្រោធបរិមណ្ឌលោ** មានទ្រង់ទ្រាយព្រះកាយប្រហែល នឹងបរិវេណមណ្ឌល នៃដើមជ្រៃ គឺមានព្រះកាយ និងព្យាមប្រវែងគ្នា (ដូចជាជ្រៃមានប្រវែងដើម និងមែកមិនលើស មិនខ្វះហួសគ្នាប៉ុន្មានទេ)។

២០-**សមវដ្តក្ខន្ធោ** មានព្រះខន្ធប្បទេស គឺមូលសម។

២១-**រសគ្គសគ្គី** មានព្រះប្រសាទ គឺសរសៃល្អិតឆ្មារក្រៃលែងសម្រាប់ទទួលនាំរសអាហារឱ្យជ្រាបផ្សព្វផ្សាយក្នុងកាយទាំងមូលបានឥតមានទើសទាក់ សូម្បីអាហារយ៉ាងតូចតិចប៉ុននឹងគ្រាប់ល្ង ១ ក៏អាចជ្រួតជ្រាបសព្វសព៌ាង្គកាយបាន។

២២-**សីហហនុ** មានព្រះហនុ គឺចង្កាសណ្ឋានស្រដៀងនឹងចង្ការាជសីហ៍ (ពេញបរិបូណ៌ ប្រហែលដូចជាព្រះចន្ទត្រង់ថ្ងៃ ១២ កើត)។

២៣-**ចត្តាឡីសទន្តោ** មានព្រះទន្ត ៤០ គត់គឺខាងលើ ២០ ខាងក្រោម ២០។

២៤- **សមទន្តោ** មានព្រះទន្តរាបស្មើ (មិនច្រពើសខ្ពស់ទាបដូចជាធ្មេញ នៃមនុស្សសាមញ្ញពួកខ្លះនោះឡើយ) ។

២៥-**អវិរឡទន្តោ** មានព្រះទន្តជិតស្និទ្ធល្អ។

២៦-**សុសុក្កទាឋោ** មានព្រះទាឋា គឺចង្កូម (ទាំង៤) សស្អាតភ្លឺងរុងរឿង ដូចជាពន្លឺនៃផ្កាយព្រឹក)។

២៧-**បហុតជិវ្ហោ** មានព្រះជិវ្ហា គឺអណ្ដាតល្មមល្មៃ (ប្លែកជាងអណ្ដាតនៃមនុស្សទាំងអស់ក្នុងលោក បើទ្រង់លៀនអណ្ដាតចេញមកក្រៅអាចយកអណ្ដាតគ្របបាំងថ្ងាសបាន) ។

២៨-**ព្រហ្មស្សរោ ករវិកភាណី** មានព្រះសូរសៀង គឺសូរស័ព្ទសំឡេងក្រាងក្រឌីដូចជាសំឡេងនៃព្រហ្ម, កាលបើបញ្ចេញវាចាលាន់ឮពីរោះដូចជាសំឡេងនៃសត្វករវិក។

២៩-**អភិនីលនេត្តោ** មានព្រះនេត្រខៀវស្រស់ (ត្រង់កន្លែងដែលត្រូវខៀវ ក៏ខៀវស្រស់ដូចជាផ្កាត្រកៀត ឬផ្កាកណ្ដៀង, ត្រង់កន្លែងដែលគួរលឿង ក៏លឿងដូចជាផ្កាកណិកា, ត្រង់កន្លែងដែលគួរក្រហម ក៏ក្រហមដូចជាផ្កាចារ, ហើយត្រង់កន្លែងដែលគួរ ស ក៏សថ្លាត្រចះត្រចង់ដូចផ្កាយព្រឹក, ត្រង់កន្លែងដែលគួរខ្មៅ ក៏ខ្មៅស្រស់ដូចផ្លែផ្ដាំ)។

៣០-**គោបខុមា** មានដួងព្រះនេត្រ ស្រដៀងនឹងដួងភ្នែកនៃគោ គឺមានដូចនេត្រាទាំងពីរថ្លាយង់ សម្បុររាងក្រហមស្រដៀងនឹងដួងភ្នែកនៃកូនគោដែលទើបនឹងសម្រាលមួយរំពេចនោះ។

៣១-**ឧណ្ណា ភមុកន្តរេ ជាតា** មានព្រះឧណ្ណាលោម គឺរោមដុះត្រង់ចន្លោះព្រះភមូ (ចិញ្ចើម) មានសម្បុរ ស ទន់ល្វន់ដូចជាសំឡី។

៣២-**ឧណ្ហិសសីលោ** មានព្រះសិរហាក់បីដូចជាប្រដាប់ដោយក្បាំងស្រេចស្រាប់រុងរឿងដូចជា ព្រះមហាក្សត្រិយ៍ដែលទ្រង់នូវក្បាំងព្រះ ភក្ត្រ។

ន័យមួយទៀតថាមូលបរិបូណ៌ល្អដូចជាមកុដ  ឬមូលហាក់ដូចជាវត្ថុដែលគេក្រឡឹងហើយយកមកតម្កល់  ពុំនោះសោតមូលហាក់ដូចជាពពុះទឹកដែលប៉ោងឡើង។

# សេចក្តីល្អរបស់ព្រះដ៏មានព្រះភាគសម្រាប់ជនច្រើនរូប

នៅពេលចេញវស្សាទី ១ របស់ព្រះដ៏មានព្រះភាគក្នុងកាលនោះឯង ព្រះអង្គទ្រង់ត្រាស់ទៅកាន់ព្រះអរហន្ត ៦០ អង្គ ដែលមានសេចក្តីថា ម្នាលភិក្ខុទាំងឡាយ តថាគតរួចហើយអំពីអន្ទាក់ទាំងអស់ ទោះជារបស់ទេវតាក្តី ទោះបីរបស់មនុស្សក្តី ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រាច់ទៅកាន់ចារិក (គឺស្រុក និងនិគម រាជធានី ហើយសម្តែងធម៌) ជាប្រយោជន៍ និងសេចក្តីសុខដល់ជនជាច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីជាប្រយោជន៍ ដើម្បីជាគុណ ដើម្បីសេចក្តីសុខដល់ពួកទេវតា និងមនុស្សទាំងឡាយដែលសេចក្តីទុក្ខកំពុងតែគ្របសង្កត់យ៉ាងខ្លាំង អ្នកទាំងឡាយកុំទៅពីរនាក់តាមផ្លូវតែមួយឡើយ អ្នកទាំងឡាយចូរសម្តែងធម៌ ឱ្យពីរោះបទដើម បទកណ្តាល និងបទចុង អ្នកទាំងឡាយចូរប្រកាសនូវព្រហ្មចរិយធម៌ដ៏បរិសុទ្ធប្រកបដោយអត្ថ និងព្យញ្ជនៈដ៏ពេញបរិបូណ៌ទាំងអស់ សត្វលោកទាំងឡាយដែលមានធូលី គឺរាគាទិក្កិលេសតិចក្នុងភ្នែកក៏មាន សត្វទាំងនោះនឹងសាបសូន្យ (ចាកមគ្គផល) ព្រោះមិនបានស្តាប់ធម៌ សត្វលោកទាំងឡាយអ្នកបម្រុងត្រាស់ដឹងនូវធម៌គង់នឹងមាន ម្នាលភិក្ខុទាំងឡាយចំណែក តថាគតក៏នឹងចូលទៅកាន់សេនានិគម ក្នុងឧរុវេលាប្រទេស ដើម្បីសម្តែងធម៌ដែរ ។

ម្នាលភិក្ខុទាំងឡាយ កាលព្រះសុគតក្តី វិន័យព្រះសុគតក្តីប្រតិស្ឋាននៅក្នុងលោក ការណ៍នោះប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ដល់ជនច្រើនដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់ពួកទេវតា និងមនុស្សជាច្រើនក្នុងលោក។ ម្នាលភិក្ខុទាំងឡាយចុះព្រះសុគតដូចម្តេច? ម្នាលភិក្ខុទាំងឡាយ ព្រះតថាគតកើតឡើងក្នុងលោកនេះជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គបរិបូណ៌ដោយវិជ្ជា និងចរណៈ ព្រះអង្គមានដំណើរល្អ ទ្រង់ជ្រាបច្បាស់នូវត្រៃលោក ព្រះអង្គប្រសើរដោយសីលាទិគុណរកបុគ្គលណាមួយស្មើគ្មានព្រះអង្គជាអ្នកទូន្មាននូវបុរសដែលគួរទូន្មានបាន ព្រះអង្គជាសាស្តានៃទេវតា និងមនុស្សទាំងឡាយ ព្រះអង្គទ្រង់ត្រាស់ដឹងនូវចតុរារិយសច្ច ព្រះអង្គលែងវិលមកកាន់ភពថ្មីទៀត អ្នកទាំងឡាយនេះជាព្រះសុគត ។

បានឮមកថា ព្រះចុល្លបន្ថកៈនោះ បួសក្នុងកាលនៃព្រះកស្សបៈសម្មាសម្ពុទ្ធជាម្ចាស់ ជាអ្នកមានបញ្ញា បានធ្វើការសើចចំអកក្នុងវេលាដែលភិក្ខុមួយរូបរៀនឧទ្ទេស ភិក្ខុអង្គនោះឯងអៀន ព្រោះការសើចចំអកនោះទើបមិនរៀនឧទ្ទេសមិនធ្វើការស្វាធ្យាយ។ ព្រោះកម្មនោះទើបព្រះចុល្លបន្ថកៈនេះបួសប៉ុណ្ណោះ កើតជាមនុស្សល្ងង់កាលលោករៀនរឿយៗទៅបទដែលរៀនហើយក៏ភ្លេចអស់ទៅ សូម្បីតែចុល្លបន្ថកៈព្យាយាមរៀនគាថានោះអស់ ៤ ខែក៏នៅតែមិនចាំ លំដាប់នោះ ទើបព្រះមហាបន្ថកៈ អូសចុល្លបន្ថកៈ នោះចៀសចេញពីវិហារ ដោយពោលថា ចុល្លបន្ថកៈ លោកជា

អ្នកអភ័ព្វក្នុងសាសនានេះ ដោយ ៤ ខែ មិនអាចរៀនគាថានេះបាន លោកនឹងធ្វើកិច្ចនៃបព្វជិតឱ្យដល់ទីបំផុតបានដូចម្តេច ចូរចៀសចេញពីវិហារទៅ ព្រោះចុល្លបន្ថកៈមិនប្រាថ្នាជាគ្រហស្ថ ព្រោះសេចក្តីស្រឡាញ់ព្រះពុទ្ធសាសនា ។

ក្នុងគ្រានោះ ព្រះមហាបន្ថកៈបានជាភត្តុទ្ទេសក៍ (អ្នកចែកភត្ត) ។ ពេទ្យជីវកកោមារភត្យកាន់គឿងក្រអូប និងផ្កាឈើជាច្រើន ទៅកាន់អម្ពវ័នរបស់ខ្លួន បូជាព្រះសាស្តា ស្តាប់ធម៌ហើយក្រោកចាកអំពីអាសនៈថ្វាយបង្គំព្រះទសពល ហើយចូលទៅរកព្រះមហាបន្ថកៈសួរថា លោកម្ចាស់ដ៏ចម្រើន ក្នុងសម្នាក់ព្រះសាស្តាមានភិក្ខុប៉ុន្មានអង្គ ? ព្រះមហាបន្ថកៈពោលថា មានព្រះភិក្ខុប្រមាណ ៥០០ អង្គ ។

ពេទ្យជីវកពោលថា លោកម្ចាស់ដ៏ចម្រើន ថ្ងៃស្អែកសូមលោកម្ចាស់នាំភិក្ខុ ៥០០ អង្គ មានព្រះពុទ្ធជាប្រធាន ទៅទទួលភិក្ខាក្នុងសម្នាក់របស់ខ្ញុំករុណាផង។ ព្រះថេរៈពោលថា ឧបាសក ឈ្មោះចុល្លបន្ថកៈជាអ្នកល្ងង់ មានធម៌មិនលូតលាស់បរិសុទ្ធ អាត្មាភាពនឹងនិមន្តភិក្ខុដ៏សេសវៀរតែភិក្ខុចុល្លបន្ថកៈនោះ។ ព្រះចុល្លបន្ថកៈបានស្តាប់ដូច្នេះ ទើបគិតថា ព្រះថេរៈបងប្រុសរបស់យើង កាលទទួលនិមន្តន៍ដើម្បីភិក្ខុទាំងឡាយ មានប្រមាណប៉ុណ្ណោះ ក៏ទទួលចំណែកយើងទុកផ្នែកខាងក្រៅ បងប្រុសរបស់យើងនឹងមិនពេញចិត្តដោយឥតសង្ស័យ ឥឡូវនេះ យើងមានប្រយោជន៍អ្វីដោយព្រះ

សាសនានេះ យើងនឹងទៅជាគ្រហស្ថ នឹងធ្វើបុណ្យ មានទានជាដើម ហើយចិញ្ចឹមជីវិត។ យប់ថ្ងៃស្អែកព្រះចុល្លបន្ថកៈនោះធ្វើដំណើរទៅពីព្រលឹម ដោយគិតថា នឹងជាគ្រហស្ថក្នុងវេលាទៀបភ្លឺ ។

ព្រះសាស្តាទ្រង់ប្រមើលមើលសត្វលោក បានឃើញហេតុនោះៗឯង ទើបស្តេចយាងទៅមុនស្រេច ហើយបានប្រថាប់ឈរនៅខ្លោងទ្វារផុតផ្លូវដែលចុល្លបន្ថកៈទៅ។ ព្រះចុល្លបន្ថកៈ កាលនឹងដើរទៅផ្ទះឃើញព្រះសាស្តា ទើបចូលទៅហើយថ្វាយបង្គំ ។

លំដាប់នោះ ព្រះសាស្តាទ្រង់ត្រាស់នឹងព្រះចុល្លបន្ថកៈនោះថា អ្នកទៅណាក្នុងវេលានេះ។ ព្រះចុល្លបន្ថកៈក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន បងប្រុសរបស់ខ្ញុំព្រះអង្គ បណ្តេញខ្ញុំ ហេតុនោះហើយ ខ្ញុំព្រះអង្គនឹងទៅជាគ្រសហ្ថ។ ព្រះសាស្តាទ្រង់ត្រាស់ថា ព្រះចុល្លបន្ថកៈ ឈ្មោះថាការបព្វជ្ជារបស់អ្នកក្នុងសម្នាក់របស់តថាគត ត្រូវបងប្រុសបណ្តេញទៅព្រោះហេតុអ្វី ទើបមិនមកនៅក្នុងសម្នាក់របស់តថាគតមកចុះ ប្រយោជន៍អ្វីអ្នកនឹងទៅជាគ្រហស្ថ។ អ្នកចូរទៅសម្នាក់របស់តថាគត ហើយទ្រង់នាំព្រះចុល្លបន្ថកៈទៅ ឱ្យព្រះចុល្លបន្ថកៈនោះអង្គុយខាងមុខព្រះគន្ធកុដិ ត្រាស់ថា ចុល្លបន្ថកៈ អ្នកចូរបែរមុខទៅទិសខាងកើត ចូរនៅក្នុងទីនេះចុះ ហើយអង្អែលសំពត់ចាស់ទៅថា **រជោ ហរណំ រជោ ហរណំ** សំពត់ជាគ្រឿងនាំធូលីទៅៗ ហើយទ្រង់ប្រទានសំពត់ចាស់បរិសុទ្ធ ដែលទ្រង់

តាក់តែងដោយរឹទ្ធិ។ កាលគេក្រាបទូលវេលាទទួលភត្តាហារឱ្យទ្រង់ជ្រាប ទើបហែហមដោយភិក្ខុសង្ឃ ស្តេចទៅកាន់និវេសន៍របស់ពេទ្យជីវក ប្រថាប់លើអាសនៈដែលគេក្រាលទុកហើយ ឯព្រះចុល្លបន្ថកៈសម្លឹងមើលទៅព្រះអាទិត្យ ហើយអង្គុយអង្អែល សំពត់ចាស់នោះថា **រជោហរណំ រជោហរណំ** កាលព្រះចុល្លបន្ថកៈ កំពុងតែស្ទាបអង្អែលសំពត់ចាស់នោះ ស្រាប់តែសំពត់នោះសៅហ្មងទៅ ពេលនោះទើបព្រះចុល្លបន្ថកៈគិតថា សំពត់ចាស់នោះបរិសុទ្ធក្រៃលែង តែព្រោះអាស្រ័យអត្តភាពនេះ ទើបសំពត់ដែលនៅជាប្រក្រតី ទៅជាសៅហ្មងយ៉ាងនេះ សង្ខារទាំងឡាយមិនទៀងហ្ន៎ ផ្តើមវិបស្សនាដោយការអស់ទៅ និងការវិនាសទៅ។ ព្រះសាស្តាទ្រង់ជ្រាបថា ចិត្តរបស់ចុល្លបន្ថកៈឡើងកាន់វិបស្សនា ទើបទ្រង់ត្រាស់ថា ចុល្លបន្ថកៈ អ្នកកុំធ្វើសេចក្តីសម្គាល់ថា សំពត់ ចាស់នោះប៉ុណ្ណោះជារបស់សៅហ្មងដោយផង់ធូលី តែធូលី គឺរាគៈជាដើម នោះមាននៅខាងក្នុង អ្នកចូរនាំធូលីគឺរាគៈជាដើមនោះចេញ ទ្រង់បញ្ចេញពន្លឺជាអ្នកមានព្រះរូបកាយឆោមប្រាកដ ដូចគង់ប្រថាប់នៅខាងមុខ បានត្រាស់ ព្រះគាថានេះថាៈ រាគៈ ហៅថា ធូលី តែលម្អងធូលីមិនហៅថាធូលីទេ ពាក្យថា ធូលីនេះ ជាឈ្មោះរបស់រាគៈ ភិក្ខុទាំងឡាយលះធូលីនោះបានហើយ រមែងនៅក្នុងសាសនារបស់ព្រះពុទ្ធ ជាអ្នកប្រាសចាកធូលី ទោសៈ ហៅថា ធូលី តែលម្អងមិនហៅថាធូលីទេ ពាក្យថាធូលី ជាឈ្មោះរបស់ទោសៈ ភិក្ខុទាំងឡាយលះធូលីនោះ

ហើយ រមែងនៅក្នុងសាសនារបស់ព្រះពុទ្ធ ជាអ្នកប្រាសចាកធូលី មោហៈ ហៅថា ធូលី តែលម្អងធូលី មិនហៅថា ធូលីទេ ពាក្យថា ធូលីនេះ ជាឈ្មោះរបស់មោហៈ ភិក្ខុទាំងឡាយ លះធូលីនោះបានហើយរមែងនៅក្នុងសាសនារបស់ព្រះពុទ្ធជាអ្នកប្រាសចាកធូលី ។

ក្នុងវេលាចប់ព្រះគាថា ព្រះចុល្លបន្ថកៈសម្រេចព្រះអរហត្តព្រមទាំងបដិសម្ភិទា បិដកទាំង ៣ មកប្រាកដដល់ព្រះចុល្លបន្ថកៈនោះព្រមដោយបដិសម្ភិទាទាំងឡាយ។

បានឮថា ក្នុងកាលមុនព្រះចុល្លបន្ថកៈនោះជាព្រះរាជា កំពុងធ្វើប្រទក្សិណព្រះនគរ កាលញើសបានហូរចេញពីព្រះនលាដ (ថ្ងាស) ទើបយកសំពត់សាដកដែលបរិសុទ្ធជូតព្រះនលាដ សំពត់សាដក ក៏បានសៅហ្មងទៅ ព្រះរាជានោះទ្រង់បានអនិច្ចសញ្ញា ដោយភាពមិនទៀងថា សំពត់សាដកដែលបរិសុទ្ធបែបនេះ លះប្រក្រតីដើម ទៅជាសៅហ្មងព្រោះអាស្រ័យរាងកាយនេះ សង្ខារទាំងឡាយមិនទៀងហ្ន៎ ដោយហេតុនោះ សំពត់ជាគ្រឿងនាំធូលីចេញទៅប៉ុណ្ណោះ ក៏កើតជាបច្ច័យដល់ព្រះចុល្លបន្ថកៈនោះ។

ចំណែកពេទ្យជីវកកោមារភត្យ នាំយកទឹកទក្ខិណោទកចូលទៅថ្វាយព្រះទសពលព្រះសាស្តា ទ្រង់យកព្រះហស្តបិទបាត្រ ដោយត្រាស់ថា ជីវក ក្នុងវិហារមិនមានភិក្ខុឬ? ព្រះមហាបន្ថកៈក្រាបទូលថា បពិត្រព្រះអង្គដ៏

ចម្រើន ក្នុងវិហារមានភិក្ខុឬព្រះអង្គ? ព្រះសាស្តាត្រាស់ថា ជីវកមានភិក្ខុ។ ទើបពេទ្យជីវកបញ្ជូនបុរសម្នាក់ទៅដោយពាក្យថា នាយ ប្រសិនបើយ៉ាងនោះ អ្នកចូរទៅ ម្យ៉ាងទៀត ចូរដឹងថា ក្នុងវិហារមានភិក្ខុ ឬមិនមានខណៈនោះ ព្រះចុល្លបន្ថកៈគិតថា បងប្រុសយើងនិយាយថា ក្នុងវិហារមិនមានភិក្ខុ យើងនឹងប្រកាស ភាពដែលភិក្ខុទាំងឡាយ មាននៅក្នុងវិហារ ដល់បងប្រុសរបស់យើងនោះ ហើយបណ្តាលឲ្យអម្ពវ័នទាំងអស់ ពេញទៅដោយភិក្ខុទាំងឡាយប៉ុណ្ណោះ ភិក្ខុមួយពួកធ្វើចីវរកម្ម ភិក្ខុមួយពួកធ្វើកម្ម គឺជ្រលក់ចីវរ ភិក្ខុមួយពួកធ្វើការស្វាធ្យាយ លោកនិម្មិតភិក្ខុ ១០០០ រូប ដែលដូចគ្នានឹងគ្នាយ៉ាងនេះ បុរសនោះឃើញភិក្ខុសន្ធឹកសន្ធាប់ក្នុងវិហារ ទើបត្រឡប់ទៅប្រាប់ពេទ្យជីវកថា បពិត្រអ្នកប្រុស ក្នុងអម្ពវ័នទាំងមូលពេញដោយភិក្ខុទាំងឡាយនោះឯង។

ព្រះថេរៈ ក៏និម្មិតអត្តភាពទាំងពាន់ (សុទ្ធតែ) ព្រះចុល្លបន្ថកៈ គង់នៅក្នុងអម្ពវ័នដ៏រុងរោចន៍ រហូតដល់ប្រកាសវេលា (ភត្ត) ឱ្យជ្រាបកាល។

លំដាប់នោះ ព្រះសាស្តាត្រាស់នឹងបុរសនោះថា អ្នកចូរទៅវិហារពោលថា ព្រះសាស្តាត្រាស់ហៅភិក្ខុឈ្មោះចុល្លបន្ថកៈ កាលបុរសនោះទៅពោលយ៉ាងនេះហើយ មាត់ទាំងមួយពាន់តាំងឡើង ថា អាត្មាឈ្មោះចុល្លបន្ថកៈៗ បុរសចូលទៅក្រាបទូលថាបពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុទាំងនោះឈ្មោះចុល្លបន្ថកៈទាំងអស់ ។ ព្រះសាស្តាត្រាស់ថា ប្រសិនបើយ៉ាង

នោះ អ្នកចូលទៅចាប់ដៃភិក្ខុដែលនិយាយថា អាត្មាឈ្មោះថាចុល្លបន្ថកៈ ភិក្ខុដ៏សេសនឹងអន្តរធានទៅបុរសនោះបានធ្វើតាមយ៉ាងនេះ ក្នុងពេលនោះឯង ភិក្ខុប្រមាណ ១០០០ បានអន្តរធានបាត់ទៅ ព្រះថេរៈបានទៅជាមួយបុរសនោះ ក្នុងវេលាដែលសម្រេចភត្តកិច្ច ព្រះសាស្តាត្រាស់ហៅពេទ្យជីវកមកថា ជីវក អ្នកចូរទទួលបាត្ររបស់ចុល្លបន្ថកៈ ព្រះចុល្លបន្ថកៈ នឹងធ្វើអនុមោទនាដល់អ្នក។ ពេទ្យជីវកបានធ្វើតាមយ៉ាងនោះ ព្រះថេរៈបន្លឺនូវសីហនាទ ដូចជារាជសីហ៍ដ៏មានកម្លាំង អាចធ្វើឱ្យបិដកទាំងបីកម្រើកញាប់ញ័រ ធ្វើអនុមោទនា ព្រះសាស្តាស្តេចក្រោកចាកអាសនៈ មានភិក្ខុសង្ឃជាបរិវារយាងទៅកាន់ព្រះវិហារ កាលភិក្ខុទាំងឡាយសម្តែងវត្តស្រេចហើយ ស្តេចក្រោកចាកអាសនៈ ទ្រង់ប្រថាប់ឈរពីមុខព្រះកម្មដ្ឋានទ្រង់ ឱ្យភិក្ខុទៅហើយ ទ្រង់ចូលទៅកាន់ព្រះគន្ធកុដិ ដែលអប់ដោយគ្រឿងក្រអូប ដ៏មានក្លិនក្រអូប ហើយទ្រង់ចូលសីហសេយ្យា ដោយទ្រង់ផ្អៀងទៅខាងស្តាំ។

គ្រាមួយ ក្នុងវេលាល្ងាច ភិក្ខុទាំងឡាយប្រជុំគ្នាគ្រប់ផ្នែក ក្នុងរោងធម្មសភា អង្គុយដូចជាវាំងននសំពត់កម្ពលក្រហម ប្រារព្ធរឿងព្រះគុណរបស់ព្រះសាស្តាថា អាវុសោទាំងឡាយ ព្រះមហាបន្ថកៈ មិនដឹងអធ្យាស្រ័យរបស់ព្រះចុល្លបន្ថកៈ មិនអាចឱ្យរៀនគាថាមួយ ក្នុងវេលា ៤ ខែ ទាញចេញពីវិហារ ដោយពោលថាព្រះចុល្លបន្ថកៈនេះល្ងង់ខ្លៅមិនឆ្លាត

តែព្រះសម្មាសម្ពុទ្ធជាម្ចាស់បានប្រទាន ព្រះអរហត្តព្រមដោយបដិសម្ភិទា ដល់ព្រះចុល្លបន្ថកៈនោះក្នុងចន្លោះសម្រេចភត្តកិច្ច ព្រោះព្រះអង្គជា ព្រះធម្មរាជាដ៏កំពូលបិដកទាំង ៣ មកព្រមដោយបដិសម្ភិទាន គួរអស្ចារ្យ ឈ្មោះថា ពុទ្ធបល្ល័ង្កធំមហាសាល។ លំដាប់នោះឯង ព្រះមានព្រះភាគទ្រង់ ជ្រាប សេចក្ដីនៃរឿងនេះ ក្នុងរោងធម្មសភា ទ្រង់ព្រះតម្រិះថា ថ្ងៃនេះ តថាគតគួរទៅទើបស្ដេចក្រោកចាកពុទ្ធសេយ្យា ទ្រង់ដណ្ដប់ចីវរពីរជាន់ ដែលមានពណ៌ក្រហមល្អ ទ្រង់ចងរឹតនូវវត្ថពន្ធដូចផ្លេកបន្ទោរ ទ្រង់ហ៊ុម មហាចីវរខ្នាតព្រះសុគតជាមួយនឹងសំពត់កម្ពលពណ៌ក្រហម ទ្រង់ចេញ ចាកពីព្រះគន្ធកុដិដ៏មានក្លិនក្រអូប យាងទៅកាន់រោងធម្មសភា ដោយ សភាពស្អាតស្អំ មានដំណើរដូចជាដំរីដ៏ប្រសើរ និងដូចជារាជសីហ៍ ដោយ ពុទ្ធលីលា ដែលមិនមានទីបំផុត ទើបស្ដេចចូលទៅកាន់ពុទ្ធាសនៈ ដែលគេ ក្រាលទុក ហើយបានបញ្ចេញឆព្វណ្ណរង្សីមានពណ៌ ៦ ប្រការ ដូចទ្រង់ញុំាង ផ្ទៃទន្លេឱ្យរញ្ជួយ និងដូចពន្លឺព្រះអាទិត្យបញ្ចេញរស្មីដ៏ស្រទន់ លើកំពូលភ្នំ យុគន្ធរដូច្នោះ។ ហើយទ្រង់ប្រថាប់នៅលើអាសនៈ កាលព្រះសម្មាសម្ពុទ្ធជា ម្ចាស់ស្ដេចយាងមកដល់ ទើបភិក្ខុសង្ឃបញ្ឈប់ការពិភាក្សា ហើយក៏នៅ ស្ងៀម។

ព្រះសាស្ដា ទ្រង់សម្លឹងមើលបរិស័ទដោយព្រះទ័យករុណា ទ្រង់ព្រះ តម្រិះថា បរិស័ទនេះល្អហើយ សំឡេងក្អកកណ្ដាសរបស់ ភិក្ខុមួយរូបក៏មិន

មាន ភិក្ខុទាំងពួងនេះមានសេចក្តីគោរព ដោយសេចក្តីគោរពក្នុងព្រះពុទ្ធជាម្ចាស់ ដែលតេជះរបស់ព្រះពុទ្ធជាម្ចាស់ គ្រប់គ្រងហើយ កាលតថាគតអង្គុយមិនពោលអស់កប្ប ភិក្ខុទាំងឡាយក៏មិននិយាយឡើយ ពោលឡើងមុន តថាគតគួរដឹងច្បាស់តថាគតនឹងពោលមុន ទើបត្រាស់ហៅភិក្ខុទាំងឡាយ ដោយព្រះសូរសៀងដូចជាសំឡេងព្រហ្មដ៏ពីរោះ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ ពួកអ្នកអង្គុយប្រជុំគ្នាដោយរឿងអ្វី រឿងអ្វីដែលពួកអ្នកនិយាយគ្នាមិនទាន់ដាច់ស្រេច ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គទាំងឡាយអង្គុយនៅទីនេះ មិនពោលតិរច្ឆានកថាយ៉ាងដទៃឡើយ តែអង្គុយពណ៌នាព្រះគុណទាំងឡាយរបស់ព្រះអង្គប៉ុណ្ណោះថា អាវុសោទាំងឡាយ ព្រះមហាបន្ថកៈមិនដឹងនូវអធ្យាស្រ័យរបស់ព្រះចុល្លបន្ថកៈ មិនអាចឱ្យរៀនគាថាមួយដោយ ៤ ខែ ទាញចេញពីវិហារដោយពោលថា ចុល្លបន្ថកៈនេះល្ងង់ខ្លៅ តែព្រះសម្មាសម្ពុទ្ធបានប្រទានព្រះអរហត្ត ព្រមទាំងបដិសម្ភិទាដល់ព្រះចុល្លបន្ថកៈនោះ ក្នុងចន្លោះភត្តនោះតែម្តង ព្រោះព្រះអង្គជាធម្មរាជាដ៏កំពូលអស្ចារ្យឈ្មោះថា កម្លាំងរបស់ព្រះពុទ្ធទាំងឡាយធំក្រៃលែង ព្រះសាស្តាទ្រង់បានស្តាប់ពាក្យ របស់ភិក្ខុទាំងឡាយហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ចុល្លបន្ថកៈសម្រេចដល់ភាពជាធំក្នុងធម៌ទាំងឡាយឥឡូវនេះព្រោះអាស្រ័យតថាគត តែក្នុងកាលមុន ចុល្លបន្ថកៈ នេះដល់ភាពជាធំក្នុងភោគៈ

ទាំងឡាយ ក៏ព្រោះអាស្រ័យតថាគត។ ទើបភិក្ខុទាំងឡាយទូលអារាធនាព្រះមានព្រះភាគ ដើម្បីត្រាស់សម្ដែងរឿងនោះឱ្យជាក់ច្បាស់ ព្រះមានព្រះភាគទ្រង់បានធ្វើហេតុក្នុងរវាងភព ដែលបិទបាំង ឱ្យប្រាកដដូចតទៅៈ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត គ្រប់គ្រងរាជ្យសម្បត្តិ នៅក្នុងក្រុងពារាណសី ក្នុងដែនកាសី ព្រះពោធិសត្វកើតនៅក្នុងត្រកូលសេដ្ឋី ចម្រើនវ័យហើយ បានទទួលតំណែងជាសេដ្ឋី បានឈ្មោះថា ចុល្លកសេដ្ឋី ចុល្លកសេដ្ឋីនោះជាបណ្ឌិតឈ្លាសវៃ ដឹងក្នុងនិមិត្តទាំងពួង ថ្ងៃមួយ ចុល្លកសេដ្ឋីនោះទៅកាន់ទីបម្រុងព្រះរាជា ឃើញកណ្ដុរងាប់កណ្ដាលថ្នល់គិតគ្នេរនក្ខត្តប្ញក្សខណៈនោះ ហើយពោលពាក្យថា កុលបុត្តអ្នកមានភ្នែក គឺបញ្ញាអាចយកកណ្ដុរមួយនេះទៅធ្វើការចិញ្ចឹមភរិយា នឹងប្រកបការងារបាន ។

# ពុទ្ធកាល

ពុទ្ធបរិស័ទជាអ្នករក្សាព្រះពុទ្ធសាសនា ត្រូវតែបានដឹងអំពីដំណើរនៃពង្សាវតារក្នុងព្រះពុទ្ធខ្លះៗ ដើម្បីងាយស្រួលក្នុងការថែរក្សា និងបានជ្រះថ្លារឹតតែខ្លាំងដោយអំណាចបានដឹង អំពីការត្រាស់ដឹងរបស់ព្រះពុទ្ធ។

ពុទ្ធកាល ឬ គឺកាលដែលព្រះពុទ្ធទ្រង់គង់ព្រះជន្មនៅក៏ ឬហៅបានថាពោធិកាលឬ ពោធិសម័យក៏បាន។ ពោធិកាលនៃព្រះសក្យមុនីសព្វញ្ញូពុទ្ធមាន ៤៥ ព្រះវស្សាបែងចែកជា ៣ សង្កាត់គឺ៖

១-រាប់ពីឆ្នាំដែលព្រះអង្គបានត្រាស់ដឹងមកដល់ឆ្នាំទី ១៥ ហៅថាបឋមពោធិកាល (គឺជាកាលខាងដើម)។

២-រាប់ពីត្រឹមឆ្នាំ ១៦ ដល់ឆ្នាំទី ៣០ ហៅថាមជ្ឈិមពោធិកាល។

៣-រាប់ពីត្រឹមឆ្នាំ ៣១ ដល់ឆ្នាំទី ៤៥ ហៅថាបច្ឆិមពោធិកាល។

ទ្រង់ចូលបរិនិព្វានក្នុងឆ្នាំទី ៤៥ នេះ,បូករួមព្រះជន្មពីកាលទ្រង់មិនទាន់បានត្រាស់ជាព្រះពុទ្ធនៅឡើយចំនួន ៣៥ ឆ្នាំផ្សំផងត្រូវជា ៨០ វស្សាឆ្នាំគត់។ សូមពុទ្ធបរិស័ទចូលសិក្សាក្នុងព្រះពុទ្ធសាសនាដោយសេចក្តីធ្វើទុកក្នុងចិត្តដើម្បីជាប្រយោជន៍ ម្យ៉ាងទៀតជាការសំខាន់នោះ គឺយើងទាំងអស់គ្នាបានដឹងអំពីដំណើររបស់ព្រះពុទ្ធ ដែលបានឆ្លងកាត់ឧបសគ្គជាច្រើនក្នុងជីវិតរស់នៅប្រចាំថ្ងៃរបស់ព្រះអង្គ មានពេលខ្លះក៏ជួបនូវសេចក្តីទុក្ខ

លំបាក មានពេលខ្លះក៏ជួបនូវសេចក្ដីសុខតាមផ្លូវកាយ និងតាមផ្លូវចិត្តរបស់ព្រះអង្គទៀតផង មិនតែប៉ុណ្ណោះទេ ព្រះអង្គបានព្យាយាមរកធម៌ជាច្រើនក្នុងការបង្ហាត់បង្រៀនពុទ្ធបរិស័ទ ព្រមទាំងភិក្ខុ ភិក្ខុនី សាមណេរ សាមណេរី ព្រមទាំងពុទ្ធបរិស័ទជាច្រើនទៀត ឱ្យបានត្រាស់ដឹងនូវអមតធម៌បាន។

# ពុទ្ធកិច្ចរបស់ព្រះសម្មាសម្ពុទ្ធ

នៅពេលដែលយើងទាំងអស់គ្នា បានអានអំពី ពុទ្ធកាលរបស់ព្រះអង្គ ហើយនោះ ពេលនេះយើងនឹងបានដឹងអំពីកិច្ចការរបស់ព្រះអង្គខ្លះៗ ទុកជាមិនបានសិក្សាពិស្តារយ៉ាងណាក៏ដោយ តែសូមពុទ្ធបរិស័ទសិក្សានូវពុទ្ធកិច្ចរបស់ព្រះអង្គដោយសង្ខេបនេះចុះ។

កិច្ចរបស់ព្រះពុទ្ធ គឺការរវល់សម្រាប់ព្រះសព្វញ្ញុពុទ្ធ មានស្តេចយាងចេញទៅបិណ្ឌបាតពីព្រឹកព្រលឹម និងទ្រង់ត្រាស់សម្តែងធម៌ដល់ពុទ្ធបរិស័ទជាដើម។ រីឯកិច្ចរបស់ព្រះពុទ្ធនោះមាន ៥ យ៉ាងគឺ៖

**១-បុរេភត្តកិច្ច** កិច្ចដែលព្រះពុទ្ធត្រូវបំពេញក្នុងពេលមុនភត្ត គឺតាំងពីពេល អរុណរះទៅទល់នឹងពេលថ្ងៃត្រង់ គឺទ្រង់បិណ្ឌបាត។

**២-បច្ឆាភត្តកិច្ច** កិច្ចដែលព្រះពុទ្ធត្រូវបំពេញក្នុងពេលក្រោយភត្ត គឺតាំងពីថ្ងៃត្រង់ទៅទល់នឹងពេលល្ងាច ទ្រង់សម្តែងធម៌)។

**៣-បឋមយាមកិច្ច** កិច្ចដែលព្រះពុទ្ធត្រូវបំពេញក្នុងយាមខាងដើមនៃរាត្រី គឺតាំងពីពេលព្រលប់ទៅទល់នឹងពេលកណ្តាលអធ្រាត្រ (ទ្រង់ប្រទានឱវាទដល់ភិក្ខុសង្ឃទាំងឡាយ)។

**៤-មជ្ឈិមយាមកិច្ច** កិច្ចដែលព្រះពុទ្ធត្រូវបំពេញក្នុងយាមកណ្តាលនៃរាត្រី គឺពេលកណ្តាលអធ្រាត្រទ្រង់ឆ្លើយបញ្ហាទេវតាមកសាកសួរ។

**៥-បច្ឆិមយាមកិច្ច** កិច្ចដែលព្រះពុទ្ធត្រូវបំពេញក្នុងយាមខាងចុងនៃរាត្រី គឺតាំងពីពេលបន្ទាប់អំពីកណ្តាលអធ្រាត្រទៅទល់នឹងពេលអរុណរះ (ទ្រង់ត្រូវមើលសត្វលោកដែល នឹងអាចសម្រេចធម៌ ដែលគួរព្រះអង្គទៅប្រោស ឬមិនទៅប្រោស)។ ក្នុងអដ្ឋកថាធម្មបទសម្តែងថា ព្រះអង្គប្រមើល មើលឧបនិស្ស័យសត្វក្នុងមួយយប់ពីរដង គឺក្នុងពេលជិតភ្លឺម្តង ពេលល្ងាចម្តង។ ពេលជិតភ្លឺទ្រង់ប្រមើល ពីកណ្តាប់មាត់ចក្រវាលរហូតមកទល់ព្រះគន្ធកុដិ, ពេលល្ងាចទ្រង់ប្រមើល មើលពីព្រះគន្ធកុដិ រហូតដល់ទៅកណ្តាប់មាត់ចក្រវាល។

ពុទ្ធភាសិតៈ **បុព្វណ្ហេ បិណ្ឌបាតញ្ច សាយណ្ហេ ធម្មទេសនំ បទោសេ ភិក្ខុឱវាទំ អឌ្ឍរត្តេ ទេវបញ្ហានំ បច្ចូសេវ គតេ កាលេ ភព្វាភព្វេ វិលោកនំ ឯតេ បញ្ចវិធេ កិច្ចេ វិសោធេតិ មុនិបុង្គវោតិ។** ព្រះសម្មាសម្ពុទ្ធជាចម្បងជាងអស់អ្នកប្រាជ្ញ ទ្រង់ជម្រះនូវពុទ្ធកិច្ចទាំងឡាយ ៥ ប្រការនេះ គឺក្នុងពេលព្រឹកទ្រង់ស្តេចទៅបិណ្ឌបាត ១ ក្នុងពេលល្ងាចទ្រង់សម្តែងធម៌ទេសនា១ ក្នុងពេលព្រលប់ទ្រង់ប្រទានឱវាទដល់ពួកភិក្ខុ១ ក្នុងពេលអធ្រាត្រទ្រង់ដោះប្រស្នានៃទេវតា១ ក្នុងពេលជិតភ្លឺទ្រង់ប្រមើលមើលនូវសត្វលោកដែលគួរត្រាស់ដឹង និងមិនគួរត្រាស់ដឹង១។

# ព្រះពុទ្ធគុណ

មានពុទ្ធបរិស័ទ ជាច្រើនដែលធ្លាប់តែបានសូត្រនូវធម៌សរសើរគុណរបស់សម្មាសម្ពុទ្ធ ប៉ុន្តែមិនបានដឹងអំពីសេចក្តីប្រែ ដូច្នេះហើយក៏ចេះតែសូធ្យៗទៅ មិនដឹងជាមានសេចក្តីប្រែយ៉ាងណានោះទេ។

ទុកតែធម៌នេះ មិនបានពិស្តារយ៉ាងណាក៏ដោយតែជាចំណែកមួយសម្រាប់ពុទ្ធបរិស័ទជាអ្នកបានចូលមកកាន់ព្រះពុទ្ធសាសនាថ្មីៗ ងាយស្រួល ក្នុងការសិក្សាយល់ដឹងអំពីគុណរបស់ព្រះសម្មាសម្ពុទ្ធមួយចំណែកដែរ សូមញាតិញោមអានសេចក្តី និងយកចិត្តទុកដាក់ដោយគោរពចុះ.. ពុទ្ធគុណ គឺជាសេចក្តីល្អរបស់ព្រះសម្មាសម្ពុទ្ធមាន ១០ យ៉ាងគឺ៖

**១.ឥតិបិ សោ ភគវា អរហំ** ព្រះដ៏មានព្រះភាគអង្គនោះទ្រង់ព្រះនាមថា អរហំ ព្រោះព្រះអង្គឆ្ងាយចាកសឹកសត្រូវ ពោលគឺកិលេសព្រមទាំងវាសនា គឺកាយបយោគ និងវចីបយោគ។

**២.សម្មាសម្ពុទ្ធោ** ទ្រង់ព្រះនាមថា សម្មាសម្ពុទ្ធោ ព្រោះព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងពួងដោយប្រពៃ ចំពោះព្រះអង្គឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ ។

**៣.វិជ្ជាចរណសម្បន្នោ** ទ្រង់ព្រះនាមថា វិជ្ជាចរណសម្បន្នោ ព្រោះព្រះអង្គ បរិបូណ៌ដោយវិជ្ជា ៣ និងវិជ្ជា ៨ និងចរណៈ ១៥ ។

៤.**សុគតោ** ទ្រង់ព្រះនាមថា សុគតោ ព្រោះព្រះអង្គមានដំណើរល្អ យាងទៅកាន់សុន្ទរស្ថាន គឺអមតមហានិព្វាន។

៥.**លោកវិទូ** ទ្រង់ព្រះនាមថា លោកវិទូ ព្រោះព្រះអង្គជ្រាបច្បាស់នូវត្រៃលោក។

៦.**អនុត្តរោ** ទ្រង់ព្រះនាមថា អនុត្តរោ ព្រោះព្រះអង្គប្រសើរដោយសីលាទិគុណរកបុគ្គលណាមួយស្មើគ្មាន។

៧.**បុរិសទម្មសារថិ** ទ្រង់ព្រះនាមថា បុរិសទម្មសារថិ ព្រោះព្រះអង្គជាអ្នកទូន្មាននូវបុរសដែលមានឧបនិស្ស័យគួរនឹងទូន្មានបាន។

៨.**សត្ថា ទេវមនុស្សានំ** ទ្រង់ព្រះនាមថា សត្ថា ទេវមនុស្សានំ ព្រោះព្រះអង្គជាសាស្តាចារ្យនៃទេវតា និងមនុស្សទាំងឡាយ។

៩.**ពុទ្ធោ** ព្រះអង្គត្រាស់ដឹងនូវចតុរារិយសច្ច ហើយញ៉ាំងអ្នកដទៃឱ្យត្រាស់ដឹងផង។

១០.**ភគវា** ព្រះអង្គមានដំណើរទៅកាន់ត្រៃភព ខ្ជាក់ចោលហើយ គឺថា ព្រះអង្គមិនត្រឡប់កើតទៀតឡើយ។

ការរលឹកដល់គុណរបស់ព្រះសម្មាសម្ពុទ្ធ ដែលហៅថាពុទ្ធានុស្សតិ មិនមែនសំដៅការលើកយកពាក្យណាមួយ មកទន្ទេញស្វាធ្យាយ ទាំងដែលមិនដឹងថា តើពាក្យនីមួយៗនោះមានន័យយ៉ាងណានោះទេ តាមពិតទៅការរឭកដល់គុណរបស់ព្រះសម្ពុទ្ធ គឺនៅត្រង់ការយល់ ហើយពិចារណា

តាមសមត្ថភាពនៃសទ្ធា និងបញ្ញារហូតកើតសេចក្ដីស្ងប់ចិត្ត ឃ្លាតឆ្ងាយពីបាបទាំងពួង។ នេះហៅថា ពុទ្ធានុស្សតិ ដែលប្រែថា ការរលឹករឿយៗដល់ព្រះសម្មាសម្ពុទ្ធ មិនមែននៅត្រង់ការទន្ទេញ ពុទ្ធានុស្សតិ ឬអរហំ ទាំងដែលមិនបានយល់ដល់ពុទ្ធគុណនោះឡើយ។

ព្រះនាមរបស់ព្រះសម្មាសម្ពុទ្ធ អាចក្លាយជាទីតាំងនៃសេចក្ដីស្ងប់ចិត្ត និងធ្វើឱ្យអ្នកនឹកឃើញមានសេចក្ដីរីករាយ ជ្រះថ្លាកើតបុណ្យកុសលផ្សេងៗយ៉ាងណាមិញ មនុស្សយើងក៏គួរតែរៀនតាមព្រះអង្គ ត្រង់ដែលថា ពេលដែលគេនឹកដល់យើងកាលណា ក៏កើតសេចក្ដីសុខកាយ សប្បាយចិត្ត មិនក្ដៅក្រហាយចិត្ត។

# បុណ្យតែងជួយអ្នកដែលប្រព្រឹត្តល្អ

យើងបានសិក្សាអំពីទង្វើល្អរបស់ខ្លួនយើងហើយ តែមានបុគ្គលខ្លះយល់ច្រឡំថាធ្វើល្អហើយបុណ្យមិនជួយ មានអ្នកខ្លះទៀតពោលថាមិនចាំបាច់ធ្វើបុណ្យទេព្រោះបុណ្យមិនជួយយើងឡើយខំធ្វើអ្វី ទាំងអស់នេះហើយជាបញ្ហាយ៉ាងខ្លាំងបំផុតក្នុងព្រះពុទ្ធសាសនា។

តាមសេចក្តីពិតបុណ្យតែងជួយយើងជានិច្ច ដូចជាគាថាព្រះពុទ្ធទ្រង់សម្តែង **សុខោ បុញ្ញស្ស ឧច្ចយោ** ការសន្សំបុណ្យតែងនាំមកនូវសេចក្តីសុខ។

ក្នុងព្រះវស្សាទី ៨ ព្រះដ៏មានព្រះភាគ ទ្រង់គង់ចាំវស្សាក្នុងភេសកឡាវ័នភគ្គជនបទ ខណៈដែលព្រះសាស្តាទ្រង់គង់ក្នុងភេសកឡាវ័ន ព្រះអនុរុទ្ធស្នាក់នៅក្នុងបាចីនវង្សទាយវ័ន ព្រះអង្គទ្រង់ជ្រាបបរិវិតក្ករបស់ព្រះអនុរុទ្ធខណៈដែលកំពុងពិចារណាធម៌ ទើបយាងទៅប្រាកដចំពោះមុខព្រះអនុរុទ្ធ ក្នុងវិហារ ត្រាស់ថាល្អហើយអនុរុទ្ធដែលអ្នកត្រិះរិះ មហាវិតក្កថាធម៌នេះជាធម៌របស់បុគ្គលអ្នកមានសេចក្តីប្រាថ្នាតិច ១ របស់អ្នកសន្តោស ១ របស់អ្នកស្ងប់ស្ងាត់ ១ របស់អ្នកប្រារព្ធព្យាយាម ១ របស់អ្នកមានសតិតាំងមាំ ១ របស់អ្នកមានចិត្តតាំងមាំ ១ របស់អ្នកមានបញ្ញា ១ នោះត្រឹមត្រូវហើយ ។

អ្នកគប្បីពិចារណាធម៌ ៨ បានដល់ ធម៌មិនជាហេតុឱ្យយឺតយូរ គឺព្រះនិព្វាន បន្ថែមឡើងមួយប្រការទៀត និងជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្ន រួចត្រាស់ថា អនុរុទ្ធអ្នកគប្បីនៅចាំវស្សាក្នុងបាចីនវង្សនេះហើយ។ បន្ទាប់មកព្រះអង្គយាងត្រឡប់មកភេសកឡាវ័ន ហើយទ្រង់សម្តែងមហាបុរិសវិតក្ក ៨ ប្រការ ដល់ភិក្ខុទាំងឡាយម្តងទៀត ព្រះអនុរុទ្ធគេចចេញចាកពួកតែម្នាក់ឯង ជាអ្នកមិនប្រមាទ មានព្យាយាម មិនយូរប៉ុន្មានក៏បានធ្វើឱ្យជាក់ច្បាស់នូវអរហត្តផលក្នុងបាចីនវង្សនោះឯង ។

បិតារបស់សិង្គាលកបុត្រលះចំណង់ក្នុងផ្ទះ ចេញបួសក្នុងព្រះពុទ្ធសាសនា ព្រះសាស្តាទ្រង់ជ្រាបអធ្យាស្រ័យ ទ្រង់ប្រទានអដ្ឋិកសញ្ញាកម្មដ្ឋានឱ្យសិង្គាលបិតាភិក្ខុទទួលកម្មដ្ឋានហើយ ចូលមកស្នាក់នៅក្នុងភេសកឡាវ័ន ទេវតានៅក្នុងព្រៃនេះ ប្រាថ្នានឹងសង្គ្រោះភិក្ខុនោះឱ្យមានឧស្សាហ៍ ដើម្បីនឹងបានសម្រេចអហត្តផលក្នុងកាលមិនយូរ ទើបពោលគាថា ដូច្នេះថាៈ ភិក្ខុនៅក្នុងភេសកឡាវ័ន ពិចារណាផែនដីនេះដោយសេចក្តីថា ឆ្អឹងទាំងអស់ជាអារម្មណ៍ នឹងបានជាទាយាទរបស់ព្រះពុទ្ធជាម្ចាស់ហើយនិងលះបង់កាមរាគៈបានដោយឆាប់រហ័ស ។

សិង្គាលកបិតាភិក្ខុ បានស្តាប់គាថារបស់ទេវតាដូច្នេះហើយ អធិដ្ឋានសេចក្តីព្យាយាម រុលទៅមុខមិនថយក្រោយ ចម្រើនវិបស្សនាបានសម្រេចអរហត្តហើយក្នុងវេលាមិនយូរ។ ក្នុងចន្លោះវស្សានេះ ព្រះអង្គទ្រង់បំពេញ

ពុទ្ធកិច្ច ប្រោសវេនេយ្យសត្វទាំងឡាយឱ្យសម្រេចមគ្គផល ដោយព្រះធម្មទេសនាដ៏ច្រើន ដូចជាត្រាស់ពោធិរាជកុមារសូត្រ ចំពោះពោធិរាជកុមារថា គប្បីរក្សាខ្លួនទុកឱ្យល្អក្នុងវ័យទាំង ៣ មិនគួរប្រមាទក្នុងកុសលទាំងបឋមវ័យ មជ្ឈិមវ័យ និងបច្ឆិមវ័យ បើមិនអាចធ្វើបានទាំង ៣ វ័យចូរតម្កល់ខ្លួនទុកក្នុងកុសលចំពោះវ័យណាមួយក៏បាន ។ ក្នុងមជ្ឈិមនិកាយ មជ្ឈិមបណ្ណាសកពោលថា ព្រះអង្គត្រាស់ដល់អ្នកមានព្យាយាម ៥ ប្រការ ថានឹងត្រូវប្រកបដោយ សទ្ធា ១ ប្រាសចាករាគៈ ១ មិនអួតអាង ១ មានព្យាយាមលះអកុសល ១ មានបញ្ញា ១ បើអ្នកណាប្រកបដោយអង្គ ៥ នេះហើយនឹងសម្រេចគុណវិសេសបានដោយឆាប់ ចប់ធម្មទេសនា ពោធិរាជកុមារបាន សម្រេចសោតាបត្តិផល ។

សិរិមណ្ឌៈជាបុត្ររបស់ព្រាហ្មណ៍ ក្នុងសុង្សុមារគិរីនគរ ខណៈដែលព្រះមានព្រះភាគទ្រង់គង់នៅភេសកឡាវន ចូលទៅគាល់ព្រះសាស្តា ស្តាប់ធម៌ហើយកើតសទ្ធា បានបួសធ្វើសមណធម៌ ក្នុងថ្ងៃឧបោសថមួយ អង្គុយនៅ ក្នុងទីសម្តែងបាតិមោក្ខ ពិចារណាខ្លឹមសាររបស់បាលីថា ភិក្ខុបើត្រូវអាបត្តិហើយរមែងមិនមានសេចក្តីសុខ ភិក្ខុណាបិទបាំងអាបត្តិទុកត្រូវអាបត្តិថែមទៀតភិក្ខុនោះរមែងនៅមិនសុខ ក៏ភិក្ខុបើកនូវអាបត្តិហើយសម្តែងអាបត្តិតាមធម៌ រមែងមានសេចក្តីសុខ។

សិរិមណ្ឌៈ កើតសេចក្តីជ្រះថ្លា ពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា បរិសុទ្ធពិត ទើបគ្របសង្កត់បីតិដែលកើតឡើងយ៉ាងនោះហើយ ចម្រើនវិបស្សនា បានសម្រេចព្រះអរហត្ត ពិចារណាការបដិបត្តិរបស់ខ្លួនហើយ មានចិត្តជ្រះថ្លាកាលឱ្យឱវាទដល់ភិក្ខុទាំងឡាយ ទើបពោលគាថាយ៉ាងនេះថាៈ សត្វលោកត្រូវមច្ចុកម្ទាត់ ត្រូវជរារួបរឹត ត្រូវកូនសរ គឺតណ្ហាចាត់ដោត ត្រូវសេចក្តីប្រាថ្នាដុតរោលគ្រប់កាលមិនមានអ្វីជាទីពឹងពាក់បាន រមែងក្តៅក្រហាយជានិច្ច ។

ជរា ព្យាធិ និងមរណៈ ដូចជាគំនរភ្លើងតាមគ្របសង្កត់សេចក្តីស្លាប់ រមែងរុកទន្ទ្រានចូលទៅជិតបុគ្គល គ្រប់ឥរិយាបថ មិនគួរបណ្តោយពេលវេលាឱ្យកន្លងទៅឥតប្រយោជន៍ រាត្រីកន្លងទៅប៉ុនណា ជីវិតរបស់សត្វក៏អស់ទៅប៉ុណ្ណោះ ទើបមិនគួរធ្វេសប្រហែសពេលវេលាឡើយ ។

គួរដាក់ចិត្តក្នុងវិបស្សនា ច្រើនខ្លះ តិចខ្លះ មិនគួរឱ្យថ្ងៃកន្លងទៅដោយឥតប្រយោជន៍ ព្រោះថាកាលកន្លងទៅប៉ុនណា ជីវិតរបស់សត្វក៏អស់ទៅប៉ុណ្ណោះ ទើបលោកសម្តែងថា ការអស់ទៅនៃរាត្រី ជាការអស់ទៅនៃអាយុ ព្រោះរាត្រីនោះមិនងាកត្រឡប់មកវិញ អ្នកមិនប្រមាទទូន្មានខ្លួនយ៉ាងនេះហើយ គប្បីធ្វើសេចក្តីព្យាយាមក្នុងសិក្ខាទាំង ៣ ចុះ ។

កាលព្រះសាស្តាទ្រង់គង់ក្នុងភេសកឡាវ័ន នកុលបិតាគហបតី បានចូលមកគាល់ ព្រមដោយអ្នកដែនសុង្សុមារគិរីនគរ ដោយការចូលគាល់

លើកដំបូងប៉ុណ្ណោះ គាត់និងភរិយាក៏តាំងសេចក្តីសម្គាល់ថា ព្រះទសពល ជាបុត្រ ទើបក្រាបចុះក្បែរព្រះយុគលបាទហើយក្រាបទូលថា កូនអើយ ! កូនឯងចោលពុកម៉ែអស់កាលយូរ លុះបានជួបក៏សម្គាល់ថាបុត្រ ទើបអ្នកទាំងពីរបានពោលវាចាដូច្នោះ តែព្រះសាស្តាមិនបានត្រាស់ពាក្យពេចន៍អ្វីឡើយ ព្រោះជ្រាបសេចក្តីដែល នកុលបិតា ធ្លាប់ជាប់ជាបិតា ជាឪពុកមាជាតា ជាអ៊ំ ចំណែក នកុលមាតា ក៏ធ្លាប់ជាមាតា ជាម្តាយមីង ជាយាយ ជាអ៊ំស្រី មកពីក្នុងអតីតៈដ៏ច្រើន ។

កាលនកុលៈទាំងពីរ ត្រឡប់មានសតិដូចដើមហើយ ទើបព្រះសាស្តាទ្រង់សម្តែងនកុលបិតុសូត្រ កាលចប់ទេសនា ទាំងពីរនាក់ក៏តាំងនៅក្នុងសោតាបត្តិផល ព្រះអង្គបានត្រាស់សម្តែងគាថានេះថាៈ

សេចក្តីស្រឡាញ់កើតឡើងព្រោះធ្លាប់នៅរួមគ្នាមកពីមុន ឬព្រោះសង្គ្រោះគ្នាក្នុងបច្ចុប្បន្នដូចផ្កាឈូកកើតឡើងអាស្រ័យទឹក និងភក់ដូច្នោះ ។

តមក ក្នុងវេលាដែលព្រះមានព្រះភាគទ្រង់ព្រះជរា បានយាងទៅកាន់ដែនភគ្គៈទៀត អ្នកទាំងពីរនោះជ្រាបថាព្រះសាស្តាយាងមក ទើបអារាធនាដើម្បីទទួលភត្ត លុះព្រឹកឡើងក៏អង្គាសភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធានដោយភោជនមានរសដ៏ប្រណីតផ្សេងៗ ក្នុងនិវេសន៍របស់ខ្លួនទូលព្រះអង្គថា ខ្ញុំព្រះអង្គប្រាថ្នាឱ្យជួបគ្នាទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងភពខាងមុខ! ទើបព្រះសាស្តាទ្រង់ទូន្មានថា ម្នាលគហបតី និងគហបតានី បើស្វាមីភរិយា

ប្រាថ្នាឱ្យបានជួបគ្នាទាំងក្នុងជាតិនេះ និងជាតិខាងមុខសោត អ្នកទាំងពីរគប្បីជាអ្នកមានសទ្ធាស្មើគ្នា មានសីលស្មើគ្នា មានចាគៈស្មើគ្នា មានបញ្ញាស្មើគ្នា ក៏នឹងបានជួបគ្នាទាំងក្នុងជាតិនេះ និងជាតិមុខ។ តមកខាងក្រោយខណៈដែលគង់ប្រថាប់នៅក្នុងវត្តជេតពន ទ្រង់សរសើរនកុលបិតា និងនកុលមាតាទាំងពីរថា ជាកំពូលជាងឧបាសក និងឧបាសិកាអ្នកស្និទ្ធស្នាលនឹងព្រះអង្គ ។

# សេចក្តីល្អរបស់មិត្ត

មនុស្សក្នុងលោកនេះ មិនងាយរកបានសន្តានចិត្តល្អគ្រប់សព្វនោះទេ តែប្រសិនបើមានវិញក៏មានដោយកម្រដែរ ដូច្នេះត្រូវចេះប្រយ័ត្នឱ្យបានច្រើនទើបល្អ និយាយខាងលើនេះមិនមែនបានន័យថា មនុស្សក្នុងលោកសុទ្ធតែអាក្រក់នោះឡើយ ។

តែទោះជាយ៉ាងនេះក្តីកូនត្រូវចេះរស់ឱ្យមានស្មារតីជានិច្ចព្រោះពិបាកណាស់បើយើងមិនបានពិចារណា វាអាចមានរឿងរ៉ាវជាច្រើនដែលយើងមិនបានដឹង ធម្មតារបស់ដែលបានបាត់បង់ ឬក៏វាត្រូវវិនាសដោយសារអ្វីមួយនោះ គឺដោយសារតែយើងភ្លេចស្មារតីហ្នឹងឯង។

នៅក្នុងសេចក្តីនេះ និយាយអំពីមិត្តល្អដែលយើងទាំងអស់គ្នាបានពិចារណាដូចតទៅ ព្រះពុទ្ធអង្គទ្រង់គង់នៅក្នុងភេសកឡាវ័ន ខណៈចូលកាន់រដូវរងា ភិក្ខុទាំងឡាយបង្កាត់ភ្លើងដោយកំណាត់ឈើមានប្រហោងមួយដុំ ដើម្បីអាំងភ្លើង ពស់វែកក្នុងប្រហោងឈើត្រូវភ្លើងរោលក្តៅ ទើបលូនចេញមកដេញពួកភិក្ខុ ពួកភិក្ខុរត់គេចទៅក្នុងទីផ្សេងៗ ព្រះមានព្រះភាគជាម្ចាស់ជ្រាបសេចក្តីនោះ ទ្រង់តិះដៀល ហើយបញ្ញត្តសិក្ខាបទថា ភិក្ខុណាប្រាថ្នាការអាំងភ្លើង បង្កាត់ភ្លើងក្តី ឱ្យគេបង្កាត់នូវភ្លើងក្តី ត្រូវអាបត្តិបាចិត្តយៈ តែទ្រង់អនុញ្ញាតដល់ភិក្ខុអាពាធអាំងភ្លើងបាន ។

បន្ទាប់មកទៀត ស្តេចយាងត្រឡប់ទៅគង់នៅនាវត្តជេតពនវិញ ទ្រង់សម្តែងធម៌ប្រោសពុទ្ធបរិស័ទទាំង ៤ ឱ្យតាំងនៅក្នុងធម៌ តាមសមគួរដល់អធ្យាស្រ័យ ។ គ្រានោះព្រាហ្មណ៍ ២ នាក់ចាស់ជរាកន្លងបច្ឆិមវ័យ មានអាយុ១២០ ឆ្នាំ ចូលមកគាល់ព្រះមានព្រះភាគ ក្រាបទូលថា ខ្ញុំព្រះអង្គជាព្រាហ្មណ៍ កន្លងកាលមករហូតដល់បច្ឆិមវ័យហើយ មិនទាន់បានធ្វើសេចក្តីល្អ មិនទាន់បានសាងកុសល មិនទាន់បានធ្វើគ្រឿងការពារភ័យ សូមព្រះគោតមដ៏ចម្រើន ប្រោសមេត្តាទ្រង់ឱ្យ ឱវាទប្រៀនប្រដៅខ្ញុំព្រះអង្គដែលនឹងប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ខ្ញុំព្រះអង្គ អស់កាលដ៏យូរអង្វែងផងចុះ ។

ព្រះមានព្រះភាគជាម្ចាស់ត្រាស់សម្តែងថា សត្វលោកនេះត្រូវជាតិនាំទៅកាន់ជរា ត្រូវជរានាំទៅកាន់ព្យាធិ ត្រូវព្យាធិនាំទៅកាន់មរណៈ ត្រូវមរណៈនាំទៅកាន់ជាតិ គឺការកើតទៀត គប្បីសង្រួមកាយ វាចា ចិត្តឱ្យជាទីពឹងក្នុងភពខាងមុខចុះ កាលផ្ទះត្រូវភ្លើងឆេះ ម្ចាស់ផ្ទះជញ្ជូនវត្ថុណាចេញបាន វត្ថុនោះក៏នឹងបានជាប្រយោជន៍ដល់ម្ចាស់ផ្ទះ ដូចសត្វលោកដែលជរាមរណៈឆេះយ៉ាងនេះ សត្វលោកគប្បីជញ្ជូនចេញដោយការឱ្យទានចុះ វត្ថុណាដែលឱ្យជាទាន ឈ្មោះថា បានជញ្ជូនចេញយ៉ាងល្អហើយ ព្រោះហេតុដែលព្រាហ្មណ៍នោះ សូម្បីបួសហើយក៏មិនអាចបំពេញវត្តឱ្យបរិបូណ៌បាន ព្រោះជរាណាស់ទៅហើយ ទើបព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ឱ្យ

សមាទានសីល ៥ ។ ព្រាហ្មណ៍នោះសមាទានសីល ៥ រក្សាសីល ៥ ឱ្យបរិបូណ៌អស់មួយជីវិត បានកើតហើយក្នុងសួគ៌ ព្រោះការសង្រួមកាយ វាចា និងចិត្ត ដែលតាំងចិត្តសមាទានទុកដោយប្រពៃ បុណ្យរមែងប្រព្រឹត្តទៅដើម្បីសេចក្តីសុខដល់គេ ដែលលះលោកនេះទៅហើយដូច្នេះ ។

ខណៈដែលព្រះពុទ្ធអង្គទ្រង់គង់នៅក្នុងព្រះជេតវនវិហារ ក្នុងវេលាជិតភ្លឺទ្រង់ឃើញឧបនិស្ស័យព្រះអរហន្តនៃ មាគន្ទិយព្រាហ្មណ៍ ពីរនាក់ស្វាមីភរិយា អ្នកស្រុកកម្មាសទ្ធម្មនិគម ដែនកុរុ ទើបយាងទៅប្រថាប់គង់នៅនាដងព្រៃមួយក្នុងនិគមនោះ ។ មាគន្ទិយព្រាហ្មណ៍ទៅកាន់ដងព្រៃនោះ បានឃើញព្រះរស្មីពណ៌មាសរបស់ព្រះសាស្តា ក៏សប្បាយចិត្តដោយបំណងនឹងលើកធីតាឱ្យ ទើបប្រញាប់ត្រឡប់ទៅផ្ទះដើម្បីប្រាប់នាងព្រាហ្មណី ហើយនាំធីតាមក ខណៈនោះព្រះពុទ្ធអង្គចូលទៅបិណ្ឌបាតក្នុងកម្មាសទ្ធម្មៈ នាងព្រាហ្មណីឃើញ ស្នាមព្រះបាទហើយពោលថា សមណៈនេះមិនបរិភោគកាមពិត ។

ព្រាហ្មណ៍ជាបិតាដឹកដៃធីតាចូលទៅហើយពោលថា បព្វជិតដ៏ចម្រើនលោកមានសម្បុរដូចមាស ទារិកានេះក៏មានសម្បុរដូចមាស ទើបទារិកានេះសមគួរដល់លោក។ ព្រះពុទ្ធអង្គត្រាស់ថា តថាគតមិនមានការពេញចិត្តក្នុងមេថុន សូម្បីព្រោះឃើញធីតារបស់មារទៀបគល់អជ្ជបាលនិគ្រោធ ដូចម្តេចនឹងមានការពេញចិត្ត ព្រោះឃើញធីតារបស់អ្នកដែលពេញទៅដោយមូត្រ

និងករីសដូច្នេះ។ ក្នុងទីបំផុតនៃគាថា ព្រាហ្មណ៍ និងព្រាហ្មណីតាំងនៅក្នុងអនាគាមិផល ចំណែកធីតារបស់មាគន្ទិយព្រាហ្មណ៍ក្រោធខឹង ចងអាឃាតជាមួយនឹងព្រះពុទ្ធអង្គតាំងពីនោះមក។ មាគន្ទិយព្រាហ្មណ៍ទូលសួរថា ធម្មតាបព្វជិតលះបង់កាម ដែលជារបស់មនុស្សហើយបួសដើម្បីកាមដែលជារបស់ទិព្វតែសមណៈនេះមិនប្រាថ្នាកាម សូម្បីតែរបស់ទិព្វ អ្វីហ្ន៎ជាទិដ្ឋិរបស់សមណៈនេះ។ ព្រះអង្គត្រាស់ថា បុគ្គលលះបង់ធម៌ដែលជាផ្នែកខ្មៅដោយការដកចេញមិនប្រកាន់មាំ ឈ្មោះថាជាអ្នកស្ងប់ ព្រោះស្ងប់ចាកកិលេសខាងក្នុងស្ងប់ចាកតណ្ហា ស្ងប់ចាកទិដ្ឋិ មិនគប្បីប្រាថ្នាភពណាៗ នេះជាសេចក្តីស្ងប់ក្នុងខាងក្នុងនៃបុគ្គលអ្នកលះតណ្ហាមានះ ទិដ្ឋិបាន ឈ្មោះថារួចផុតហើយចាកកិលេសទាំងពួង មិនញ៉ាំងអត្តភាពឱ្យកើតទៀត កាលចប់ទេសនាមាគន្ទិយព្រាហ្មណ៍ទាំងពីរនាក់សូមបួស ហើយបានសម្រេចអរហត្តផល នាំធីតាទៅផ្ញើទុកជាមួយនឹងមាគន្ទិយាដែលជាឪពុកមាហើយទៅកាន់សំណាក់ព្រះសាស្តា ។

ក្នុងកុរុរដ្ឋនេះ ខណៈដែលព្រះពុទ្ធអង្គយាងដល់ថុល្លកោដ្ឋិតនិគមកុលបុត្រឈ្មោះ រដ្ឋបាល បានស្តាប់ព្រះធម្មទេសនាហើយ កើតសទ្ធាជ្រះថ្លាចង់បួស ធ្វើការអត់នូវអាហារអស់ ៧ ថ្ងៃ ទើបមាតាបិតាអនុញ្ញាតឱ្យបួសបានចូលទៅគាល់ព្រះពុទ្ធអង្គបួសហើយក្នុងសំណាក់ព្រះថេរៈមួយរូប តាមបញ្ជារបស់ព្រះសាស្តា។ ព្រះពុទ្ធទ្រង់ប្រាប់ថា នៅនាថុល្លកោដ្ឋិតគ្រាមអស់

កន្លះខែ ហើយយាងត្រឡប់ទៅក្រុងសាវត្ថី ព្រមដោយព្រះរដ្ឋបាល ព្រះថេរៈធ្វើកិច្ចក្នុងយោនិសោមនសិការៈ ចម្រើនវិបស្សនាសម្រេចអរហត្ត ហើយបានទូលសូមការអនុញ្ញាតពីព្រះសាស្តា ត្រឡប់ទៅសួរសុខទុក្ខមាតាបិតានាថុល្លកោដ្ឋិតគ្រាម ទៅសម្រាកនៅក្នុងសួនរបស់ព្រះរាជានៃដែនកុរុ ព្រឹកឡើងទៅបិណ្ឌបាតឯផ្ទះ ជួបនាងទាសីកំពុងចាក់នំកុម្មាសផ្អូមចោល ទើបចូលទៅបិណ្ឌបាតនំនោះពីនាងទាសី នាងទាសីចាំសំឡេងបាន ទើបប្រគេននំនោះ ហើយចូលទៅប្រាប់ដល់មាតាបិតា បិតាចេញមកឃើញលោកកំពុងឆាន់នំផ្អូមស្រេចហើយ បាននិមន្តចូលទៅក្នុងផ្ទះ តែព្រះថេរៈមិនព្រមចូលទៅ។ ស្អែកឡើងព្រះរដ្ឋបាលចូលទៅបិណ្ឌបាត ឯផ្ទះទៀត បិតាព្យាយាមប្រលោមចិត្តដោយភោគទ្រព្យ ព្រោះត្រូវការឱ្យបុត្រ ត្រឡប់មកជាយរាវាសដូចដើម ព្រះថេរៈបានឃើញអតីតភរិយាតែងខ្លួនយ៉ាងស្រស់ស្អាតកើតអសុភសញ្ញាក្នុងស្ត្រីនោះ សម្រេចអភិញ្ញាហោះទៅកាន់មិគាចិរៈឧទ្យានរបស់ព្រះបាទកោរព្យៈ ដែលជាព្រះរាជានៃដែនកុរុឈរ សម្តែងធម៌ដែលប្រកបដោយសេចក្តីជ្រះថ្លា ៤ ប្រការ ដល់ព្រះរាជាដែលមកសួរសុខទុក្ខក្នុងឧទ្យាននោះថា

**១.ឧបនិយតិ លោកោ អទ្ធុវោ** សត្វលោកដែលជរានាំទៅ មិនតាំងនៅយូរ។

**២.អតាណោ លោកោ អនភិស្សរោ** សត្វលោកមិនមានទីពឹងពួន មិនជាឥស្សរៈលើខ្លួនឯង ។

**៣.អស្សកោ លោកោ សព្វំ បហាយគមនិយំ** សត្វលោកមិនមានវត្ថុណាជារបស់ខ្លួន ត្រូវលះបង់នូវវត្ថុគ្រប់យ៉ាងហើយទៅ ។

**៤.ឩនោ លោកោ អតិត្តោ តណ្ហាទាសោ** សត្វលោកខ្វះកន្លះជានិច្ច មិនចេះឆ្អែតជាទាសៈនៃតណ្ហា ។

ព្រះរដ្ឋបាលចារិកទៅដោយលំដាប់ ត្រឡប់ទៅគាល់ព្រះសាស្តានាក្រុងសាវត្ថីទៀត តមកព្រះអង្គទ្រង់សរសើរព្រះរដ្ឋបាលថា ជាកំពូលលើសភិក្ខុទាំងឡាយផ្នែកអ្នកបួសដោយសទ្ធា ។

សម័យនោះតាបស ៥០០ នាក់ដែលស្នាក់នៅក្នុងព្រៃហិមពាន្ត ចូលមកភិក្ខាចារក្នុងក្រុងកោសម្ពីជាប្រចាំ សេដ្ឋីក្រុងកោសម្ពី ៣ នាក់ គឺឃោសកៈ កុក្កុដៈ និង បាវារិកៈ ឃើញតាបសទាំងនោះហើយ កើតសេចក្តីជ្រះថ្លា ទើបនិមន្តឱ្យទទួលភិក្ខានៅផ្ទះរបស់ខ្លួនទាំង ៣ ជាប្រចាំ។ មុនដល់រដូវភ្លៀង គ្រាមួយពួកតាបសបានធ្វើដំណើរពីព្រៃហិមពាន្ត ដើម្បីមកកាន់ក្រុងកោសម្ពី ក្នុងចន្លោះផ្លូវឆៀងចុះសម្រាកក្បែរ គល់ជ្រៃធំមួយដើម រុក្ខទេវតាដែលស្ថិតនៅត្រង់ដើមជ្រៃនោះ សម្តែងកាយចេញមកឱ្យទឹកភេសជ្ជៈ ពួកតាបស ឃើញរុក្ខទេវតាប្រដាប់ដោយអាភរណៈទិព្វដ៏ស្រស់ស្អាត ទើបសួរថាអ្នកបានសម្បត្តិនេះដោយផលបុណ្យណា រុក្ខទេវតាពោល

ឱ្យស្តាប់ថា ជាផលពីការដែលខ្ញុំបានអធិដ្ឋានអង្គឧបោសថកន្លះថ្ងៃ កាលដែលខ្ញុំចាប់កំណើត ជាបរិវាររបស់លោកអនាថបិណ្ឌិកសេដ្ឋី ហើយបានធ្វើកាលកិរិយាក្នុងល្ងាចថ្ងៃនោះ មកកើតជារុក្ខទេវតាក្នុងទីនេះ សេដ្ឋីនោះជាអ្នកដែលមានសទ្ធាខ្លាំង ចំពោះព្រះសម្មាសម្ពុទ្ធជាម្ចាស់ ព្រះធម៌ និងព្រះសង្ឃ។ ពួកតាបសបានស្តាប់ ពាក្យថាព្រះសម្មាសម្ពុទ្ធ កើតសេចក្តីជ្រះថ្លា តាំងចិត្តធ្វើដំណើរទៅគាល់ព្រះសាស្តា លុះដល់ក្រុងកោសម្ពី ក៏ចូលទៅប្រាប់ពីបំណងដល់សេដ្ឋីទាំងបី សេដ្ឋីពោលថា ពួកយើងខ្ញុំនឹងសូមទៅតាមលោកផង តាបសធ្វើដំណើរទៅមុខ កាលចូលគាល់ព្រះសាស្តានៅជេតវនវិហារ ស្តាប់ធម៌ទេសនាហើយតាបសទាំង ៥០០ បានសម្រេចអរហត្តព្រមដោយបដិសម្ភិទាទាំងអស់ ទើបទូលសូមបព្វជ្ជាឧសម្បទា ព្រះសាស្តាទ្រង់ប្រទានឯហិភិក្ខុឧបសម្បទា។ សេដ្ឋីទាំង ៣ ព្រមដោយរទេះផ្ទុកគ្រឿងទេយ្យធម៌ជាចំនួនច្រើន តាមមកខាងក្រោយ តាំងទីស្នាក់នៅក្បែរវត្តជេតពន បានថ្វាយទានក្នុងទីនោះ ប្រមាណកន្លះខែ កាលទទួលស្តាប់ព្រះធម៌ទេសនាហើយ បានសម្រេចសោតាបត្តិផល ទូលអារាធនាព្រះពុទ្ធអង្គ ទៅគង់នៅក្នុងក្រុងកោសម្ពី។

សេដ្ឋីទាំង ៣ ត្រឡប់មកដល់ក្រុងកោសម្ពីវិញ ម្នាក់ៗ កសាងអារាមមួយៗម្នាក់ ឃោសកសេដ្ឋីកសាងឃោសិតារាម បាវារិកសេដ្ឋីសាង បាវារិកា

រាម កក្កុដសេដ្ឋីសាង កុក្កុដារាម ក្រោយពីសាងវិហារស្រេចទើបទៅអារាធនាព្រះពុទ្ធអង្គ ។

កាលព្រះសាស្តាយាងមកដល់ ទើបសេដ្ឋីថ្វាយវិហារដល់ភិក្ខុសង្ឃដែលមកអំពីទិសទាំង ៤ ដែលមានព្រះពុទ្ធជាប្រធានឲ្យព្រះសាស្តាអនុមោទនា និងទ្រង់គង់ក្នុងអារាមទាំង ៣ នោះ សេដ្ឋីម្នាក់ៗ ក៏ផ្លាស់ប្តូរគ្នាឧបដ្ឋាកព្រះសម្មាសម្ពុទ្ធជាម្ចាស់ និងភិក្ខុសង្ឃតាមវារៈរបស់ខ្លួន។

# កូនត្រូវចេះថែរក្សាសុខភាព

កូនៗទាំងឡាយ សូមកូនចងចាំថា សុខភាពជាកត្តាចម្បងសម្រាប់ជីវិតយើងណាកូន ដូច្នេះកូនត្រូវចេះថែរក្សាសុខភាពរបស់ខ្លួនឯងណាកូន មិនមាន នរណាអាចថែរក្សាសុខភាពយើងបានក្រៅអំពីខ្លួនយើងឡើយ។

យ៉ាងនេះហើយបានជាម៉ែ ចង់ប្រាប់កូនៗទាំងឡាយឲ្យចេះថែរក្សាសុខភាពខ្លួនឯង ព្រោះកូនបែកអំពីម៉ែឆ្ងាយ ពុកម៉ែបារម្ភ ខ្លាចកូនមានរោគច្រើនណាកូនម៉ែ សូមកូនចងចាំពាក្យទូន្មានរបស់ព្រះសាស្តាខ្លះៗ ក្រៅពីកូនសិក្សានៅសាលាណាកូន សូមកូនសិក្សាដូចតទៅ........អាយុវឌ្ឍនធម៌គឺវិធីថែរក្សាសុខភាពល្អ និងចម្រើនអាយុឱ្យបានវែងផងណាកូនម៉ែ។

ដោយសារអាយុវឌ្ឍធម៌នេះឯង ទើបព្រះអង្គអាចតម្រង់ព្រះជន្មបានរហូតដល់ ៨០ វស្សាទើបចូលនិព្វាន ឯការថែរក្សាអាយុនោះមិនមានអ្វីច្រើននោះទេ គឺមានតែ ៧ យ៉ាងប៉ុណ្ណោះ

**១.សប្បាយការី** ចេះធ្វើសេចក្តីសប្បាយឱ្យដល់ខ្លួនឯង គឺអនុវត្តទៅតាមក្បួនអនាម័យ និងក្បួនសុខភាព ដូចជាឥរិយាបថទាំង ៤ គឺដេកដើរ ឈរ អង្គុយ ត្រូវផ្លាស់ប្តូរឱ្យបានសមរម្យ មានការហាត់ប្រាណបញ្ចេញកម្លាំង សម្អាតខ្លួនប្រាណកូន។

**២.សប្បាយេ មត្តញ្ញូ** មានប្រមាណ ស្គាល់ល្មម ស្គាល់ប្រមាណនៅក្នុងរបស់សប្បាយទាំងឡាយ ដូចជាមិនបរិភោគរហូតទាល់តែហាល់ មើលសម្លឹងទូរទស្សន៍ រហូតដល់ទៅព្រិលភ្នែក ហៀរទឹកភ្នែក ផឹករហូតដល់ក្អែចេញមកវិញ។ ម្យ៉ាងវិញទៀត គឺចេះជ្រើសរើសរបស់ណាមិនហុចទោសយកមកបម្រើសេចក្ដីសប្បាយរបស់ខ្លួនដូចជាស្រា បារី កញ្ឆា ជាដើមនេះសុទ្ធតែជារបស់នាំឱ្យទោស អ្នកសប្បាយត្រូវចេះស្គាល់ប្រមាណក្នុងការជ្រើសរើសរបស់ទាំងនេះ មកប្រើផងដែរ។

**៣.បរិណតភោជី** បរិភោគតែអាហារណាដែលរលាយងាយ ក្រពះស្រួលកិន មិននាំឱ្យខូចក្រពះ និងទំពាឱ្យបានម៉ដ្ឋល្អ ។

**៤.កាលចារី** ស្គាល់ពេលវេលាក្នុងការធ្វើការ ធ្វើត្រូវសមពេល ធ្វើមានពេល មានវេលា ស្គាល់ថាគួរធ្វើការប៉ុន្មានម៉ោង សម្រាកកាយប៉ុន្មានម៉ោង រៀនសូត្រប៉ុន្មានម៉ោងជាដើម ។

**៥.ព្រហ្មចារី** ប្រព្រឹត្តព្រហ្មចរិយធម៌ អ្នកដែលជាគ្រហស្ថត្រូវចេះកំណត់កាមារម្មណ៍របស់ខ្លួន ត្រូវវៀរចាកនូវការសេពសន្ថវៈខ្លះ ព្រោះអ្នកល្មោភក្នុងកាមគុណ នឹងនាំឱ្យបាក់កម្លាំងថែមទាំងវិនាសទ្រព្យសម្បត្តិ។

**៦.សីលវា** មានសីល ប្រព្រឹត្តល្អ មិនធ្វើអ្វីដែលខុសច្បាប់ក្នុងប្រទេស ដែលសង្គមគេស្អប់ខ្ពើមណាកូន។

**៧.កល្យាណមិត្ត** មានកល្យាណមិត្ត មិត្តល្អ មិត្តដែលមិនបបួលទៅរកអបាយមុខទាំង ៤ គឺស្រី ស្រា ល្បែង អំពើពាលា។

ទាំងអស់នេះតើកូនអាចធ្វើបានទេ? ប្រសិនបើកូនធ្វើបាននោះល្អខ្លាំងណាស់ណាកូនម៉ែ តែបើកូនមិនអាចធ្វើបានទេ កូនត្រូវតែព្យាយាមណា ទាំងនេះជាកត្តាសំខាន់ សម្រាប់ជីវិតកូនព្រមទាំងអ្នកដទៃណាកូនម៉ែ។

# ធ្វើជាមនុស្សត្រូវចេះអភ័យទោស

កូនត្រូវយល់ថា ការសងសឹកទៅលើបុគ្គលដែលជាអ្នកបង្កបញ្ហាបាន ត្រឹមតែបង្កើនបញ្ហា និងបង្កផលលំបាកកាន់តែច្រើនថែមទៀតប៉ុណ្ណោះ កូនត្រូវដឹងថា គំនិត និងសកម្មភាពអាក្រក់នាំមកនូវការខូចខាត និងសេចក្តីទុក្ខដល់អ្នកបង្កបញ្ហាថែមទាំងខ្លួនកូនទៀតផង ។

ដូច្នេះកូនធ្វើអ្វីមួយត្រូវពិចារណាឱ្យបានច្បាស់ និងប្រកបដោយបញ្ញាជានិច្ចណាកូនរបស់ម៉ែ ទោះស្ថិតនៅកន្លែងណាក៏ដោយត្រូវចេះធ្វើជាមនុស្សឱ្យអភ័យដល់អ្នកដទៃ ព្រោះអ្នកដទៃគេចង់បានសេចក្តីសន្តោសប្រោសប្រណីពីរូបកូនណាស់ណាកូន។ កូនៗត្រូវចាំថាការខឹងក្រោធរបស់ខ្លួនយើងទៅដាក់អ្នកដទៃអាក្រក់ខ្លាំងបំផុត ដូចជាការពោលពាក្យអាក្រក់ទ្រគោះបោះបោក ពាក្យគ្រោតគ្រាតជាដើមវាមិនល្អទេកូន ពេលដែលកូនខឹងជាមួយនរណាហើយក្នុងចិត្តរបស់កូន រមែងនៅមិនសុខឡើយ មានការអន្ទះសាចង់តែទៅបញ្ចេញកំហឹងដាក់គេ ថាខ្លួនឯងគ្រាន់បើផងណាកូន តើខ្លួនរបស់កូនមានគិតអ៊ីចឹងទេ?

ប្រសិនបើកូន មានរឿងដូចជាពាក្យម៉ែពោលខាងលើពិតមែន សូមកូនពិចារណាមើលទោសរបស់វាសាកមើលណាកូន...

**១.ន ហិ សាធុ កោធោ** សេចក្តីក្រោធមិនល្អសោះឡើយ

**២.កោធោ សត្ថមលំ លោកេ** សេចក្តីក្រោធ ទុកដូចជាច្រែស របស់អាវុធក្នុងលោក

**៣.អនត្ថជននោ កោធោ** សេចក្តីក្រោធ នាំទៅរកសេចក្តីវិនាស

**៤-កោធោ ចិត្តបកោបនោ** សេចក្តីក្រោធ ធ្វើឱ្យចិត្តមិនបានសម្រាក

**៥-កោធោ ទុម្មេធគោចរោ** សេចក្តីក្រោធ ជាលក្ខណៈរបស់មនុស្សពាលណាកូនម៉ែ

**៦-នត្ថិ ទោសសមោ គហោ** គ្មានការចាប់ចងឯណាស្មើ នឹងទោសៈនេះទេ (គឺការចងនូវកំហឹងដែលបានខឹងនឹងនរណាម្នាក់)

**៧-នត្ថិ ទោសសមោ កលិ** គ្មានកំហុសណាស្មើនឹងទោសៈទេ

**៨-ហន្តិ កុទ្ធោ សមាតរំ** ជនដែលក្រោធ សូម្បីតែម្តាយខ្លួនក៏ហ៊ានសម្លាប់

**៩-កុទ្ធោ អត្ថំ ន ជានាតិ** ជនដែលក្រោធ រមែងមិនឃើញនូវហេតុទាំងឡាយ

**១០-កុទ្ធោ ធម្មំ ន បស្សតិ** អ្នកក្រោធ រមែងមិនឃើញនូវធម៌ដែលជាហេតុទាំងឡាយ

**១១-ទុក្ខំ សយតិ កោធនោ** មនុស្សក្រោធ តែងដេកកើតទុក្ខជានិច្ច

**១២-អថោ អត្ថំ គហេត្វាន អនត្ថំ បដិបជ្ជតិ** អ្នកដែលមានសេចក្តីក្រោធចូលលុកលុយហើយ តែងបំផ្លាញនូវផលប្រយោជន៍ដែលខ្លួនមាន ។

ទាំងអស់នេះ គឺជាពុទ្ធភាសិតខ្លះៗ សូមកូនៗពិចារណានូវជាតកជារឿងមួយដែលនៅក្នុងព្រះពុទ្ធសាសនាសង្ខេបថា នៅភាគខាងត្បូងនៃព្រៃហិមពាន្តនៃប្រទេសឥណ្ឌា កាលពីយូរលង់មកហើយ មាននគរមួយឈ្មោះបទុមនគរ សោយរាជ្យដោយព្រះបាទបទុមរាជ និងនាងបទុមទេវី ជាអគ្គមហេសី។ ព្រះរាជាមានព្រះរាជបុត្រាបុត្រីជាច្រើនអង្គ តែអង្គដែលធំជាងគេព្រះនាមថា មហាបទុម ព្រះរាជាសោយរាជ្យដ៏សុខសាន្ត ឯព្រះរាជកុមារមហាបទុមក៏មានព្រះជន្មាយុ ១៨ វស្សា ជាទីស្រឡាញ់គោរពរបស់ប្រជារាស្ត្រជាខ្លាំង ព្រោះព្រះអង្គជារាជកុមារដែលមានកិរិយាទន់ភ្លន់ និងឆ្លៀវឆ្លាត។

ព្រះបាទបទុមរាជទ្រង់មានមហេសីថ្មី ១ ព្រះអង្គទៀតដែលនៅវ័យក្មេងខ្ចីអាយុស្របាលៗនឹងមហាបទុមជារាជបុត្រ។ ជាធម្មតាទៅហើយដែលព្រះបាទបទុមរាជ ទ្រង់មានព្រះជន្មាយុជាង ៦០ វស្សាទៅហើយហើយបានមហេសីក្មេង ព្រះអង្គពុំអាចបំពេញនូវចំណង់រាគៈតណ្ហាតាមផ្លូវកាមរបស់មហេសីក្មេងនោះបានឡើយ បើទោះជាព្រះអង្គផ្តល់នូវកិត្តិយសនិងផ្តល់ព្រះរាជទ្រព្យដ៏បរិបូណ៌យ៉ាងណាក្តី។ ដូច្នេះហើយ បន្ទាប់ពីអភិសេកមហេសីទី ២ មិនយូរប៉ុន្មាន ព្រះនាងរតនាវតីក៏លបលួចស្នេហា

ទៅលើព្រះរាជកុមារមហាបទុម ព្រោះនៅក្មេងជាទីពេញចិត្តមនោរម្យរបស់វ័យស្រីក្មេងដូចគ្នា។ នាងរតនាវតី តែងតែបញ្ចេញនូវមាយាស្រីទាំងពួងឱ្យមហាបទុមដឹងថានាងស្រឡាញ់ ហើយព្យាយាម នឹងបើកដៃឱ្យមហាបទុមរួមដំណេក ជាមួយនាងជានិច្ច។ តែមហាបទុមជារាជកុមារល្អ តែងតែគេចចេញជានិច្ច មិនឱ្យកាមលោកិយដែលមាតាចុងក្មេងព្យាយាមឱ្យនោះ គ្របដណ្តប់បានឡើយ។ សំបុត្រស្នេហាជាច្រើន បានសរសេរផ្ដោះផ្ដងឱ្យព្រះរាជកុមារ តែព្រះអង្គក៏ពុំតបត ហើយក៏លាក់ការណ៍នោះរហូត។

រាត្រីមួយ ដោយទ្រាំទ្រនឹងភ្លើងរាគៈមិនបាន នាងរតនាវតី មហេសីចុងព្រះបាទបទុមរាជា ក៏ពុតធ្វើជាប្រឈួនខ្លាំង ហើយក៏បានឱ្យភីលៀងទៅតាមរាជកុមារមហាបទុមមកមើលខ្លួនក្នុងបន្ទប់។ ពេលបទុមចូលដល់ក្នុងបន្ទប់ ឃើញនាងរតនាវតីសំងំគ្រលុំផាហ៊ុម ក៏ដើរទៅលុតជង្គង់សួរ។ ពេលនោះឯង នាងរតនាវតីក៏ងើបឡើងមួយរំពេច ហើយក៏ស្ទុះទៅបិទទ្វារយកខ្នងរាំងជាប់ មហាបទុមដឹងថាចាញ់ល្បិចក៏ស្ទុះចេញ តែត្រូវនាងរតនាវតីចាប់ឱបដោយភ្លើងតណ្ហា ហើយក៏ប្រតាយគ្នារហូតដល់របូតស្បៃសំពត់សារីពីខ្លួននាងរតនាវតី។ មហាបទុមខំរើ ឯនាងរតនាវតីខំរឹតជួនជាពេលជួបនឹងគ្រោះអកុសល ព្រះបាទបទុមរាជាក៏រុញទ្វារចូលមក ហើយក៏ស្រឡាំងកាំងចំពោះទិដ្ឋភាពប្រតាយគ្នានោះ ពេលនោះនាងរតនាវតី ស្រីចិត្តចើកក៏ស្រែកយំភ្លាម ហើយធ្វើជាខំរើបម្រាសស្រែកសុំឱ្យបទុមរាជាស្វាមីជួយដោយទទូច

ថាមហាបទុមកំពុងចាប់រំលោភខ្លួន។ ព្រះបាទបទុមរាជាក្រោធខ្ញាល់ជាខ្លាំង ក៏បញ្ជាឱ្យអាមាត្យចាប់ចង ហើយឱ្យយកទៅបោះក្នុងជ្រោះទាំងរស់ឱ្យបានទាន់មុនថ្ងៃរះ បើទោះជាមហាបទុមកុមារខំស្រែកប្រាប់ថាមិនពិតយ៉ាងណាក៏ដោយ។ តែកំហឹងព្រះរាជា ធ្វើឱ្យព្រះអង្គលែងគិតថា មហាបទុមជាបុត្រព្រះអង្គទៅហើយ ឯព្រះនាងបទុមទេវី ជាព្រះមាតាពុំអាចដឹងរឿងឡើយ។

មុននឹងដើរទៅទម្លាក់ខ្លួន ទៅក្នុងជ្រោះដោយស្ម័គ្រចិត្តនិងបានអនុញ្ញាតពីពេជ្ឈឃាត មហាបទុមកុមារបានផ្ញើសំបុត្រសរសេរនឹងឈាមតាមពេជ្ឈឃាតទៅឱ្យព្រះមាតាព្រះអង្គដឹង ហើយក៏លោតទម្លាក់ខ្លួនទៅក្នុងជ្រោះទៅ។

ព្រឹកព្រហាមឡើង ព្រះនាងបទុមទេវី ក៏បានទទួលសំបុត្រលោហិតដែលនៅក្នុងនោះមានបញ្ជាក់ពីកន្លែងទុកភស្តុតាងនានា ជាពិសេសសំបុត្ររតនាវតី ព្រះនាងបទុមទេវីតក់ស្លុតរហូតដល់បាត់ព្រះស្មារតីសន្លប់លុះដឹងព្រះកាយវិញ ព្រះនាងក៏នាំយកភស្តុតាងនោះទៅថ្វាយព្រះបទុមរាជឱ្យបានជ្រាប។ ពេលឃើញភស្តុតាងហើយ ព្រះបាទបទុមរាជាក៏ក្តៅក្រហាយ ខឹងក្រេវក្រោធជាខ្លាំង ចំពោះរតនាវតី ហើយក៏បានឱ្យអាមាត្យចាប់នាងរតនាវតីយកទៅទម្លាក់ក្នុងជ្រោះមុន ព្រះអាទិត្យលិច ចំណែកព្រះអង្គមានការសោកស្តាយជាខ្លាំងចំពោះព្រះរាជបុត្រ ដែលត្រូវអស់ព្រះជន្មជីវិតដោយសារសេចក្តីក្រោធរបស់ព្រះអង្គ។

ថ្ងៃក្រោយមក ព្រះបាទបទុមរាជា ក៏បានចេញទៅប្រពាតព្រៃបរបាញ់សត្វជាមួយនឹងព្រះរាជបុត្រព្រះអង្គ ១ អង្គទៀត ហើយពេលដែលដើរទៅដល់ព្រៃជ្រៅ ក៏បានវង្វេងផ្លូវបានដើររហូតទៅដល់យប់ នៅតែរកផ្លូវត្រឡប់មករាជវាំងវិញមិនឃើញ ជាភ័ព្វសំណាងព្រះអង្គក៏បានចូលទៅក្នុងរូងភ្នំមួយ ហើយនៅទីនោះ ព្រះអង្គបានជួបនឹងឫសីយោគី ដែលមានសក់វែងពុកមាត់ ពុកចង្កាវែង ដូចព្រាយម្នាក់កំពុងបដិបត្តិធម៌ ឥសីអង្គនោះ ក៏បានទទួលព្រះរាជា និងរាជបុត្រឱ្យស្នាក់នៅ ១ យប់ បន្ទាប់ពីសន្ទនាគ្នា ១ សន្ទុះធំមកព្រះរាជាក៏ដឹងថា ឥសីអង្គនោះ គឺជាមហាបទុមរាជបុត្រដែលព្រះអង្គបានឱ្យពេជ្ឈឃាតសម្លាប់។ ព្រះរាជាសោកសង្រេងជាខ្លាំងបានថ្វាយបង្គំសូមខមាទោសឥសីមហាបទុម ហើយបានអង្វរសុំឱ្យមហាបទុមវិលត្រឡប់ ទៅវិញដើម្បីគ្រងរាជ្យតែមហាបទុមមិនព្រមឡើយ ព្រោះចិត្តឥសីតម្រង់ឆ្ពោះទៅរកពោធិញ្ញាណ ដើម្បីត្រាស់ដឹងជាព្រះពុទ្ធនៅពេលអនាគត។

ព្រឹកឡើងដោយចាញ់ចេះនឹងអង្វរ ព្រះបាទបទុមរាជា និងព្រះរាជបុត្រ ក៏លាឥសីមហាបទុមត្រឡប់មកទៅវិញ បន្ទាប់ពីបានប្រាប់ផ្លូវដល់ព្រះរាជា និងព្រះអនុជហើយ ឥសីមហាបទុមក៏បានពោលជាគាថាផ្តាំផ្ញើដល់បិតា និងព្រះអនុជថា៖

**នាទិដ្ឋា បរតោ ទោសំ អណុំ ថូលានិ សព្វសោ**

**ឥស្សរោបណាយេ ឧណ្ហំ   សាមំ អប្បដិវេក្ខិយ ។**

ព្រះរាជាឥស្សរជន  បើមិនទាន់ឃើញទោសតូចទោសធំដោយសព្វគ្រប់អំពីសម្នាក់បុគ្គលដទៃ  ទាំងមិនទាន់ពិចារណាឱ្យឃើញច្បាស់ដោយខ្លួនឯងទេ មិនគប្បីដាក់អាជ្ញាឡើយ។

រឿងសេចក្តីក្រោធនេះបើកើតមាន ចំពោះបុគ្គលណាហើយវាអាក្រក់ខ្លាំងណាស់ ដូច្នេះចូរកូនថែរក្សាចិត្តរបស់កូនឱ្យបានស្ថិតនៅតែក្នុងអំពើល្អ តែម្យ៉ាងពេលណាដែលមានសេចក្តីក្រោធកើតឡើង កូនត្រូវតែពិចារណារកនូវដំណោះស្រាយឱ្យបានលឿនបំផុត តែបើរកដំណោះស្រាយមិនឃើញទេត្រូវតែអត់ធ្មត់ជានិច្ច  អ្នកណាអាចរម្ងាប់សេចក្តីក្រោធដែលកើតឡើងបានភ្លាមមួយរំពេច ដូចអ្នកបើកបររថ បញ្ឈប់រថដែលកំពុងរត់ទៅមុខយ៉ាងលឿនបានភ្លាមមួយរំពេច អ្នកនោះ ព្រះសម្មាសម្ពុទ្ធហៅថាជានាយសារថីចំណែកអ្នកក្រៅពីនោះព្រះសម្មាសម្ពុទ្ធ  ហៅត្រឹមតែជាអ្នកកាន់ខ្សែតែប៉ុណ្ណោះ ។

# កូនត្រូវចេះឱ្យទានផង

កូនត្រូវចេះឱ្យទានដល់អ្នកដទៃផងណាកូន ពេលដែលខ្លួនរបស់កូនមានសមត្ថភាព កូនអាចពឹងពាក់លើខ្លួនឯងបាន កូនត្រូវតែចេះជួយអ្នកដទៃមិនថាជួយដោយកាយក្តី ដោយវាចា ឬក៏ដោយចិត្តនោះទេ។

យើងត្រូវតែមាន ជំនឿចិត្តលើខ្លួនឯងជានិច្ចមិនត្រូវអស់សង្ឃឹមនោះឡើយ ដូចជាការសិក្សា ការរកជំនួញជួញដូរ គឺត្រូវតែមានក្តីសង្ឃឹម យ៉ាងធំបំផុតលើខ្លួនឯង អ្នកដទៃគ្រាន់តែបន្ទាប់បន្សំតែប៉ុណ្ណោះមិនអាចជួយយើងបានទាំងអស់នោះទេ ទាំងនេះហើយជាការងារ ដែលយើងត្រូវធ្វើវាឱ្យបានញឹកញាប់បំផុតផងដែរណាកូន។ ចំពោះរឿងមួយទៀត គឺសន្តានចិត្តល្អមិនថាស្ថិតក្នុងកាលៈទេសៈណាទេ យើងត្រូវតែមានសន្តានចិត្តឱ្យបរិសុទ្ធជានិច្ច សន្តានចិត្តល្អនេះណាកូនសំខាន់ខ្លាំងណាស់ ពេលដែលកូនមានសន្តានចិត្តល្អហើយនៅទីកន្លែងណាៗ រមែងមានគេស្រឡាញ់រាប់អាននៅទីនោះ មួយទៀតសូមកូនជាអ្នកធ្វើទានដោយមានបញ្ញាផងព្រះសម្មាសម្ពុទ្ធបានត្រាស់សម្តែងថា ការឱ្យទាន និងផលរបស់ទានដែលពួកសប្បុរសបានឱ្យ មាន ៥ យ៉ាង សូមកូនពិចារណា...

## សប្បុរិសទាន ៥ យ៉ាង

**១.សក្កច្ចំ ទានំ ទេតិ** ឱ្យទានដោយគោរព ចំពោះវត្ថុដែលគួរឱ្យ

**២.ចិត្តី កត្វា ទានំ ទេតិ** ឱ្យទានដោយតាំងចិត្តគោរពចំពោះ វត្ថុនិងបដិគ្គាហកៈ

**៣.សហត្ថា ទានំ ទេតិ** ឱ្យទានដោយដៃខ្លួនឯង

**៤.អនបវិទ្ធំ ទានំ ទេតិ** ឱ្យទានដោយមិនបោះឱ្យ

**៥.អាគមនទិដ្ឋិកោទានំ ទេតិ** ឱ្យទានដោយចិត្តជឿថា នឹងបានទទួលផលដោយពិត។

សូមពិចារណាផងថា ការដែលយើងធ្វើអ្វីមួយហើយ រមែងឱ្យផលយ៉ាងពិតប្រាកដ ដូចជាការសិក្សាជាដើម ពេលដែលយើងខំរៀនរមែងបានទទួលលទ្ធផលល្អយ៉ាងពិត មានការងារជាច្រើនទៀត មិនបានរៀបរាប់បញ្ចូលក្នុងទីនេះ យ៉ាងណាមិញការឱ្យទានរបស់យើងក៏មានផល ៥ យ៉ាងដែរ...

**១.សទ្ធាយ ទានំ ទេតិ** ឱ្យទានដោយសទ្ធា បុគ្គលដែលឱ្យទានដោយសទ្ធាដោយផលទានទាំងនោះកើតឡើងក្នុងទីណាៗ ជាបុគ្គលស្តុកស្តម្ភ មានទ្រព្យច្រើនមានភោគៈច្រើនផង ជាបុគ្គលមានរូបល្អ គួររមិលមើលជាទីជ្រះថ្លាប្រកបដោយភាពជាអ្នកមានសប្បុរសធម៌ល្អដ៏ក្រៃលែង។

**២-សក្កច្ចំ ទានំ ទេតិ** ឱ្យទានដោយគោរព បុគ្គលដែលឱ្យទានដោយគោរព ដោយផលទាននោះកើតក្នុងទីណាៗ ជាបុគ្គលស្តុកស្តម្ភ មានទ្រព្យច្រើនមានភោគច្រើនផង ពួកជនណា ទោះបីកូនក្តី ប្រពន្ធក្តី ខ្ញុំក្តី អ្នក

បម្រើក្ដី អ្នកធ្វើការក្ដី របស់បុគ្គលនោះជនទាំងនោះតែងស្ដាប់ដោយល្អផ្ទៀង សោតាតាំងចិត្តដើម្បីដឹងផង។

**៣-កាលេន ទានំ ទេតិ** ឱ្យទានសមគួរតាមកាល បុគ្គលដែលឱ្យទានតាមកាលដ៏សមគួរ ដោយផលទាននោះ កើតក្នុងទីណាៗ ជាបុគ្គលស្ដុកស្ដម្ភមានទ្រព្យច្រើន មានភោគច្រើន ប្រយោជន៍ គឺពោរពេញ រមែងមកតាមកាលដ៏គួរដល់បុគ្គលនោះផង។

**៤-អនុគ្គហិតចិត្តោ ទានំ ទេតិ** ឱ្យទានដោយសេចក្ដីអនុគ្រោះ បុគ្គលដែលឱ្យទានដោយចិត្តអនុគ្រោះ ដោយផលទាននោះ កើតក្នុងទីណាៗ ជាអ្នកស្ដុកស្ដម្ភមានទ្រព្យច្រើន មានភោគច្រើន រមែងបង្អោនចិត្តទៅដើម្បីបរិភោគកាមគុណ ៥ ដ៏លើសលប់ផង។

**៥-អត្តានញ្ច បរញ្ច ទានំ ទេតិ** ឱ្យទានដោយមិនបានបៀតបៀនខ្លួនឯង និងអ្នកដទៃ បុគ្គលដែលឱ្យទានមិនបានបៀតបៀនខ្លួនឯង និងអ្នកដទៃដោយផលទាននោះកើតក្នុងទីណាៗ ជាបុគ្គលស្ដុកស្ដម្ភមានទ្រព្យច្រើន មានភោគៈច្រើន សេចក្ដីអន្តរាយនៃភោគទាំងឡាយមិនមានមកពីទីណាមួយ គឺភ្លើង អំពីទឹក អំពីស្ដេច អំពីចោរ អំពីហេតុមិនជាទីស្រឡាញ់ និងមនុស្សដែលជា ទាយាទ។ ទាំងអស់នេះហើយដែលយើងត្រូវពិចារណាអំពីសេចក្ដីល្អរបស់ខ្លួនឯងដែលបានធ្វើ និងបានបរិច្ចាគជាច្រើន ឬមួយកំពុងតែធ្វើសព្វថ្ងៃនេះ។ ចំពោះទានដែលកូនបានធ្វើហើយមិនមាន

ផលក៏មានដែរសូមសិក្សាដូចតទៅនេះ ដែលពួកសប្បុរសឱ្យឈ្មោះថា អសប្បុរិសទាន មាន ៥ យ៉ាង គឺៈ

**១.អសក្កច្ចំ ទានំ ទេតិ** ឱ្យទានដោយមិនគោរពវត្ថុ គឺមិនបានសម្អាតផ្ចិតផ្ចង់ទេយ្យវត្ថុឱ្យថ្លៃថ្លាជាមុន។

**២.អចិត្តី កត្វា ទានំ ទេតិ** ឱ្យទានដោយមិនតាំងចិត្តចំពោះវត្ថុ និងអ្នកទទួល (គឺមើលងាយ)

**៣.អសហត្ថា ទានំ ទេតិ** មិនឱ្យដោយដៃខ្លួនឯង (ប្រើគេ)

**៤.អបវិដ្ឋំ ទានំ ទេតិ** ឱ្យទានធ្វើដូចយកទៅបោះចោល

**៥.អនាគមនាទិដ្ឋិកោទានំទេតិ** ឱ្យទានដោយយល់ថាមិនមានផល។

ដូច្នេះ កូនធ្វើអ្វីមួយត្រូវពិចារណាឱ្យបានច្រើនផងណា កូនរបស់ម៉ែ ព្រោះអំពើ ដែលយើងធ្វើទៅលើអ្វីមួយ រមែងមានការល្អ និងអាក្រក់យ៉ាងនេះហើយមុន នឹងនិយាយស្តីអ្វីមួយចូរពិចារណាទុកជាមុន ថាតើអ្វីដែលយើងធ្វើ អ្វីដែលយើងធ្វើ អ្វីដែលយើងពោលទៅនោះមានទោស ឬក៏គ្មានទោស។

# អានិសង្សនៃការឱ្យទាន

អានិសង្សនៃការឱ្យទាន មានផលដែលនាំទៅរកសេចក្តីល្អយ៉ាងពិតប្រាកដទាំងបច្ចុប្បន្ន ទាំងទៅបរលោក មានប្រយោជន៍ទៅដល់ជនជាច្រើនទៀតដែលយើងមិនធ្លាប់បានដឹងទៀតផង។

១-អ្នកណាឱ្យទាន ដោយប្រាថ្នាតបផលមកវិញ យ៉ាងណាមួយក្នុងភពខាងមុខកាលស្លាប់ហើយ នឹងទៅកើតទេវតាជាន់ចាតុម្មហារាជិកា។

២-អ្នកណាឱ្យទាន ដោយមិនប្រាថ្នាផលតបមកវិញ ក្នុងភពខាងមុខទេ គឺឱ្យដោយគិតថា ការឱ្យទានជាការល្អ កាលស្លាប់ហើយ នឹងទៅកើតទេវតាជាន់តាវត្តិង្ស។

៣-អ្នកណាឱ្យទាន ដោយគិតថា មាតា បិតា យាយ តា ធ្លាប់ធ្វើមកហើយគួរធ្វើទៅ មិនឱ្យខូចប្រពៃណី កាលស្លាប់ទៅហើយ នឹងទៅកើតទេវតាជាន់យាមា។

៤-អ្នកណាឱ្យទាន ដោយមេត្តាប្រាថ្នានឹងឱ្យអ្នកទទួលទានមានសេចក្តីសុខ មិនមានសេចក្តីលំបាក កាលស្លាប់ហើយ នឹងទៅកើតទេវតាជាន់តុសិត។

៥-អ្នកណាឱ្យទាន ដើម្បីបដិបត្តិតាមអ្នកប្រាជ្ញ លោកឱ្យទានកន្លងមកពីកាលមុនកាលស្លាប់ហើយ នឹងទៅកើតទេវតាជាន់និម្មានរតី។

៦-អ្នកណាឱ្យទាន ដោយឃើញថា កាលឱ្យទានហើយ នឹងធ្វើចិត្តឱ្យរីករាយសោមនស្ស កើតសេចក្តីជ្រះថ្លា កាលស្លាប់ហើយនឹងទៅកើតទេវតាជាន់បរនិម្មិតវសវត្តី។

៧-អ្នកណាឱ្យទាន ដើម្បីជម្រះចិត្តឱ្យផូរផង់ បានឈាន កាលស្លាប់ហើយ នឹងទៅកើតក្នុងព្រហ្មលោក។

## បុគ្គលអ្នកធ្វើបុណ្យបានផលឃើញនឹងភ្នែក ៦ រូបគឺៈ

១-នាយបុណ្ណទាសីនោះ បានថ្វាយភត្តាហារដល់ព្រះសារីបុត្តត្ថេរ ក៏បានជាបុណ្ណកសេដ្ឋីក្នុងថ្ងៃថ្វាយភត្តាហារនុ៎ះឯង។

២-ព្រះនាងគោបាលមាតា ប្រកបដោយសទ្ធា យកសក់ទៅលក់បាន ៨ កហាបណៈហើយយកទ្រព្យ ៨ កហាបណៈនោះទៅទិញអាហារបិណ្ឌបាត ថ្វាយដល់ព្រះមហាកច្ចាយនត្ថេរ ក៏បានផលជាទិដ្ឋធម្មវេទនីយកម្ម បានជាអគ្គមហេសីរបស់ព្រះបាទចណ្ឌប្បជ្ជោត ក្នុងថ្ងៃដែលថ្វាយអាហារបិណ្ឌបាតនោះ...តមកព្រះអគ្គមហេសីមានព្រះរាជឱរសមួយព្រះអង្គទ្រង់ព្រះនាមថា **គោបាលកុមារ** ព្រះរាជទានព្រះនាមនេះឱ្យដូចជាលោកមហាសេដ្ឋីដែលជាតា.... តអំពីនោះជាដើមមកព្រះអគ្គមហេសីក៏មានព្រះនាមថ្មីថា ព្រះនាងគោបាលមាតា។

៣-នាងសុប្បិយាឧបាសិកា បានកាត់យកសាច់ភ្លៅរបស់ខ្លួនឯងធ្វើជាអាហារថ្វាយដល់ភិក្ខុដែលមានអាពាធ ក៏បានផលជាទិដ្ឋធម្មវេទនីយកម្ម ព្រឹកឡើងថ្ងៃទីពីរដំបៅដែលកាត់នោះក៏ជាសះភ្លាម អត់មានស្នាម។

៤-នាងមល្លិកានោះ បានថ្វាយនំសណ្តែកមួយដុំ ដល់ព្រះមានព្រះភាគ ក៏បានផលជាទិដ្ឋធម្មវេទនីយកម្មឃើញជាក់ច្បាស់ភ្លាមៗ គឺបានជាអគ្គមហេសី របស់ព្រះបាទកោសលក្នុងថ្ងៃថ្វាយទាននុ៎ះឯង។

៥-នាយសុមនមាលាការនោះ បានផ្កាម្លិះ ៨ ក្តាប់រោយរាយបូជាព្រះបរមលោកនាថ ក៏បានផល ជាទិដ្ឋធម្មវេទនីយកម្ម ឃើញជាក់ច្បាស់ ភ្លាមៗ គឺបានសម្បត្តិយ៉ាងច្រើនដែលជារបស់ព្រះរាជាប្រទាន។

៦-ឯកសាដកព្រាហ្មណ៍នោះ មានសំពត់ដណ្តប់មួយផ្ទាំង យកសំពត់ដណ្តប់មួយផ្ទាំងនោះបូជាដល់ព្រះសម្មាសម្ពុទ្ធ ព្រះរាជាក៏ទ្រង់ព្រះរាជទានរបស់ទាំងឡាយទាំងពួងម្តង ៨ មុខៗក្នុងថ្ងៃថ្វាយទាននុ៎ះឯង (ពីរនាក់ប្តីប្រពន្ធ មានសំពត់ដណ្តប់តែមួយផ្ទាំង សំពត់ស្លៀកមួយផ្ទាំង បើនឹងថ្វាយបានក៏ជាវេលាយូរ រមែងត្រូវទូន្មានចិត្តកំណាញ់ រហូតកាត់ចិត្តបានក៏យូរដែរ)។

# ឧត្តមបុរស

សូមកូនរបស់ឪ ពិចារណាផងណា ថាទង្វើដែលយើងបានប្រព្រឹត្តទៅមិនល្អទៅដល់អ្នកដទៃដូចជាអំពើហិង្សាជាដើម។

កូនៗ សុទ្ធតែជាអ្នកធ្លាប់បានឮពាក្យថាបុរសនេះហើយ តែមានកូនមួយចំនួន មិនបានយល់ពាក្យថាបុរសនេះ ដូច្នេះហើយធ្វើខ្លួនឯងជាបុរសរួចទៅប្រព្រឹត្តអំពើមិនល្អ ដូចជាមានការធ្វើចោរកម្ម វាយកាប់ចាក់ ធ្វើបាបប្រពន្ធកូន មើលងាយឪពុកម្ដាយរបស់ខ្លួនជាដើម អំពើទាំងនេះមិនមែនជាបុរសទេណាកូន។ តាមការពិត ពាក្យថាបុរសនេះមានអត្ថន័យពីរោះណាស់ណាកូនរបស់ម៉ែ ជាមនុស្សល្អ ដូចជាការធ្វើការងារបម្រើមាតាបិតា ជាអ្នកបំពេញចិត្តភរិយា ជាអ្នកមើលការខុសត្រូវក្នុងប្រទេសដែលខ្លួនរស់នៅជាដើម តទៅនេះសូមកូនពិចារណានូវព្រះធម៌មួយកន្លែងដែលព្រះសម្មាសម្ពុទ្ធបរមគ្រូបាន ត្រាស់សម្ដែងទុកអំពីអង្គរបស់ឧត្តមបុរសដូចតទៅ

**១-អស្សទ្ធោ** មិនជឿអ្នកដទៃ បានសេចក្ដីថា ខណៈដែលខ្លួនដឹងច្បាស់ចាំរហូតដោយមិនចេះតែជឿអ្នកដទៃ។

**២-អកតញ្ញូ ច** ស្គាល់ព្រះនិព្វាន បានចាក់ធ្លុះព្រះនិព្វានហើយ។

**៣-សន្ធិច្ឆេទោ** កាត់នូវតំណបាន (កាត់នូវសង្សារវដ្ត)។

**៤-ហតាវកាសោ** មានឱកាសកម្ចាត់បង់ហើយ (ឱកាសដែលនឹងត្រូវកើតទៀតកម្ចាត់បានហើយ បានដល់មិនធ្វើពូជ គឺកុសលកម្ម និង អកុសលកម្មផងដែរ)។

**៥-វន្តាសោ** ខ្ជាក់ចោលនូវសេចក្តីប្រាថ្នា (សេចក្តីប្រាថ្នាចំពោះមគ្គផលមិនមាន ព្រោះបានសម្រេចមគ្គផលហើយ)។

**បុរសដែលល្អ គឺមានសេចក្តីអត់ធន់ មានការព្យាយាម មានចំណេះវិជ្ជា ជាអ្នកចេះដឹង មានការងារល្អ ទើបជាបុរសដែលនារីគ្រប់រូបប្រាថ្នាត្រូវការចង់បានជាគូស្វាមីអស់មួយជីវិត។**

# នាមអ្នកពោល នមោ គ្រាដំបូង ៥ នាក់

មានពុទ្ធបរិស័ទ មួយចំនួនតែងតែនិយាយគ្នាអំពី **នមោ** ហើយម្យ៉ាងទៀត មានពុទ្ធបរិស័ទតែងតែបានសូធ្យធម៌ នមោ នេះជាញឹកញាប់តែនៅមិនបានដឹងថា នរណាជាអ្នកពោលនូវពាក្យទាំងនេះ។

ម្យ៉ាងទៀត នមោ នេះបើសម្តែងឱ្យពិស្តារទៅវែងឆ្ងាយពេកសូមពុទ្ធបរិស័ទអានតែនាមអ្នកដែលបានពោលដូចតទៅ...

**១-នមោ** សាតាគិរីយក្សអ្នកពោលនមស្ការ

**២-តស្ស** អសុរិន្ទរាហូអ្នកពោលនមស្ការ

**៣-ភគវតោ** ស្តេចចាតុម្មហារាជិកាអ្នកពោលនមស្ការ

**៤-អរហតោ** ស្តេចសក្កទេវរាជអ្នកពោលនមស្ការ

**៥-សម្មាសម្ពុទ្ធស្ស** ស្តេចមហាព្រហ្ម

ទេវតាទាំង ៥ អង្គនេះ ជាអ្នកពោលនមស្ការម្តងមួយបទៗ ព្រះគាថានេះមានប្រាកដនៅក្នុងដីកាមង្គល ព្រះអរហន្តបានប្រមូលចងក្រង ទុកជាបទ ជាមួយគ្នាសម្រាប់នឹងបាននមស្ការដល់ព្រះគុណរបស់ព្រះសម្មាសម្ពុទ្ធទាំង ៣

**១-បញ្ញាធិក** ព្រះសម្មាសម្ពុទ្ធអ្នកក្រៃលែងដោយបញ្ញា

**២-សទ្ធាធិក** ព្រះសម្មាសម្ពុទ្ធអ្នកក្រៃលែងដោយសទ្ធា

**៣-វីរិយាធិក** ព្រះសម្មាសម្ពុទ្ធអ្នកក្រៃលែងដោយវិរិយៈ (គឺសេចក្តីព្យាយាម) យើងទាំងអស់គ្នា បានសិក្សាយល់ច្បាស់ហើយក្នុងការប្រតិបត្តិមិនយល់ខុស មានការជ្រះថ្លាពោលសរសើរគុណព្រះដ៏មានព្រះភាគមិនចេះនឿយហត់ ទីបំផុតនៃជីវិតរស់នៅមានតែសុខសន្តិភាពទាំងអស់គ្នា។

# រយៈពេលនៃការបំពេញបារមីរបស់ព្រះពុទ្ធ ៣ ព្រះអង្គ

**១-បញ្ញាធិក** បំពេញបារមីរួមទាំងអស់ ១៦ អសង្ខេយ្យ ១ សែនកប្ប គឺ កាលបំពេញបារមីហើយនឹកនៅតែក្នុងព្រះហឫទ័យថា នឹងបានជាព្រះពុទ្ធ មិនបានបញ្ចេញវាចារាប់បាន ៧ អសង្ខេយ្យ បំពេញបាបរមីហើយបានបញ្ចេញវាចាប្រាថ្នាជាព្រះពុទ្ធរហូតទល់នឹងបានទទួលការណ៍ អំពីក្នុងសំណាក់នៃព្រះសម្មាសម្ពុទ្ធអង្គណាមួយរាប់បាន ៥ អសង្ខេយ្យ ចាប់ផ្ដើមពីបានទទួលការព្យាករអំពីក្នុងសំណាក់ របស់ព្រះសម្មាសម្ពុទ្ធអង្គណាមួយហើយថា នឹងបានត្រាស់ជាព្រះសម្មាសម្ពុទ្ធរាប់បាន ៤ អសង្ខេយ្យ និង ១ សែនកប្បរួមការបំពេញបារមីទាំងអស់ ១៦ អសង្ខេយ្យនិង ១ សែនកប្ប។

**២-សទ្ធាធិក** បំពេញបារមីរួមទាំងអស់ ៤០ អសង្ខេយ្យ ១ សែនកប្ប គឺកាលបំពេញបារមីហើយ នឹកនៅតែក្នុងព្រះហឫទ័យថា នឹងបានជាព្រះពុទ្ធ មិនបានបញ្ចេញវាចារាប់បាន ១៤ អសង្ខេយ្យ កាលបានបញ្ចេញវាចាប្រាថ្នាជាព្រះពុទ្ធ រហូតទល់នឹងបានទទួលការណ៍អំពីក្នុងសំណាក់នៃ ព្រះសម្មាសម្ពុទ្ធអង្គណាមួយរាប់បាន ៥ អសង្ខេយ្យចាប់ផ្ដើមពីបានទទួលការព្យាករ អំពីក្នុងសំណាក់របស់ព្រះសម្មាសម្ពុទ្ធអង្គណាមួយហើយថានឹងបានត្រាស់ជា ព្រះសម្មាសម្ពុទ្ធ រាប់បាន ១៨ អសង្ខេយ្យ ចាប់ផ្ដើមពីបានទទួលការព្យាករក្នុងសំណាក់របស់ព្រះសម្មាសម្ពុទ្ធអង្គណាមួយ

ហើយថា នឹងបានត្រាស់ជាព្រះសម្មាសម្ពុទ្ធ រាប់បាន ៨ អសង្ខេយ្យនិង ១ សែនកប្ប រួមការបំពេញបារមីទាំងអស់ ៤០ អសង្ខេយ្យនិង ១ សែនកប្ប។

**៣-វីរិយាធិក** បំពេញបារមីរួមទាំងអស់ ១៨ អសង្ខេយ្យ និង ១ សែនកប្ប កាលបំពេញបារមីហើយ នឹកនៅតែក្នុងព្រះហឫទ័យ ថានឹងបានជាព្រះពុទ្ធ មិនបានបញ្ចេញវាចា រាប់បាន ២៨ អសង្ខេយ្យ កាលបានបញ្ចេញវាចា ប្រាថ្នាជាព្រះពុទ្ធរហូតនឹងបានទទួលការណ៍ អំពីក្នុងសំណាក់នៃព្រះសម្មាសម្ពុទ្ធអង្គណាមួយរាប់បាន ៣៦ អសង្ខេយ្យ ចាប់ផ្ដើមពីបានទទួលការព្យាករក្នុងសំណាក់របស់ ព្រះសម្មាសម្ពុទ្ធអង្គណាមួយ ហើយថានឹងបានត្រាស់ជាព្រះពុទ្ធសម្មាសម្ពុទ្ធ រាប់បាន ១៦ អសង្ខេយ្យ និង ១សែនកប្ប រួមការបំពេញបារមីទាំងអស់ ៨០ អសង្ខេយ្យ និង ១ សែនកប្ប។

# បុញ្ញនិធិ

កូនៗទាំងឡាយចូរចាំថា បុញ្ញនិធិ នេះជាឈ្មោះមួយដ៏ល្អសម្រាប់កូនៗ គួរតែចាំទាំងអស់គ្នាព្រោះវាមានសារៈប្រយោជន៍ជាច្រើនសម្រាប់ខ្លួនរបស់កូន និងអ្នកដទៃផងណាកូន។

ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្ដែងថា **ឯស ទេវមនុស្សានំ សព្វកាម ទទោ និធិ យំ យំ ទេវាភិបត្ថេន្តិ សព្វមេតេន សព្ភតិ** កំណប់ទ្រព្យ គឺបុណ្យនេះឯងរមែងជួយឱ្យសព្វសត្វដែលប្រាថ្នាឱ្យបានដល់នូវភាពជាទេវតា និងមនុស្សទាំងឡាយ ទេវតានិងមនុស្សទាំងឡាយប្រាថ្នាផលណាៗក៏រមែងបានផលទាំងពួងនោះដោយបុញ្ញឫទ្ធិនេះ និធិ ប្រែថា កំណប់ទ្រព្យ តែក្នុងទីនេះសំដៅយក កំណប់ទ្រព្យ គឺបុណ្យកុសល ទើបហៅថាបុញ្ញនិធិ គឺបុញ្ញឫទ្ធិ ការបំពេញបុណ្យក្នុងព្រះពុទ្ធសាសនា មានការបរិច្ចាគទានដោយកុសលចេតនា មិនជាការសូន្យទទេ ប្រៀបបីដូចជាការកប់ទ្រព្យទុក ផលនៃការធ្វើនោះ នឹងហុចផលឱ្យក្នុងកាលដែលបានឱកាស កំណប់ទ្រព្យដែលពិត គឺការកប់ទ្រព្យទុកក្នុងផែនដីដើម្បីឱ្យផុតភ័យ ក៏ហៅថាកំណប់ទ្រព្យៗ ដែលផុសឡើងអំពីផែនដីដោយអានុភាពរបស់អ្នកឯណាមួយ ដូចជាទ្រព្យដែលកើតឡើងដើម្បីព្រះពោធិសត្វ កាលព្រះអង្គប្រសូតយ៉ាងនេះ ក៏ហៅថាកំណប់ទ្រព្យ ក្នុងសព្ទមគធៈលោកប្រើថា និធិ ទាំង

អស់។ម្យ៉ាងទៀតអំពើល្អកូនត្រូវតែចងចាំថា អំពើល្អតែងជួយមនុស្សដែលប្រព្រឹត្តល្អជានិច្ច មិនមែនអំពើល្អទៅជួយមនុស្សអាក្រក់នោះទេ ចូរគិតរឿងមួយថា ពេលវេលាមិនរង់ចាំមនុស្សយើងទេ ដូច្នេះមិនត្រូវប្រហែសខ្លួនឡើយណាកូនរបស់ម៉ែ។

**ធម្មតាដុំពពក ជាធម្មជាតិប្រែប្រួលលឿនឆាប់រហ័សណាស់ហើយវាមិននៅស្ងៀមមួយកន្លែងនោះឡើយ យ៉ាងណាមិញ ចិត្តរបស់មនុស្សយើងជាធម្មជាតិប្រែប្រួលលឿនណាស់ហើយតែងតែគិតទៅរកអារម្មណ៍ខាងក្រៅ ជានិច្ចក៏យ៉ាងនោះដែរ។**

# តួនាទីនីមួយៗក្នុងព្រះពុទ្ធសាសនា

តទៅនេះសូមកូនៗ អានតួនាទីនីមួយៗក្នុងព្រះពុទ្ធសាសនាដើម្បីជាប្រយោជន៍ទុកនៅក្នុងខ្លួនសម្រាប់យកទៅ ប្រតិបត្តិប្រចាំថ្ងៃផងដែរណ៎ាកូន។

សំខាន់ខ្លាំងណាស់ចំពោះតួនាទីនេះ ទោះជាកូននៅទីណាក៏ដោយ សុទ្ធតែមានកាបែងចែកតួនាទីនេះដែរ ប្រសិនបើយើងមិនបានបែងចែកការងារនោះទេ រមែងពិបាកធ្វើការងារហើយណាកូន តែនៅទីនេះឪមិនបានរៀបរាប់អំពីតួទីខាងផ្លូវលោកមកទេ ព្រោះកូនៗបានសិក្សាមកខ្លះហើយ ដូច្នេះសូមកូនយកចិត្តទុកដាក់ក្នុងការអានតួនាទីទាំងអស់នេះដោយសេចក្ដីគោរពចុះ.......

## តួនាទីរបស់មាតាបិតា ៥ យ៉ាង

១-ហាមមិនឱ្យកូនធ្វើសេចក្ដីអាក្រក់

២-ឱ្យកូនតាំងនៅក្នុងសេចក្ដីល្អ

៣-ឱ្យកូនសិក្សាសិល្បវិជ្ជាផ្សេងៗ

៤-រកភរិយាស្វាមីដែលសមគួរឱ្យកូន

៥-ប្រគល់ទ្រព្យឱ្យកូនក្នុងសម័យដ៏សមគួរ។

## តួនាទីរបស់បុត្តធីតា ៥ យ៉ាង

១-ត្រូវចិញ្ចឹមថែរក្សាមាតាបិតា

២-ត្រូវជួយធ្វើកិច្ចការរបស់មាតាបិតា

៣-តាំងរក្សាវង្សត្រកូលឱ្យល្អ

៤-ប្រព្រឹត្តខ្លួនឱ្យជាអ្នកគួរទទួលមត៌ក

៥-កាលមាតាបិតាអស់ជីវិតហើយគប្បីធ្វើបុណ្យឧទ្ទិសឱ្យលោក។

## តួនាទីរបស់អាចារ្យ(គ្រូ) ៥ យ៉ាង

១-ណែនាំសិស្សានុសិស្សឱ្យសិក្សាបានដោយល្អ

២-ឱ្យសិស្សរៀនដោយល្អ

៣-ប្រាប់សិល្បវិជ្ជាឱ្យអស់ដោយមិនមានការលាក់បិទបាំងទុក

៤-លើកតម្កើងឱ្យប្រាកដក្នុងពួកមិត្ត

៥-ធ្វើសេចក្តីការពារសិស្សគ្រប់ទិសទាំងឡាយ។

## តួនាទីរបស់សិស្ស ៥ យ៉ាង

១-លោកអញ្ជើញមកត្រូវក្រោកឈរទទួល

២-ចូលទៅឈរចាំទទួលបម្រើលោក

៣-ស្តាប់ពាក្យទូន្មានប្រៀនប្រដៅរបស់លោក

៤-បម្រើលោក

៥-រៀនសិល្បវិជ្ជាដោយគោរព។

## តួនាទីរបស់ស្វាមី ៥ យ៉ាង

១-លើកតម្កើងរាប់អានថាជាភរិយា

២-មិនមើលងាយប្រពន្ធ

៣-មិនប្រព្រឹត្តក្បត់ចិត្តប្រពន្ធ

៤-ប្រគល់ភាពជាធំឱ្យដល់ប្រពន្ធ

៥-ឱ្យគ្រឿងអលង្ការទៅដល់ប្រពន្ធ។

## តួនាទីរបស់ភរិយា ៥ យ៉ាង

១-ចាត់ចែងការងារឱ្យបានល្អ

២-សង្គ្រោះញាតិរបស់ស្វាមី

៣-មិនប្រព្រឹត្តក្បត់ចិត្តស្វាមី

៤-រក្សាទ្រព្យដែលស្វាមីរកបានមក

៥-ខំធ្វើកិច្ចការងារទាំងពួង។

## តួនាទីរបស់មិត្តអ្នកធ្វើឧបការៈមុន ៥ យ៉ាង

១-ចែកចាយរបស់

២-និយាយដោយពាក្យពីរោះ

៣-ប្រព្រឹត្តក្នុងអំពើដែលជាប្រយោជន៍

៤-ដោយភាពជាអ្នកមានខ្លួនស្មើ

៥-មិនពោលឱ្យឃ្លាតពីការពិត។

## តួនាទីរបស់មិត្តអ្នកធ្វើគប ៥ យ៉ាង

១-រក្សាមិត្តអ្នកដែលទ្វេសប្រហែសហើយ

២-រក្សាទ្រព្យរបស់មិត្តដែលទ្វេសប្រហែស

៣-កាលមានភ័យយកជាទីពឹងពំនាក់បាន

៤-មិនលះបង់ចោលមិត្តក្នុងពេលមានវិបត្តិ

៥-រាប់អានគ្នារហូតដល់វង្សត្រកូលរបស់មិត្ត។

## តួនាទីរបស់ចៅហ្វាយនាយ ៥ យ៉ាង

១-ឱ្យការងារសមគួរដល់កម្លាំង

២-ឱ្យអាហារនិងរង្វាន់លើកទឹកចិត្ត

៣-រក្សាព្យាបាលពេលមានជំងឺ

៤-ចែកអាហារមានរសប្រណីតឱ្យបរិភោគ

៥-អនុញ្ញាតឱ្យឈប់សម្រាក ដើរលេងក្នុងសម័យដ៏សមគួរ។

## តួនាទីរបស់អ្នកបម្រើ ៥ យ៉ាង

១-ក្រោកឡើងធ្វើការងារមុនចៅហ្វាយនាយ

២-ឈប់ធ្វើការងារក្រោយចៅហ្វាយនាយ

៣-កាន់យកតែរបស់ដែលចៅហ្វាយនាយឱ្យ

៤-ធ្វើការងារឱ្យល្អប្រសើរឡើង

៥-ពោលសរសើរគុណរបស់ចៅហ្វាយនាយ។

## តួនាទីរបស់សមណព្រាហ្មណ៍ ៥ យ៉ាង

១-ហាមមិនឱ្យកុលបុត្រធ្វើអំពើអាក្រក់

២-ញ៉ាំងកុលបុត្រឱ្យតាំងនៅក្នុងសេចក្ដីល្អ

៣-អនុគ្រោះកុលបុត្រដោយទឹកចិត្តដ៏ល្អ

៤-ឱ្យស្ដាប់នូវពាក្យដែលមិនធ្លាប់បានស្ដាប់ ឱ្យស្គាល់នូវរបស់ដែលមិនធ្លាប់បានស្គាល់ឱ្យជាក់ច្បាស់

៥-ប្រាប់ផ្លូវទៅកាន់ស្ថានសួគ៌។

## តួនាទីរបស់ពុទ្ធសាសនិកជន ៥ យ៉ាង

១-ធ្វើអ្វីដោយកាយដែលប្រកបដោយមេត្តា

២-និយាយអ្វីដោយវាចាដែលប្រកបដោយមេត្តា

៣-គិតអ្វីដោយមនោដែលប្រកបដោយមេត្តា

៤-មិនបិទទ្វារផ្ទះរបស់ខ្លួន (បានន័យថាត្រូវធ្វើទានជាមួយនឹងព្រះសង្ឃ....)។

៥-ប្រគេនរបស់ដែលសមគួរដល់ព្រះសង្ឃ។

តួនាទីទាំងអស់នេះ ប្រសិនបើកូនបានអានរាល់ថ្ងៃនោះរមែងរីកចម្រើនបញ្ញារបស់កូន និងបានយល់ព្រះធម៌ខ្លះៗដែរណាកូន ។

យើងបានកើតជាមនុស្សនេះជាការក្រណាស់ ដូច្នេះយើងត្រូវមានសីល ៥ (ឬហៅថានិច្ចសីល) ជាសីលដែលត្រូវមានជានិច្ចកាល។ មានពុទ្ធបរិស័ទភាគច្រើនជាអ្នកកាន់ព្រះពុទ្ធសាសនា តែមិនសូវបានចេះដឹងជម្រៅក្នុងព្រះពុទ្ធសាសនាទេ ហើយឪពុកនិយាយនេះមិនមែនឪពុក អ្នកចេះដឹងក្នុងព្រះពុទ្ធសាសនាច្បាស់នោះទេ គ្រាន់ជាអ្នកមានការសិក្សាចេះដឹងតិចតួចប៉ុណ្ណោះតទៅនេះសូមកូនពិចារណាសីល ៥ ក្នុងលោកនេះហើយពិចារណាថាបានជួយក្នុងសង្គមយ៉ាងណានោះ។

# សិក្ខាបទទាំង ៥ និងអត្ថមានដូចតទៅ

សិក្ខាបទ ៥ (បាលី បញ្ចសីលានិ,សំស្ក្រឹត បញ្ចសីលានិ) គឺជាសិក្ខាបទចាំបាច់របស់ពុទ្ធសាសនិកជន ដែលសមាទានដោយគ្រហស្ថ (ឧបាសក និងឧបាសិកា) ក្នុងសាសនាព្រះពុទ្ធសមណគោតម ក្នុងប្រពៃណី ថេរវាទ ហើយនិងប្រពៃណីមហាយានផងដែរ។ សិក្ខាបទនៃប្រពៃណីទាំងពីរនេះ មានសារៈសំខាន់ដូចគ្នា គឺការប្រកាន់យកកិរិយាវៀរចាកការសម្លាប់សត្វ វៀរចាកការលួចយកទ្រព្យគេ វៀរចាកការប្រព្រឹត្តខុសក្នុងកាម វៀរចាកការ ពោលនូវពាក្យកុហក វៀរចាកការសេពគ្រឿងស្រវឹង។ សមាទានសិក្ខាបទ ៥ គឺជាការប្រតិបត្តិដំបូង និងទៀងទាត់ប្រកបដោយវីរិយភាព នៃពុទ្ធសាសនិកដែលជាគ្រហស្ថ។ សិក្ខាបទ ៥ នេះ មិនតាំងឡើងដោយការបង្ខិតបង្ខំទេ ប៉ុន្តែជាក្បួនរៀន ធ្វើដោយស្ម័គ្រចិត្ត ដើម្បីសម្រួលការប្រតិបត្តិ សូមពុទ្ធបរិស័ទសិក្សា ទាំងព្រះបាលីទាំងភាសាខ្មែរដូចតទៅៈ

**១.បាណាតិបាតា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាធ្វើនូវសត្វមានជីវិតឱ្យធ្លាក់ចុះកន្លង គឺសម្លាប់សត្វ។

**២.អទិន្នាទានា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាកាន់យកនូវវត្ថុដែលគេមិនបានឱ្យដោយកាយឬដោយវាចា។

**៣.កាមេសុ មិច្ឆាចារា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាប្រព្រឹត្តខុសក្នុងកាមទាំងឡាយ។

**៤.មុសាវាទា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យកុហក។

**៥.សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាជាហេតុទីតាំងនៃសេចក្តីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ។

**១.បាណាតិបាត មានអង្គ ៥ គឺៈ**

| | |
|---|---|
| **១-បាណោ** | សត្វមានជីវិត |
| **២-បាណសញ្ញិតា** | សេចក្តីដឹងថាសត្វមានជីវិត |
| **៣-វធកចិត្តំ** | គិតនឹងសម្លាប់ |
| **៤-ឧបក្កមោ** | ព្យាយាមនឹងសម្លាប់ |

**៥-តេនមរណំ** សត្វស្លាប់ដោយព្យាយាមនោះ។

**២.អទិន្នាទាន មានអង្គ ៥ គឺ:**

**១-បរបរិគ្គហិតំ** ទ្រព្យដែលម្ចាស់គេហួងហែងរក្សា

**២-បរបរិគ្គតសញ្ញិតា** សេចក្តីដឹងថាទ្រព្យមានម្ចាស់

**៣-ថេយ្យចិត្តំ** ចិត្តគិតនឹងលួច

**៤-ឧបក្កមោ** ព្យាយាមនឹងលួច

**៥-តេន ហរណំ** លួចបានមកដោយព្យាយាមនោះ។

**៣.កាមេសុមិច្ឆាចារ មានអង្គ ៤ គឺ:**

**១-អគមនីយវត្ថី** ស្រ្តីដែលមានគេហួងហែងរក្សា

**២-តស្មឹ សេវនចិត្ត** គិតនឹងសេពមេថុនធម្មនឹងស្រ្តីនោះ

**៣-សេវនប្បយោគោ** ព្យាយាមនឹងសេពនូវមេថុនធម្ម

**៤-មគ្គេន មគ្គប្បដិបត្តិអធិវាសនំ** ញ៉ាំងមគ្គនិងមគ្គឱ្យដល់គ្នា

**៤.មុសាវាទ មានអង្គ ៤ គឺ:**

**១-អតថំវត្ថុ** វត្ថុមិនពិត

**២-វិសំវាទនចិត្តំ** គិតនឹងពោលឱ្យខុស

**៣-តជ្ជោវាយាមោ** ព្យាយាមនឹងពោលឱ្យខុស

**៤-បរស្សតទត្ថវិជាននំ** ញ៉ាំងអ្នកដទៃឱ្យដឹងច្បាស់នូវសេចក្តីនោះ

## ៥.សុរាមេរយ មានអង្គ ៤ គឺ:

**១-មជ្ជនីយវត្ថុ** វត្ថុជាទីតាំងនៃសេចក្តីស្រវឹងគឺសុរានិងមេរ័យ

**២-បាតុកម្យតាចិត្តំ** គិតបម្រុងនឹងផឹក

**៣-តជ្ជោវាយាមោ** ព្យាយាមនឹងផឹកនូវទឹកស្រវឹងនោះ

**៤-តស្សបានំ** បានផឹកទឹកស្រវឹងនោះឱ្យកន្លងបំពង់កចូលទៅ។

ក្នុងសិក្ខាបទនីមួយៗ មានអង្គរបស់វាកាលណាបើយើងប្រព្រឹត្តគ្រប់អង្គនៅក្នុងសិក្ខបទណាមួយហើយទើបឱ្យឈ្មោះថាដាច់សិក្ខាបទ តែមិនមែនដាច់រហូតនោះទេ បើយើងបានដឹងខ្លួនថាដាច់ហើយត្រូវតែសមាទានភ្លាម នោះសិក្ខាបទយើងនឹងឡើងដូចដើមវិញ តើកូនអាចធ្វើបានទេមើលទៅ? ក្នុងសង្គមយើងប្រសិនបើយើងមាននូវសីល ៥ យើងនឹងរស់នៅដោយសន្តិភាពមិនមាននូវអំពើហិង្សា មិនមានការលួចប្លន់គ្នា មិនមានការប្រព្រឹត្តខុសក្នុងប្រពន្ធកូនអ្នកដទៃ មិនមានពាក្យចាក់ដោតគ្នា មិនមាននូវការសម្លាប់គ្នា ជីវិតរស់បានយ៉ាងមានសុភមង្គលជារៀងរហូត។

# សុជីវធម៌

កូនៗទាំងឡាយ រស់នៅក្នុងសង្គមត្រូវតែមានសុជីវធម៌ ព្រោះសង្គមត្រូវការមនុស្សបែបនេះច្រើនណាស់ណាកូន។

ព្រោះយើងរស់នៅក្នុងសង្គម ត្រូវតែមានចំណេះដឹងសណ្តាប់ធ្នាប់ការដឹងប្រមាណ ចេះគួរសមក្នុងកិច្ចការប្រាស្រ័យជាមួយអ្នកដទៃផងគ្នា បើយើងមិនមានសុជីវធម៌ទេ មិនថាយើងរៀនដល់កម្រិតណានោះទេ វាដូចជាអ្នកអត់បានរៀនអ៊ីចឹងណាកូន។ ដូចជាការនិយាយស្តីត្រូវតែសុភាពរាបសាជានិច្ច មិនត្រូវពោលពាក្យអាក្រក់នោះឡើយ ពេលដែលកូនចូលក្នុងវត្តអារាមជាកន្លែងសក្ការបូជា ជាទីគោរព កូនមិនត្រូវសម្តែងកិរិយាមិនគប្បីសោះឡើយ អ្នកជិះកង់ ម៉ូតូ កុំលឿនពេកមានការបន្ថយល្បឿនខ្លះផង បើកូនអាចចុះបណ្តើរបានរឹតតែប្រសើរ វាមិនជាយូរប៉ុន្មានទេត្រឹមតែចម្ងាយក្នុងវត្តប៉ុណ្ណឹងណាកូនរបស់ម៉ែ។

យើងជានារី ត្រូវចេះសង្រួមពេលចូលមកក្នុងវត្តអារាមណាកូនរបស់ម៉ែ ដូចជាការនិយាយស្តីកូនត្រូវពិចារណាផងណាកូន ពេលយើងនិយាយខ្លាចប៉ះពាល់ដល់អ្នកដែលគេកំពុងស្តាប់ កូននិយាយត្រូវនិយាយសំឡេងកុំឮពេកក្រែងគេនិយាយដើមណាកូន។ មួយទៀតចូរកូនកុំធ្វើជាមនុស្សរឹងរូស ត្រូវជាមនុស្សរឹងប៉ឹង មិនត្រូវធ្វើជាមនុស្សទន់ជ្រាយ ត្រូវធ្វើជាមនុស្ស

ទន់ភ្លន់ជានិច្ច ព្រោះកូនម៉ែរឹតតែទន់ភ្លន់រឹតតែល្អណាកូន ពេលដែលប្រុសៗគេឃើញកូនភ្លាម គេរមែងមើលកូនគ្រប់ទីកន្លែងទាំងអស់ណាកូន ពេលដែលគេថាស្រឡាញ់កូននោះគេមើលឃើងអស់ហើយណាកូន ដូចជាការស្លៀកពាក់របស់កូនជាដើម បើកូនធ្វើជាមនុស្សឆើតឆាយគេស្រឡាញ់កូនត្រឹមបោកប្រាស់ប៉ុណ្ណោះណា កូនស្រីម៉ែត្រូវតែប្រុងប្រយ័ត្នឱ្យមែនទែនព្រោះមនុស្សប្រុសថ្វីត្បិតតែថា ស្រឡាញ់កូនពិតមែនតែគេរើសណាស់ណាកូនស្រី ធម្មតាគេឃើញរូបកូនស្លៀកពាក់ឆើតឆាយចេះតែថាស្រឡាញ់ឱ្យរួចពីមាត់របស់គេទៅ មើលទៅកូនប្រហែលបានត្រឹមតែត្រូវគេបោកប្រាស់តែប៉ុណ្ណោះណាកូន តែបើកូនសុភាពរាបសាវិញនោះល្អណាស់កូន ព្រោះគេឃើញរូបកូន គេមិនហ៊ាននិយាយមើលងាយកូនឡើយ ព្រោះពួកប្រុសៗទាំងអស់ខ្លាចស្ត្រីណាដែលមានចរិតសុភាពរាបសាណាកូន។ ពេលកូនធ្វើខ្លួនសុភាពរាបសាកុំភ័យខ្លាចអត់ប្ដីឱ្យសោះណាកូន មនុស្សល្អរមែងជួបនឹងមនុស្សល្អ។

# ស្ត្រី ៤ ពួក

១-ស្ត្រីពួកខ្លះក្នុងលោកនេះ ជាអ្នកមានរូបអាក្រក់ខ្មៅ មិនគួរមើល ទាំងជាអ្នកខ្សត់ខ្សោយទ្រព្យសម្បត្តិ ហើយជាអ្នកមានស័ក្តិទាប គឺជាអ្នកមិនមានយសស័ក្តិព្រោះហេតុដូច្នេះ ជាអ្នកមានសេចក្តីក្រោធច្រើន ជាអ្នកមិនបរិច្ចាគទាន ជាអ្នកមានចិត្តច្រណែន។

២-ស្ត្រីពួកខ្លះក្នុងលោកនេះ ជាអ្នកមានរូបអាក្រក់មិនគួរមើល តែជាអ្នកមានទ្រព្យសម្បត្តិច្រើន ហើយជាអ្នកមានស័ក្តិខ្ពស់ (គឺមានទាំងយសមានទាំងស័ក្តិ) ព្រោះហេតុនេះឯង ទាំងនេះគឺជាអ្នកមានសេចក្តីក្រោធច្រើន ជាអ្នកបរិច្ចាគទាន ជាមនុស្សមិនមានចិត្តច្រណែន។

៣-ស្ត្រីពួកខ្លះក្នុងលោកនេះ ជាអ្នកមានរូបស្អាតគួរមើល គួរសរសើរ គួរប្រកបមានសណ្ឋានរូបរាង និងពណ៌សម្បុរស្រស់ស្អាត តែជាអ្នកមានទ្រព្យសម្បត្តិខ្សត់ខ្សោយជាអ្នកមានស័ក្តិទាប (គឺមិនមានយសមិនមានស័ក្តិ) ដូចនេះ ព្រោះហេតុទាំងនេះ គឺជាអ្នកមិនមានសេចក្តីក្រោធ ជាអ្នកកំណាញ់ មិនបរិច្ចាគទាន ទាំងជាអ្នកមានចិត្តច្រណែន។

៤-ស្ត្រីពួកខ្លះក្នុងលោកនេះ ជាអ្នកមានរូបស្អាតគួរមើល គួរសរសើរ ដែលប្រកបដោយទ្រង់ទ្រាយ និងពណ៌សម្បុរស្រស់ស្អាត ទាំងជាអ្នកមានធនធានទ្រព្យសម្បត្តិច្រើន ទាំងជាអ្នកមានស័ក្តិខ្ពស់ (មានទាំងយសមាន

ទាំងស័ក្តិ) ដូចនេះព្រោះហេតុទាំងនេះ គឺជាអ្នកមិនមានសេចក្តីក្រោធ ជាអ្នកបរិច្ចាគទាន ជាអ្នកមិនមានចិត្តច្រណែន។

# ស្ត្រីចូលទៅកាន់ត្រកូលស្វាមីមាន ៥ យ៉ាង

កូនៗទាំងឡាយ ខ្លួនយើងជាស្រីដែលមានគូស្រករ ពោលគឺមានស្វាមីហើយ ត្រូវមានការរស់នៅបែកពីពុកម៉ែ ដូច្នេះកូនរស់នៅជាមួយប្តីត្រូវតែមានសេចក្តីអត់ធ្មត់ឱ្យបានច្រើនផងណាកូន។

នៅពេលនេះ ពុកម៉ែសូមផ្តាំផ្ញើពាក្យពេចន៍ខ្លះៗ ពេលដែលកូនត្រូវឃ្លាតទៅរស់នៅខាងស្វាមីណាកូនម៉ែ ធម្មតាចានដែលនៅក្នុងរាវ រមែងប៉ះទង្គិចគ្នាមិនខាន សំខាន់ជាងនេះទៅទៀត ពេលដែលកូនត្រូវទៅរស់នៅខាងស្វាមី ចូរកូនស្រីម៉ែរក្សាធម៌ទាំង ៥ នេះឱ្យជាប់ណាកូន។

១-ពេលដែលកូនចូលដំណេក ត្រូវដេកក្រោយស្វាមី ឬឪពុកម្តាយខាងស្វាមី តែកូនត្រូវភ្ញាក់មុនពួកគាត់ និងត្រូវបម្រើ យកចិត្តទុកដាក់ជាមួយពួកគាត់ ចេះប្រើពាក្យសម្តីគួរជាទីស្រឡាញ់។

២-ជនណាជាទីគោរពរបស់ភស្តា ដូចជាមាតាបិតា សមណព្រាហ្មណ៍យើងត្រូវធ្វើសក្ការៈគោរពសំពះបូជាបុគ្គលនោះ ស្វាគមន៍អ្នកដែលមកផ្ទះដោយការឱ្យនូវទីកន្លែងអង្គុយ និងទឹកជាដើម។

៣-ការងារជាការងារក្នុងផ្ទះស្វាមី កូនត្រូវយកចិត្តទុកដាក់ធ្វើឱ្យបានល្អជានិច្ចមិនត្រូវធ្វេសប្រហែសឡើយ កូនត្រូវឆ្លាតឈ្លាសក្នុងកិច្ចការងារ។

៤-មនុស្សខាងក្នុងរបស់ស្វាមី ដូចជាទាសៈអ្នកបម្រើ ឬកូនជាងយើង ត្រូវដឹងអ្វីៗ ដែលគេធ្វើហើយ និងអ្វីដែលមិនទាន់ធ្វើ ត្រូវដឹងអាការៈឈឺ ឬជារបស់អ្នកទាំងនោះត្រូវចែករបស់ទទួលទានឱ្យដល់ពួកគេ តាមចំណែកដែលគេគួរទទួលបាន។

៥-ទ្រព្យអ្វីៗ ដែលស្វាមីរកបានមកជាទ្រព្យ ឬមាសប្រាក់ យើងត្រូវឃុំគ្រងការពារទ្រព្យទាំងនោះ ទាំងជាអ្នកមិនលេងល្បែងភ្នាល់ ឆក់លួច មិនជាអ្នកផឹកស្រា មិនបំផ្លាញទ្រព្យសម្បត្តិ។

បើរូបកូន បានកាន់ជាប់នូវគោលការណ៍ទាំង ៥ យ៉ាងនេះហើយ ប្រាកដជាមានសេចក្ដីសុខក្នុងគ្រួសាររបស់កូនជានិច្ចណាកូនស្រីម៉ែ ប៉ុណ្ណឹងចុះពេលនេះរូបកូនបានយល់នូវសេចក្ដីដែលបានប្រាប់ពីថ្ងៃមុន ខ្លះហើយមើលទៅ។

សូមកូនចងចាំថា សេចក្ដីសុខរបស់គ្រួសារកូន មិនអាចនរណាម្នាក់ធ្វើឱ្យបានឡើយ ក្រៅអំពីរូបកូនចេះយោគយល់គ្នាទៅវិញទៅមកនោះណាកូន។

# នារីគ្រប់លក្ខណ៍

យើងជាស្រីណាកូន ត្រូវតែសុភាពរាបសាជានិច្ចដើម្បីលើកតម្កើងសង្គមរបស់យើង ដែលដូនតារបស់យើងខំរក្សាទុកជាយូរមកហើយជាប្រពៃណីដែលល្អសម្រាប់បន្សល់ឱ្យកូនស្រីប្រុសជាអ្នកថែរក្សា។

នារី ដែលប្រកបដោយលក្ខណៈ ៣១ ប្រការហៅថា ស្ត្រីគ្រប់លក្ខណ៍ គឺមិនចេះអេចអូចនិយាយដើមគេ ១ ចេះគួរសមទទួលមាតាបិតា និងស្វាមី ១ ដឹងគុណ តបគុណមាតាបិតាញាតិសន្តានទាំងសងខាង ១ មិនចេះដេកថ្ងៃ ១ មិនវង្វេងភ្លេចមុខភ្លេចក្រោយ ១ ចេះថៃទាំរបស់ទ្រព្យ ១ មិនផិតក្បត់ចិត្តស្វាមី ១ មិនចេះប្រចណ្ឌស្វាមី ១ គ្មានកលមាយា ១ មិនរំសាយសក់ឱ្យគេឃើញ ១ មានចិត្តអត់ធន់ធ្ងន់ធ្ងរ ១ មានជើងស្រាលមិនតន្ត្រំក្តុងក្តាំង ១ មិនឈរ ឬអង្គុយសម្ងាចកាយឱ្យគេឃើញ ១ មិនដើរកាច់រាង ១ ចេះសង្រួមភ្នែកមិនក្រឡេមក្រឡឹម ១ មានដំណើរល្អមិនគ្រលែងកាយទយគួទ ១ មិនបង់បោយញាក់ស្មាគ្រលែងជើងដៃ ១ មានសំឡេងតិចច្បាស់លាស់ ១ មិនចេះឡេះឡោះលេងសើច ១ មិននិយាយផ្តោះផ្តងចំពោះបុរស១ មិនទម្រន់ក្នុងការងារ ធ្វើទាល់តែហើយការងារនោះ ១ ទៅណាឆាប់ត្រឡប់មកវិញ ១ ចេះទុកដាក់អីវ៉ាន់ក្នុងពេលគួរទុកដាក់ ១ ចេះរៀបចំផ្ទះសំបែងឱ្យសមរម្យ ១ ចេះតុបតែងគ្រឿងឧបភោគបរិភោគ ១ ខ្លាច

ចិត្តស្វាមីមាតាបិតា ហើយគោរពតាមឱវាទ ១ បរិភោគចំណីអាហារក្រោយ មាតាបិតានិងស្វាមី ១ ឈប់បរិភោគ មុនមាតាបិតានិងស្វាមី ១ ចូលដេក ក្រោយស្វាមី ១ ភ្ញាក់មុនស្វាមី ១ មានមេត្តាករុណាចេះធ្វើបុណ្យ ទាន ១ ។ ស្ត្រីដែលប្រកបដោយលក្ខណៈគ្រប់ពេញលេញហៅថាស្ត្រីគ្រប់លក្ខណ៍។ លក្ខណៈស្ត្រីគ្រប់លក្ខណ៍ដូចខាងលើនេះ បើតាមសម័យបច្ចុប្បន្ននេះ ឃើញថា លក្ខណៈខ្លះហួសសម័យទៅហើយ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ បើស្ត្រីណាប្រកបដោយលក្ខណៈដូចបាននិយាយ គោលៗក្នុងទីនេះ ស្ត្រីនោះគួររាប់ថាជាមនុស្សស្រីគ្រប់លក្ខណ៍បានដោយបរិបូណ៌។

**នារីដែលល្អ គឺមានចរិយាល្អ មានគំនិតល្អ មានចំណេះវិជ្ជាល្អ ទើបជានារីឆ្លាតមិនចាញ់បោកពួកប្រុសៗដោយងាយ។**

# មង្គលជីវិត

ពេលដែលយើងធ្វើអ្វីមួយ តែងតែចង់បាននូវផលប្រយោជន៍ខ្លួនឯង ក្នុងការដែលខំប្រឹងប្រែងធ្វើនូវការងារទាំងអស់នោះ មិនថាតិចឬក៏ច្រើនឡើយ ឱ្យតែផលប្រយោជន៍ដែលខ្លួនបានធ្វើ។

ចំណែកក្នុងផលប្រយោជន៍ ដែលខ្លួនប្រព្រឹត្តទៀតសោត វាមានផល ២ យ៉ាង គឺផលល្អ និងផលអាក្រក់ ទាំងនេះហើយដែលកូនត្រូវសិក្សាអំពីសេចក្តីល្អរបស់ខ្លួនឯងឱ្យបានច្រើន។ មួយទៀតមានមនុស្សមិនតិចនាក់ទេកូន ដែលស្វែងរកនូវមង្គលតែមិនដឹងធ្វើយ៉ាងណានោះចេះតែដើររកគ្រប់ទីកន្លែង រហូតមានមនុស្សមួយចំនួនទៀត ដោយអំណាចចង់តែបាននូវសេចក្តីសុខផ្ទាល់ខ្លួន ត្រូវចាញ់បោកគេក៏មានដែរ។

តែមង្គលដែលនាំឱ្យយើងមានសេចក្តីសុខពិតប្រាកដនោះ គឺមិនចាំបាច់រកនៅទីណានោះទេ វាស្ថិតនៅតែជាមួយខ្លួនយើងហ្នឹងឯងណាកូន ម៉ែមានរឿងមួយទៀតឱ្យកូនបានដឹង នូវមង្គលទាំង ៣៨ ប្រការដែលនាំមកនូវសេចក្តីសុខពិតប្រាកដ និងមានផលច្រើនទៀតផង សូមកូនសិក្សាមង្គលពិតប្រាកដដូចតទៅ....

**១-អសេវនា ច ពាលានំ** កិរិយាមិនសេពគប់នូវបុគ្គលពាលទាំងឡាយ

**២-បណ្ឌិតានញ្ច សេវនា** កិរិយាសេពគប់នូវបុគ្គលជាបណ្ឌិតទាំងឡាយ

**៣-បូជា ច បូជនីយានំ** កិរិយាបូជាដល់បុគ្គលដែលគួរបូជាទាំងឡាយ

**៤-បដិរូបទេសវាសោ ច** កិរិយានៅក្នុងប្រទេសដ៏សមគួរ

**៥-បុព្វេ កតបុញ្ញតា** ភាវៈនៃបុគ្គលបានធ្វើបុណ្យទុកហើយក្នុងកាលមុន

**៦-អត្តសម្មាបណិធិ ច** កិរិយាតម្កល់ខ្លួនដោយប្រពៃ

**៧-ពាហុសច្ចញ្ច** ភាវៈនៃបុគ្គលបានស្តាប់ បានរៀនហើយដោយច្រើន

**៨-សិប្បញ្ច** សិល្បសាស្ត្រ គឺសេចក្តីឆ្លៀវឆ្លាសក្នុងហត្ថកម្មរបស់អ្នកបួស និងគ្រហស្ថ

**៩-វិនយោ ច សុសិក្ខិតោ** វិន័យដែលបុគ្គលសិក្សាដោយប្រពៃ

**១០-សុភាសិតា ច យា វាចា** វាចាដែលបុគ្គលពោលត្រឹមត្រូវ

**១១-មាតា ឧបដ្ឋានំ** កិរិយាបម្រើនូវមាតា

**១២-បិតុ ឧបដ្ឋានំ** កិរិយាបម្រើនូវបិតា

**១៣-បុត្តទារស្ស សង្គហោ** សេចក្តីសង្គ្រោះដល់បុត្រ និងភរិយា

**១៤-អនាកុលា ច កម្មន្តា** ការងារទាំងឡាយដែលមិនច្របូកច្របល់

**១៥-ទានញ្ច** កិរិយាបរិច្ចាគទាន

**១៦-ធម្មចរិយា** កិរិយាប្រព្រឹត្តនូវធម៌

**១៧-ញាតកានញ្ច សង្គហោ** សេចក្ដីសង្គ្រោះដល់ញាតិទាំងឡាយ

**១៨-អនវជ្ជានិ កម្មានិ** ការងារទាំងឡាយដែលមិនមានទោស

**១៩-អារតី វិរតី បាបា** កិរិយាមិនត្រេកអរក្នុងបាប និងកិរិយាវៀរចាកបាប

**២០-មជ្ជបានា ច សញ្ញមោ** សេចក្ដីសង្រួមចាកកិរិយាផឹកនូវទឹកស្រវឹង

**២១-អប្បមាទោ ច ធម្មេសុ** សេចក្ដីមិនប្រមាទក្នុងធម៌ទាំងឡាយ

**២២-គារវោ ច** សេចក្ដីគោរពចំពោះបុគ្គលដែលគួរគោរព

**២៣-និវាតោ ច** កិរិយាប្រព្រឹត្តបន្ទាបខ្លួន

**២៤-សន្តុដ្ឋិ ច** សេចក្ដីត្រេកអរចំពោះរបស់ដែលមាន

**២៥-កតញ្ញុតា** ភាវៈនៃបុគ្គលអ្នកដឹងនូវឧបការៈដែលបុគ្គលដទៃធ្វើហើយដល់ខ្លួន

**២៦-កាលេន ធម្មស្សវនំ** កិរិយាស្តាប់នូវធម៌តាមកាល

**២៧-ខន្តិ ច** សេចក្តីអត់ធន់

**២៨-សោវចស្សតា** ភាវៈនៃបុគ្គលដែលគេប្រដៅបានដោយងាយ

**២៩-សមណានញ្ច ទស្សនំ** កិរិយាបានឃើញ បានជួបនូវសមណៈទាំងឡាយ

**៣០-កាលេន ធម្មសាកច្ឆា ធម្មសាកច្ឆា** គឺកិរិយាសន្ទនាទៅវិញទៅមកនូវធម៌តាមកាល

**៣១-តបោ ច** សេចក្តីព្យាយាមដុតនូវបាបធម៌

**៣២-ព្រហ្មចរិយញ្ច** កិរិយាប្រព្រឹត្តនូវធម៌ដ៏ប្រសើរ

**៣៣-អរិយសច្ចាន ទស្សនំ** កិរិយាឃើញនូវអរិយសច្ចទាំងឡាយ

**៣៤-និព្វានសច្ឆិកិរិយា ច** កិរិយាធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាន

**៣៥-ផុដ្ឋស្ស លោកធម្មេហិ ចិត្តំ យស្ស ន កម្បតិ** ចិត្តរបស់បុគ្គលឯណាដែលលោកធម៌ទាំងឡាយពាល់ត្រូវហើយមិនរំភើបញាប់ញ័រ

**៣៦-អសោកំ** មិនមានសេចក្តីសោក

**៣៧-វិរជំ** មានធូលី គឺរាគៈទៅប្រាសហើយ

**៣៨-ខេមំ** ជាចិត្តក្សេមក្សាន្ត។

មង្គលទាំង ៣៨ ប្រការនេះហើយដែលធ្វើឱ្យអ្នកប្រព្រឹត្តបាននូវសេចក្តីសុខយ៉ាងពិតប្រាកដណាកូន មិនថាយើងរស់នៅកន្លែងណាទេឱ្យតែ

ចេះសាងនូវមង្គលទាំងអស់នេះហើយរមែងបានសេចក្តីសុខពិតប្រាកដ និង
មានផលច្រើនទៀតផង។

# ឃរាវាសធម៌

ឃរាវាសធម៌ គឺជាធម៌មួយសម្រាប់ការរស់នៅគ្រប់គ្រងក្នុងផ្ទះដែលត្រូវប្រតិបត្តិទាំងអស់គ្នាមិនថាក្មេង មិនថាចាស់នោះឡើយ គឺត្រូវរក្សាទើបល្អក្នុងគ្រួសារណាកូន។

សូមកូនយកចិត្តទុកដាក់អានខាងក្រោមនេះ........

**១-សច្ចៈ** សេចក្តីទៀងត្រង់ដល់គ្នា នឹងគ្នា

**២-ទមៈ** ទូន្មានចិត្តឱ្យទន់ភ្លន់

**៣-ខន្តី** អត់ធន់គ្រប់យ៉ាង ក្នុងភារកិច្ចគ្រប់មុខ

**៤-ចាគៈ** លះបង់ទ្រព្យសម្បត្តិដល់អ្នកដទៃដែលគួរឱ្យ។

កូនៗ ទាំងឡាយដែលជាអ្នកគ្រប់គ្រងផ្ទះសម្បែង តែងតែមានភរិយាស្វាមី ហើយត្រូវមានការរស់នៅបែកពីម៉ែហើយ និងមានសមាជិកគ្រួសាររៀងៗខ្លួន។ សមាជិកទាំងនោះតែងមានអត្តចរិតផ្សេងៗគ្នា ហើយណាកូនទោះបីអ្នកទាំងនោះមានឈាមជ័រតែមួយក៏ដោយ។ តែខ្លះមាននិស្ស័យខុសគ្នាណាកូន មានអ្នកខ្លះចូលចិត្តតែសប្បាយហើយនិយាយច្រើន ខ្លះចូលចិត្តកំប្លែងលេងក្រមាច់ក្រមើម ខ្លះចំណូលខាងភូតភរកុហកគេ កុហកឯង ប្រើល្បិចគ្រប់យ៉ាង ខ្លះទៀតជាមនុស្សស្មោះត្រង់ ទៀងត្រង់ហើយប្រាថ្នាតិចចូលចិត្តការស្ងប់ស្ងាត់ មិនចង់បានមានអ្វីឱ្យហួសហេតុដែលផ្ទុយពីចរិយា

សម្បត្តិរបស់មាតាបិតាឡើយណាកូន។ ដោយហេតុមនុស្សដែលកើតក្នុងគ្រួសារតែមួយ ហើយមានអធ្យាស្រ័យ និងលក្ខណៈផ្សេងៗពីគ្នា តាមការប្រព្រឹត្ត ការយល់ឃើញផ្ទាល់ខ្លួនម្នាក់ៗដូច្នោះហើយបានជាព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងអំពីសច្ចធម៌នេះ ថាជាធម៌សម្រាប់ទំនាក់ទំនងគ្នា ល្អវិសេសអាចបង្កើតសាមគ្គីភាពក្នុងគ្រួសារនីមួយៗបាន។

បើគ្រួសារយើង បានតាំងនៅស្ថបមាំក្នុងសច្ចធម៌ គឺសេចក្តីទៀងត្រង់រវាងគ្នានឹងគ្នាហើយក៏តោងមានទមធម៌ គឺការទូន្មានចិត្តឱ្យបានល្អ ដែលគេហៅថាលត់ដំធ្វើចិត្តឱ្យស្ងប់ស្ងាត់ ទន់ភ្លន់កុំឱ្យមានការក្រេវក្រោធ រំលោភលើគ្នាថែមទៀត ។ គឺជាសភាវៈតែងតែត្រិះរិះនូវអារម្មណ៍ផ្សេងៗ មិនឈប់ឈរ តែងតែរំភើបញាប់ញ័រពិបាកនឹងការពារ ឬទប់ទល់ឱ្យនៅនឹងមួយកន្លែងបាន ។ អ្នកប្រាជ្ញបានពោលថា បុគ្គលណា បានទូន្មានចិត្តឱ្យល្អប្រពៃហើយ បុគ្គលនោះឈ្មោះថាបានសេចក្តីសុខ ដែលជាចំណង់ធំបំផុតរបស់មនុស្សលោក ។ ពិតមែនតែចិត្តជាអរូបីយើងមិនអាចមើលឃើញដោយចក្ខុទេ តែវាអាចបង្គាប់បញ្ជាលើរូបរាងកាយទាំងមូលបាន។ យ៉ាងនេះហើយបានជាព្រះសាស្តាប្រដៅសត្វលោក ឱ្យអប់រំចិត្ត ឱ្យមានសភាពទន់ភ្លន់ល្អឱ្យវៀរចាកអកុសលទាំងពួងមានការប្រព្រឹត្តអាក្រក់ ដោយកាយឬវាចាជាដើម ទៅលើមនុស្សសត្វដែលនៅជុំវិញខ្លួនយើង។ ចិត្តនេះទោះបីរឹងប៉ឹងរឹងរូសដូចម្តេចក្តីក៏គេអាចទូន្មាន ឬអប់រំឱ្យបានល្អដែរ មិនខុសពីជាងធ្នូពត់តម្រង់កូនសរឱ្យត្រង់ដែលអាចបាញ់ចំគោលដៅ ក្នុងទិសទាំងបួនដូចសេចក្តីប្រាថ្នាបាន។ បើលំអិតចិត្តបានហើយ ទើបបំពេញកិច្ចការឲ្យ

សម្រេចបាន ក៏អាស្រ័យទៅលើការធ្វើ ដោយសេចក្តីព្យាយាម និងសេចក្តីអត់ធន់ ដែលលោកហៅថាខន្តីគឺការអំណត់តស៊ូ ធ្វើមិនខ្លាចនឿយលំបាកគ្រប់យ៉ាងក្នុង ការបំពេញកិច្ចការនោះៗ។ ការងារទាំងឡាយមិនអាចសម្រេចដោយឯងៗ ដោយគ្រាន់តែគិត ឬនឹកចង់នោះទេលុះត្រាតែធ្វើហើយអំណត់ទៀតទើបសម្រេច។ ខន្តីលោកចាត់ជាតបធម៌ដ៏ខ្ពង់ខ្ពស់ក្រៃលែង សម្រាប់កម្ចាត់អកុសលធម៌ទាំងឡាយ មានហិង្សាជាដើម និងជាអលង្ការដ៏ប្រសើររបស់បុរសស្រ្តីផង។ កាលបើមានអំណត់អត់ឱនចំពោះគ្នានឹងគ្នាហើយ ក៏ត្រូវមានការចែកចាយទ្រព្យសម្បត្តិរបស់ខ្លួនតទៅទៀតដែលលោកហៅថាចាគៈនេះឯង ។ ចាគៈគឺជាការលះបង់ភាពកំណាញ់ហើយយកទ្រព្យសម្បត្តិឱ្យទៅជាទាន ដល់អ្នកដែលគួរនឹងឱ្យ ពីព្រោះគ្រហស្ថត្រូវបែងចែកសម្បត្តិរបស់ខ្លួនជា ៥ ផ្នែកគឺៈ

១-ចិញ្ចឹមខ្លួន និងមាតាបិតាបុត្រភរិយាទាសៈកម្មករឱ្យបានសេចក្តីសុខទើបប្រសើរ

២-ទំនុកបម្រុងកល្យាណមិត្តឱ្យបានល្អ

៣-កម្ចាត់អន្តរាយដែលកើតមកអំពីភ័យផ្សេងៗ

៤-ឱ្យទានដល់សមណព្រាហ្មណ៍ដែលប្រព្រឹត្តល្អ

អ្នកស្វែងរកទ្រព្យសម្បត្តិបានមកដោយផ្លូវល្អ ផ្លូវសុចរិតហើយ គួរតែចេះកាន់យកនូវប្រយោជន៍នៃទ្រព្យនោះឱ្យបាន មិនត្រូវទុកទ្រព្យឱ្យនៅទំនេរទេ។ បុគ្គលណាចាយវាយប្រើប្រាស់ទ្រព្យសម្បត្តិចិញ្ចឹមខ្លួន និងមាតា

បិតាជាដើម បុគ្គលនោះឈ្មោះថា កាន់យកនូវប្រយោជន៍នៃទ្រព្យនោះទុកបាន។ ប្រើប្រាស់ទ្រព្យសម្បត្តិក្នុងផ្លូវឥតប្រយោជន៍ ដូចជាលេងល្បែងភ្នាល់ និងផ្គាប់ផ្គុនស្រីជាដើម ឈ្មោះថាមិនបានកាន់យកនូវប្រយោជន៍នៃទ្រព្យសម្បត្តិនោះឡើយ។

ចិញ្ចឹមមិត្តសម្លាញ់ឱ្យបានសុខ គឺថាយើងរើសយកតែកល្យាណមិត្ត ឯបាបមិត្ត យើងមិនត្រូវចែកចាយឱ្យទេ ត្បិតអីអសេវនធម៌ជារឿងធំ បំផុតនៃជីវិតមនុស្សយើងសូម្បីតែព្រះពុទ្ធជាម្ចាស់សម្ដែងក្នុងមង្គលសូត្រ ៣៨ ប្រការក៏ ចាប់យកការសេពគប់ជាមុនដែរ ដូចបទថា **អសេវនា ច ពាលានំ បណ្ឌិតានញ្ច សេវនា** ជាដើមមានសេចក្ដីថា ចូរអ្នកកុំសេពគប់នឹងមនុស្សពាល ឱ្យសេពគប់តែបណ្ឌិតទើបសន្មតថា ជាមង្គលគឺសេចក្ដីចម្រើន។ ហេតុនេះ បានជាព្រះអង្គឱ្យសង្គ្រោះតែមិត្តល្អៗ ដែលអាចពឹងពាក់ ឬជួយធុរៈយើងគ្រប់គ្រាក្នុងគ្រាក្រ។

ចំណាយទ្រព្យសម្បត្តិ កម្ចាត់អន្តរាយដែលកើតពីហេតុផ្សេងៗ នោះគឺបំបាត់អន្តរាយដែលកើតអំពីភ័យគ្រប់យ៉ាងមានភ្លើងឆេះ ចោរភ័យ ភ័យអំពីចោរលួច ឧទកភ័យ ភ័យអំពីទឹកលិចជាដើម ដោយកម្លាំងទ្រព្យដែលអាចចាត់វិធានការ ការពារឱ្យបានល្អ មិនឱ្យកើតឡើងបាន។

កូនត្រូវជួយសង្គ្រោះញាតិ ទៅតាមលំដាប់ថ្នាក់នៃជួរទាំងសងខាងដែលហៅថាញាតិពលី ត្រូវចេះធ្វើបុណ្យឧទ្ទិសផលដល់បុព្វបុរស

ទាំងឡាយ មានមាតាជាដើម ដែលចែកស្ថានទៅកាន់បរលោក ហៅថា បុព្វបេតពលី ត្រូវតែធ្វើវិធានការបង់ពន្ធដារជូនរដ្ឋ តាមប្រពៃណីនៃច្បាប់ប្រទេសនីមួយៗ ហៅថា រាជពលី។

ទេវតាដែលជាសម្មាទិដ្ឋិរក្សាគ្រប់គ្រងលោកធាតុទាំងមូល ឱ្យតាំងនៅដោយសេចក្ដីសុខគ្រប់កន្លែង អ្នកម្ចាស់ទីកន្លែងកូនត្រូវតែធ្វើបុណ្យឧទ្ទិសផលឱ្យតាមគតិនិយម ចំពោះទេវតាទាំងនោះហៅថា ទេវតាពលី ម្យ៉ាងទៀតចំពោះសមណព្រាហ្មណ៍ ដែលប្រកបដោយសីលាចារវត្ត ជាអ្នកបំពេញកិច្ចក្នុងផ្លូវព្រះពុទ្ធសាសនា ឬបំពេញសាធារណប្រយោជន៍ដល់មហាជនទូទៅ ក៏គួរទទួលឋានៈជាបុគ្គលដែលត្រូវគោរពបូជាដែរ។

# ឋានសួគ៌ ៦ ជាន់

ក្នុងការប្រព្រឹត្តរបស់មនុស្សមានច្រើនហេតុ ច្រើនប្រការណាស់កូនប្រុសស្រី តែចំពោះបុគ្គលដែលអាចទៅកាន់ស្ថានសួគ៌បានលុះត្រាតែបុគ្គលហ្នឹងប្រព្រឹត្តតែអំពើល្អ។

ម្យ៉ាងទៀត ក្នុងស្ថានសួគ៌ក៏មានកន្លែងខុសគ្នាដែរដោយអំណាចក្នុងការប្រព្រឹត្តរបស់យើង ទៅតាមអំណាចនៃផលបុណ្យដែលជួយឃឹតយោងទៅតាមស្ថានមាន ៦ ស្ថានហើយសុទ្ធតែកន្លែងមានសេចក្ដីសុខច្រើនទៀតផង។

**១-ចាតុម្មហារាជិកា** ស្ដេចមហារាជទាំង ៤ អង្គ ជាអ្នកគ្រប់គ្រង ស្ដេចធតរដ្ឋ មានពួកគន្ធព្វជាបរិវារគ្រប់គ្រងក្នុងទិសបូព៌ា (ទិសខាងកើត) ស្ដេចវិរុឡ្ហកៈ មានពួកកុម្ភណ្ឌជាបរិវារគ្រប់គ្រងនៅក្នុងទិសទក្សិណ (ទិសខាងត្បូង) ស្ដេចវិរូបក្ខ មានពួកនាគជាបរិវារគ្រប់គ្រងនៅក្នុងទិសបស្ចិម (ទិសខាងលិច) ស្ដេចកុវេរៈ មានពួកយក្ស ជាបរិវារគ្រប់គ្រងនៅក្នុងទិសឧត្តរ (ទិសខាងជើង)។

**២-តាវត្តិង្ស** ស្ដេចវេបចិត្តិ ជាអ្នកគ្រប់គ្រង ព្រោះជាន់នេះពីដើមជាកន្លែងនៅរបស់ពួកអសុរ តមកស្ដេចសក្កទេវរាជ គឺព្រះឥន្ទ្រជាមួយទេវតា

អ្នកជាសព្រហ្មចារី ៣៣ អង្គកើតឡើងក្នុងឋានសួគ៌ជាន់នេះ ឈ្នះពួកអសុរហើយ បានគ្រប់គ្រងស្ថានសួគ៌ជាន់នេះមក។

**៣-យាមា** ស្តេចសុយាមទេវបុត្តជាអ្នកគ្រប់គ្រង។

**៤-តុសិត** ស្តេចសន្តុសិតទេវបុត្ត ជាអ្នកគ្រប់គ្រង លោកពោលថា ស្ថានសួគ៌ជាន់នេះជាទីកើត និងជាទីនៅរបស់ព្រះពោធិសត្វ និងព្រះពុទ្ធបិតា ព្រះពុទ្ធមាតា និងលោកអ្នកវិសេសដទៃៗទៀត។

**៥-និម្មានរតី** ស្តេចនិម្មិតទេវរាជ ជាអ្នកគ្រប់គ្រង លោកពោលថា ទេវតាជាន់នេះ ជាជំពូកដែលបរិបូណ៌ប្រាថ្នាវត្ថុណាមួយ ក៏និម្មិតយកខ្លួនឯង។

**៦-បរនិម្មិតវសវត្តី** ស្តេចនិម្មិតវសវត្តី ជាអ្នកគ្រប់គ្រង លោកពោលថា ទេវតាជាន់នេះ ប្រាថ្នាវត្ថុណាមួយមិនត្រូវនិម្មិតខ្លួនឯងទេ មានអ្នកដទៃនិម្មិតឱ្យមួយទៀត។

មែនពិតស្ថានសួគ៌ ៦ ជាន់នេះ អ្នកសិក្សាធ្លាប់បានជ្រាបមកហើយ តែហេតុដែលខ្ញុំយកមកសរសេរទុកក្នុងទីនេះ ក៏ដើម្បីបំណងនឹងឱ្យសៀវភៅមួយក្បាលនេះបានជារបស់ដែលគួរដឹង គួរឃើញគ្រប់ដោយបរិបូណ៌ ខ្ញុំមិនមានប្រាថ្នាជាយ៉ាងដទៃឡើយ និងក្រៃលែងជាងនោះ ឋានសួគ៌ ៦ ជាន់នេះ មិនបានជាប់ទាក់ទងជាមួយព្រះធម៌ឡើយ ការដឹងក៏ត្រឹមតែតាមក្បួនច្បាប់ប៉ុណ្ណោះ។ តែអ្នកគិតអាចយកមកប្រៀបធៀបជាមួយ

មនុស្សសម័យបច្ចុប្បន្ននេះ ក៏បានដែរ តែមិនបានសម្គាល់ថានឹងទាញរបស់ដែលធ្លាក់ចុះនោះទេ គឺត្រឹមតែគិតប្រៀបធៀបតែប៉ុណ្ណោះឯង។

# មាឃបូជា

ថ្ងៃនេះជាតិថី ពេញបូណ៌មីនៃខែមាឃ មានព្រះចន្ទពេញវង់ត្រូវនឹងថ្ងៃនៃសាវ័កសន្និបាត របស់ព្រះសក្យមុនីអរហន្តសម្មាសម្ពុទ្ធ ជាបរមគ្រូនៃយើង សាវ័កសន្និបាតនោះប្រកបដោយអង្គ ៤ គឺថ្ងៃពេញបូណ៌មី ខែមាឃមានព្រះចន្ទចរចូលមាឃនក្ខត្តឫក្ស នេះជាអង្គទី ១ ព្រះភិក្ខុសង្ឃមានចំនួន១.២៥០ អង្គ ឥតមានអ្នកណានិមន្ត ឬណាត់ពេលគ្នាសោះឡើយក៏ស្រាប់តែមកប្រជុំគ្នាក្នុងសំណាក់នៃព្រះបរមគ្រូ នាវត្តវេឡុវ័នកលន្ទកនិវាបស្ថាន ក្រុងរាជគ្រឹះ មគធរដ្ឋនៅវេលាថ្ងៃល្ងាច នេះជាអង្គទី ២ ព្រះភិក្ខុសង្ឃទាំង ១.២៥០ អង្គនោះ សុទ្ធតែជាឯហិភិក្ខុដូចគ្នាទាំងអស់ នេះជាអង្គទី ៣ ព្រះភិក្ខុសង្ឃទាំង ១.២៥០ អង្គនោះ សុទ្ធតែជាព្រះខីណាស្រពទាំងអស់ នេះជាអង្គទី ៤ ព្រះសព្វញ្ញុពុទ្ធ ទ្រង់ត្រាស់សម្តែង នូវឱវាទបាដិមោក្ខក្នុងទីប្រជុំនៃព្រះភិក្ខុសង្ឃនោះ។ ការប្រជុំសាវ័កបែបនេះ ហៅថា **ចតុរង្គសន្និបាត** គឺការប្រជុំ ប្រកបដោយអង្គ ៤ ក្នុងពុទ្ធកាលនៃព្រះសក្យមុនីបរមគ្រូនៃយើងមានតែម្តងប៉ុណ្ណោះ។ មួយទៀត កាលដែលព្រះបរមសាស្តានៃយើងទ្រង់មានព្រះជន្ម បើគិតតាមឈ្មោះខែ នៅខ្វះ ៤ ខែបើគិតតាមចំនួនថ្ងៃ នៅខ្វះ ៨៨ ថ្ងៃទៀត នឹងគ្រប់ ៨០ ឆ្នាំគត់ព្រះអង្គទ្រង់កំណត់នូវព្រះជន្មាយុសង្ខារថា ម្នាលភិក្ខុទាំងឡាយគិតពីថ្ងៃនេះទៅនៅខ្វះតែ ៣ ខែ

ទៀតទេតថាគតនឹងរំលត់ខន្ធចូលកាន់ព្រះនិញ្វាន។ ការកំណត់ជន្មាយុនេះ នៅថ្ងៃ ១៥ កើតខែមាឃដែរ តិថីនេះជាឧបលក្ខិតសម័យមួយដ៏ឧត្តម ក្នុងព្រះពុទ្ធសាសនា គឺជាថ្ងៃសម្រាប់ពុទ្ធមាមកជន ទាំងបព្វជិត និងគ្រហស្ថប្រជុំគ្នាធ្វើសក្ការបូជា ចំពោះព្រះសម្មាសម្ពុទ្ធអង្គនោះព្រមទាំងព្រះធម៌ជាបរមពុទ្ធោវាទ និងព្រះសង្ឃជាសាវ័ករបស់ព្រះអង្គ។

# ពិធីបុណ្យមាឃបូជា

មាឃបូជា ជាពីធីបុណ្យមួយដែលមានសារៈសំខាន់នៅក្នុងពុទ្ធសាសនាដែលរួមមាន មាឃបូជា ពិសាខបូជា អាសាឡ្ហបូជា និងបុណ្យបវារណា (ចេញវស្សា)។ បុណ្យមាឃបូជាប្រារព្ធឡើង ដើម្បីរំលឹកដល់ថ្ងៃដែលព្រះសម្មាសម្ពុទ្ធទ្រង់ប្រកាសបង្កើតព្រះពុទ្ធសាសនាឡើងក្នុងលោកនាប្រទេសឥណ្ឌាកាលពី ៥៨៨ ឆ្នាំ មុនគ្រិស្តសករាជ នាថ្ងៃទី ១៥ កើតខែមាឃ ក្រោយពីការត្រាស់ដឹងរបស់ព្រះអង្គចំនួន ៩ ខែគត់។ ការបង្កើតព្រះពុទ្ធសាសនា ក្នុងឋានៈជាអង្គការសាសនាមួយនេះ ធ្វើឡើងនៅក្នុងចំណោមព្រះសង្ឃចំនួន ១.២៥០ អង្គ ជាសមាជិកក្នុងអង្គមហាសន្និបាតមួយ ដែលបាននិមន្តមកពីគ្រប់ស្រទាប់វណ្ណៈទាំងអស់។ នៅក្នុងមហាសន្និបាតនោះ ព្រះសម្មាសម្ពុទ្ធទ្រង់បានប្រកាសនៅគោលការណ៍ចំនួន ១១ ប្រការ សម្រាប់ឱ្យសមាជិកមហាសន្និបាត ទាំងអស់កាន់យកជាវិថីជីវិត និងសម្រាប់យកទៅផ្សព្វផ្សាយដល់ជនដទៃទៀត បានយល់ពីពុទ្ធសាសនា ។ គោលការណ៍ ទាំង ១១ ប្រការនេះ មានឈ្មោះជាភាសាបាលីថា "ឱវាទបា្បដិមោក្ខ" ដែលពុទ្ធសាសនិកជនម្នាក់ៗ ត្រូវយកមកសិក្សាឲ្យ យល់ដឹង និងអនុវត្តដូចតទៅ : ១. គោលបំណងរបស់ ព្រះពុទ្ធសាសនា ឬក៏ដូចជាគោលបំណងរបស់ពុទ្ធសាសនិកម្នាក់ៗ គឺស្វែងរក

និព្វានដែលប្រែថា សភាវៈប្រាសចាកទុក្ខមិនមាន សេចក្ដីទុក្ខ មិនមានបញ្ហា នៅក្នុងដួងចិត្តរបស់ខ្លួន ពាក្យនិព្វាននេះ មានន័យស្មើនឹង ពាក្យថា សន្តិ ដែលប្រែថា សេចក្ដីស្ងប់។ យើងអាចនិយាយថា គោលបំណងរបស់ព្រះពុទ្ធសាសនា គឺការបង្កើតឡើងនូវសន្តិភាពក្នុងដួងចិត្តនេះដែរ ក៏ជាមូលដ្ឋានគ្រឹះនៃសន្តិភាពក្នុងសង្គម ដែលខ្លួនរស់នៅផង។ ការកាន់ព្រះពុទ្ធសាសនា គឺជាការប្រឹងប្រែង ដើម្បីបង្កើតសន្តិភាពដល់ខ្លួន និងចូលរួមចំណែកដល់សន្តិភាពសង្គម និងពិភពលោក នេះជាកាតព្វកិច្ចដែលពុទ្ធសាសនិកម្នាក់ៗត្រូវប្រឹងប្រែង ធ្វើឱ្យសម្រេច ។

២-គោលដៅ :សន្តិភាព ឬនិព្វាន មិនមែនកើតឡើងដោយការសូមបន់ស្រន់បួងសួងទេ និងក៏មិនអាចកើត ឡើងដោយសារការផ្ដល់ ឬប្រទានឲ្យ ដោយចិត្តស្រឡាញ់ មេត្តារបស់អាទិទេព ឬព្រះជាម្ចាស់អង្គណាមួយឡើយ សន្តិភាពនេះ កើតដោយសារការសន្សំ របស់សកម្មភាព ៣ យ៉ាងគឺ:

១-ការមិនធ្វើអាក្រក់ ការកម្ចាត់អំពើអាក្រក់ និងការពារអំពើអាក្រក់គ្រប់ប្រភេទ មិនឲ្យកើតក្នុងជីវិតរស់នៅទាំងផ្លូវកាយនិងផ្លូវសម្ដី។

២-ការធ្វើអំពើល្អ បង្កើតអំពើល្អ និងរក្សាអំពើល្អឲ្យ ស្ថិតស្ថេរគង់វង្សក្នុងជីវិតរស់នៅប្រចាំថ្ងៃ ទាំងអំពើល្អខាងផ្លូវកាយ និងផ្លូវសម្ដី។

៣-ពង្រឹងចិត្តដែលជាមូលដ្ឋាននៃអំពើល្អ ដោយកម្ចាត់កិលេស ឬមេរោគដែលគោង ចិត្តឲ្យអស់ទៅ រហូតដល់ចិត្តស្អាតបរិសុទ្ធ មិនមានសភាវៈអាក្រក់ស្ថិតនៅ។

## ២.លក្ខណះរបស់ព្រះពុទ្ធសាសនិកជនៈ

លក្ខខណ្ឌទី ១ មានការអត់ធ្មត់ក្នុងការធ្វើអំពើល្អ និងកម្ចាត់អំពើអាក្រក់។

លក្ខខណ្ឌទី ២ មិនប្រើអំពើហិង្សាក្នុងការរស់នៅ។

លក្ខខណ្ឌទី ៣ មិនប្រើពាក្យបៀតបៀន និងតិះដៀលអ្នកដទៃ។

លក្ខខណ្ឌទី ៤ រក្សាសីលរស់នៅក្នុងច្បាប់ យកច្បាប់ជាធំ។

លក្ខខណ្ឌទី ៥ បរិភោគប្រើប្រាស់វត្ថុទាំងឡាយដោយសន្សំសំចៃ និងស្គាល់ប្រមាណ។

លក្ខខណ្ឌទី ៦ ចូលចិត្តភាពស្ងប់ស្ងាត់ និង បង្កើតបរិយាកាសស្ងប់ស្ងាត់។

លក្ខខណ្ឌទី ៧ មានសេចក្តីព្យាយាមក្នុងការសម្អាតចិត្តធ្វើឱ្យមានសមាធិ។

៣.មេរៀនពីបុណ្យមាឃបូជា ៖ថ្ងៃនេះជាថ្ងៃដែលព្រះពុទ្ធអង្គទ្រង់ប្រកាសគោលការណ៍ទាំង ១១ ប្រការនេះសម្រាប់ជាប្រយោជន៍ដល់បរិស័ទយកទៅប្រើប្រាស់ៈ

ចំណុច ១ ក្នុងឋានៈជាបរិស័ទ ការអនុវត្តតាមប្រការទាំង ១១ នេះនឹងនាំទៅរកសន្តិភាពផ្លូវចិត្តជាពិតប្រាកដ។ ចំណុច ២ ក្នុងឋានៈជាពលរដ្ឋ ក្នុងសង្គមការដែលមានគោលបំណងរួមមានគោលដៅដូចគ្នា និងការប្រព្រឹត្ត

ប្រហាក់ប្រហែលគ្នានេះ នឹងអាចនាំមកនូវសន្តិភាព និងការអភិវឌ្ឍដែលប្រកបដោយនិរន្តរភាព។ ចំណុច ៣ ក្នុងឋានៈជាក្រុមបក្សនៅក្នុងសង្គម ឬប្រទេសជាតិមួយ ដែលព្យាយាម ស្វែងរកនូវឱកាសដើម្បីរក្សាសន្តិភាព និងជំរុញដល់ការអភិវឌ្ឍដល់ប្រទេសជាតិតែឯងនោះ ការគោពតាមគោលការណ៍ទាំង ១១ ប្រការនេះ នឹងកាត់បន្ថយបាននូវអស្ថិរភាព ជម្លោះ និងអំពើហិង្សា ដែលកើតមកពីការប្រកួតប្រជែងគ្នាបាន។ ចំណុច ៤ ក្នុង ឋានៈជាអ្នកផ្សាយសាសនា ការប្រព្រឹត្តទៅតាមគោលការណ៍នេះ នឹងនាំ ឲ្យមានការយោគយល់ការផ្តល់កិត្តិយសដល់គ្នានឹងគ្នា និងការរស់នៅជុំគ្នា ក្នុងឋានៈជាមនុស្សជាតិបាន បើទោះជាមាន សាសនាខុសគ្នាៗក៏ដោយ។ ចំណុច ៥ ក្នុងឋានជាអន្តរជាតិ ការគោរពតាមគោលការណ៍នេះ នឹងនាំមកនូវនិរន្តរភាពនៃមនុស្សជាតិបរិស្ថានធម្មជាតិ ពិភពសត្វ និងអាកាសធាតុ ដ៏យូរអង្វែង បានដោយមិនបាច់ព្រួយបារម្ភក្នុងការ ដណ្តើមគ្នាដើម្បីរស់ឡើយ។

សង្ឃឹមថាយើងម្នាក់ៗ អាចទាញយកប្រយោជន៍បានខ្លះពីថ្ងៃមាឃបូជានេះ និងអញ្ជើញនាំគ្នាធ្វើបុណ្យទានរក្សាសីល និងសមាធិសម្អាតចិត្តរបស់ខ្លួនក្នុងថ្ងៃនេះ ដើម្បីបូជា និងរំលឹកចំពោះគុណព្រះសម្មាសម្ពុទ្ធដែលព្រះអង្គបានបង្កើតព្រះពុទ្ធសាសនាសម្រាប់ជាមាគ៌ាជីវិតដល់ពួកយើងទាំងអស់គ្នា។

# នរក ៤ រូប

យើងជាពុទ្ធបរិស័ទ គួរតែមានសេចក្ដីសង្វេគតក់ស្លុតក្នុងជីវិតរស់នៅក្នុងបច្ចុប្បន្ននេះ វាមិនមានអ្វីស្ថិតស្ថេរឡើយក្នុងលោកនេះ មានការកើតឡើងហើយមានការស្ថិតនៅ និងការបាត់ទៅវិញជាធម្មតា។

